**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

UNIVERSITÉ ROYALE DE DROIT ET DES SCIENCES ÉCONOMIQUES

ROYAL UNIVERSITY OF LAW AND ECONOMICS


# សារណាបញ្ចប់ការសិក្សា

# ការចាត់ចែងក្សាការពារ

## ករណីប្រៀបធៀបការអនុវត្តការចាត់ចែងក្សាការពារកម្ពុជា-ជប៉ុន

ស្រាវជ្រាវចាប់ពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១ ដល់ថ្ងៃទី១៣ ខែសីហា ឆ្នាំ ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ៖ **លោក រេត សារៈវិចឡ្សន៍**

**កញ្ញា ស៊ុន នាគពុទ្ធគុណា**

សាស្ត្រាចារ្យណែនាំ

លោក **ភង ស៊ីផាន់ណារ៉ា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១(អាហារូបករណ៍

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

UNIVERSITÉ ROYALE DE DROIT ET DES SCIENCES ÉCONOMIQUES

ROYAL UNIVERSITY OF LAW AND ECONOMICS

# សារណាបញ្ចប់ការសិក្សា

# ការចាត់ចែងក្បួនការពារ

## ករណីប្រៀបធៀបការអនុវត្តការចាត់ចែងក្បួនការពារកម្ពុជា-ជប៉ុន

ស្រាវជ្រាវចាប់ពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១ ដល់ថ្ងៃទី១៣ ខែសីហា ឆ្នាំ ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ៖ **លោក រេត សារៈវិចឡុន៍**

**កញ្ញា ស៊ុន នាគពុទ្ធគុណា**

សាស្ត្រាចារ្យណែនាំ

លោក **ភង ស៊ីផាន់ណារ៉ា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១ (អាហារូបករណ៍

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ ផេត សារៈវិរឌ្ឍន៍ និងស៊ុន នាគពុទ្ធគុណ ជានិស្សិតផ្នែកនីតិសាស្ត្រ ជំនាន់ទី ២១នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងជានិស្សិតផ្នែកច្បាប់ជប៉ុន ជំនាន់ទី១០ នៃមជ្ឈមណ្ឌលអប់រំ និងស្រាវជ្រាវច្បាប់ជាភាសាជប៉ុន(CJL)។ ក្នុងឱកាសដ៏មានតម្លៃនេះ ជាបឋមយើងខ្ញុំទាំងពីរនាក់សូមអនុញ្ញាតសម្តែងនូវការដឹងគុណ កតញ្ញូកតវេទីចំពោះលោកអ្នកមានគុណដែលមានរាយនាមដូចខាងក្រោម៖

១. លោកឪពុក ស៊ិន ផេត និង អ្នកម្តាយ គីវ សារៈ

២.លោកឪពុក ស៊ុន ប៊ុនរិទ្ធ និង អ្នកម្តាយ ទូច មោលី

សូមធ្វើការគោរពដឹងយ៉ាងជ្រាលជ្រៅជាទីបំផុត សម្រាប់ការផ្តល់នៅកំណើតដល់យើងខ្ញុំជាមនុស្សនៅក្នុងសង្គម។ លោកទាំងបួនបានមានគុណបំណាច់យ៉ាងមហិមាដែលពុំអាចមានអ្វីយកមកកាត់ថ្លៃបាន។ រាល់ជំហាននីមួយៗរបស់យើងខ្ញុំទាំងពីរមកដល់សព្វថ្ងៃនេះ សុទ្ធតែមានបង្កប់នូវស្រមោល កម្លាំងចិត្ត និងការយកចិត្តទុកដាក់ទំនុកបំរុងស្ទើរគ្រប់បែបយ៉ាងទាំងថវិកា ដំបូន្មាន ជាពិសេសសេរីភាពលើការសម្រេចចិត្តរបស់យើងខ្ញុំ។ គុណរបស់លោកអ្នកមានគុណទាំងបួន មិនអាចរៀបរាប់ពីការចង់បង្ហាញពីទំហំទឹកចិត្តនៅក្នុងអត្ថបទប៉ុន្មានជួរនេះបានអស់នោះឡើយ។ ទន្ទឹមនឹងនេះផងដែរ យើងខ្ញុំក៏សូមធ្វើការខមាទោសចំពោះការប្រព្រឹត្តខុសឆ្គងទាំងពាក្យសម្តី និងកាយវិការទាំងចេតនាក្តី អចេតនាក្តី។

យើងខ្ញុំក៏សូមថ្លែងអំណរគុណដល់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានផ្តល់នូវចំណេះដឹងរយៈពេល ៤ឆ្នាំលើការសិក្សាច្បាប់។ សូមថ្លែងអំណរគុណដល់ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ **លុយ ចណ្ណា** ដែលបានដឹកនាំសាលាប្រកបដោយប្រសិទ្ធិភាព។ លើសពីនេះ បំណាច់គុណរបស់លោក លោកស្រីសាស្ត្រាចារ្យ បានផ្តល់ចំណេះដឹងពិតប្រាកដដល់រូបយើងខ្ញុំជានិស្សិត ថែមទាំងជួយហាត់ពត់លត់ដំចរិយាមារយាទ អប់រំ ស្មារតីឱ្យបណ្តុះខ្លួនក្លាយទៅជាពលរដ្ឋល្អ ជាទំពាំង ស្នងឬស្សី នៃប្រទេសជាតិទៀតផង។ រាល់វត្តមានរបស់លោកទាំងអស់គ្នា ទើបធ្វើឱ្យយើងខ្ញុំមានឱកាសដូចសព្វថ្ងៃនេះ។

ជាបន្ត យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ មជ្ឈមណ្ឌលអប់រំ និងស្រាវជ្រាវច្បាប់ ជប៉ុន (CJL) ព្រមទាំងអាហារូបករណ៍ អ.ម.ត ដែលបានផ្តល់អាហារូបករណ៍សិក្សារយៈពេល ៤ឆ្នាំពេញក្នុងការបន្តការសិក្សាជំនាញនីតិសាស្ត្រ។ មជ្ឈមណ្ឌលជាកន្លែងបណ្តុះបណ្តាលធនធាននិស្សិតនូវជំនាញភាសាជប៉ុន និងច្បាប់ប្រទេសជប៉ុនជាភាសាជប៉ុនដែលជួយឱ្យយើងខ្ញុំចេះភាសាជប៉ុន ចេះវិភាគ ប្រៀបធៀប និងយល់ដឹងបានស៊ីជម្រៅបន្ថែមមួយកម្រិតទៀតទៅលើប្រព័ន្ធច្បាប់កម្ពុជា និងជប៉ុន។ ដោយសារតែសាគុណដ៏ធំធេងនេះហើយទើបស្នាដៃស្រាវជ្រាវនេះបានប្រសូតឡើងបាន។

ក្នុងវេលានេះដែរ យើងខ្ញុំទាំងពីរ សូមគោរពអរគុណចំពោះ លោកសាស្ត្រាចារ្យ **កង ស៊ីផាន់ណារ៉ា** ដែលរូបលោកបានចំណាយពេលវេលា និងគំនិតយោបល់ធ្វើជាសាស្ត្រាចារ្យដឹកនាំលើស្នាដៃស្រាវជ្រាវមួយនេះ។ សារណានេះនឹងមិនអាចកើតជារូបរាងឡើងប្រសិនបើគ្មានវត្តមានលោក។ មិនត្រឹមតែប៉ុណ្ណោះ លោកសាស្ត្រាចារ្យក៏ធ្លាប់បានបណ្តុះបណ្តាលយើងខ្ញុំទាំងពីរ តាំងតែពីថ្នាក់សិក្សាមូលដ្ឋានឱ្យយល់ដឹងទៅលើមុខវិជ្ជាសេចក្តីផ្តើមនីតិ ដែលជាច្រកសំខាន់ដើម្បីទៅយល់ដឹងពីច្បាប់ដទៃៗឯទៀត។ ការបណ្តុះបណ្តាលរបស់លោកគឺធ្វើឱ្យនិស្សិតសិក្សាពិចារណាស៊ីជម្រៅទៅលើបញ្ហាច្បាប់ និងសង្គម ដោយមិនមែនជាការសិក្សាបែបសូត្រទន្ទេញសោះកក្រោះនោះទេ។ ប្រការនេះហើយជាការលើកទឹកចិត្តយ៉ាងសំខាន់ដល់ការសិក្សាស្រាវជ្រាវលើកនេះ ដែលឱ្យតម្លៃលើការពិចារណាបែបច្បាប់ ជាជាងការសូត្របែបច្បាប់។

យើងខ្ញុំទាំងពីរគ្មានអ្វីក្រៅពីម្រាមដៃដប់ លើកសំពះបួងសួងដល់វត្ថុស័ក្តិសិទ្ធឱ្យជួយតាមថែរក្សាលោកទាំងអស់គ្នាឱ្យមានសុខភាពល្អ មានសុភមង្គល និងបន្តជាធនធានក្នុងអភិវឌ្ឍសង្គមតទៅមុខទៀត។ ទង្វើប្រកបដោយមេត្តា ករុណា មុទិតា និងឧបេក្ខានេះយើងខ្ញុំសាទរនឹងទទួលយក និងព្យាយាមធ្វើជាគម្រូដល់ប្អូនជំនាន់ក្រោយៗទៀត។

# អារម្ភកថា

សារណាដែលស្ថិតក្នុងដៃរបស់មិត្តអ្នកអាននេះ គឺជាអ្វីដែលយើងខ្ញុំមានចំណាប់អារម្មណ៍យ៉ាងខ្លាំងជាងគេបំផុត អំឡុងពេលសិក្សាផ្នែកនីតិសាស្ត្រ៤ឆ្នាំកន្លងមកនេះ។ ការចាត់ចែងរក្សាការពារ ឬញ្ញត្តិអំពីការអនុវត្តដើម្បីរក្សាការពារនូវសិទ្ធិ ឬទ្រព្យសម្បត្តិដែលជាផលប្រយោជន៍ណាមួយ ដោយប្រើប្រាស់នូវអំណាចរដ្ឋ។ ដូចដែលយើងដឹងស្រាប់ហើយ ក្រមនីតិវិធីរដ្ឋប្បវេណីគឺដាក់ឱ្យនិស្សិតសិក្សានៅតែដើមឆមាសទី១នៃឆ្នាំទី៤ប៉ុណ្ណោះ។ ជាក់ស្តែងក្រមនីតិវិធីគឺមានលក្ខណៈស្មុគស្មាញជាងក្រមសារធាតុដែលបង្ហាញតែពីគោលគំនិតនៃច្បាប់មកលើសង្គម។ ភាពស្មុគស្មាញនៃក្រមនីតិវិធីរដ្ឋប្បវេណី មិនមែនស្ថិតត្រឹមតែលើសញ្ញាណ ឬទស្សនទាននៃច្បាប់ប៉ុណ្ណោះទេ តែមានការផ្សារភ្ជាប់យ៉ាងស្អិតរមួតទៅលើការអនុវត្តជាក់ស្តែងផងដែរ ព្រោះក្រមនីតិវិធីរដ្ឋប្បវេណីជាកញ្ចក់នៃការអនុវត្តច្បាប់។

គោលបំណងចម្បងនៃការស្រាវជ្រាវប្រធានបទនៃសារណានេះ មិនមានគោលបំណងពន្យល់ ឬណែនាំឱ្យអ្នកអានឱ្យយល់ថា និងនីតិវិធីនៃការចាត់ចែងរក្សាការពារលម្អិតនោះទេ (ពោលមិនមែនជាការបកស្រាយច្បាប់)។ ផ្ទុយទៅវិញគោលបំណងជាសារវន្តនៃសារណានេះ ចង់ផ្តល់ជូននូវអត្ថបទស្រាវជ្រាវផ្នែកច្បាប់ ដែលសិក្សាទៅលើការអនុវត្តជាក់ស្តែងនៃប្បញ្ញត្តិស្តីពី **ការចាត់ចែងរក្សាការពារ** ដែលត្រូវបានឃើញថាប្រើប្រាស់យ៉ាងមមាញឹកលើនីតិរដ្ឋប្បវេណី។

ប៉ុន្តែដើម្បីឈានដល់ការបកស្រាយអំពីបញ្ហាដែលចោទឡើង លុះត្រាតែសិក្សាលើវិធានគតិយុត្តិជាមុនសិនទើបយើងអាចមានលទ្ធភាពសិក្សាពីភាពប្រក្រតីលើការអនុវត្តបាន ថាតើវាមានលក្ខណៈត្រឹមត្រូវ ឬក៏ខុស។ មួយវិញទៀត អាចបង្ហាញឱ្យឃើញថាវាជាបញ្ហាដែលកើតចេញពីច្បាប់ ឬក៏កើតចេញពីការអនុវត្ត ។

ដោយសារបញ្ហាផ្នែកឯកសារ គឺយើងខ្ញុំនឹងសិក្សាទៅលើរបាយការណ៍នានារបស់អ្នកជំនាញការ JICA ដើម្បីជាមូលដ្ឋានគ្រឹះសម្រាប់បកស្រាយលើការចាត់ចែងរក្សាការពារនេះ។ នេះដោយសារតែជំនួយផ្នែកគតិយុត្តិលើច្បាប់សារធាតុ និងនីតិវិធីរដ្ឋប្បវេណីនេះ គឺខាងប្រទេសជប៉ុនជាអ្នកផ្តល់ ដូច្នេះហើយបានជាគោលគំនិត និងមាត្រាមួយផ្នែកធំនៃក្រមកម្ពុជាទាំងពីរនេះមានលក្ខណៈស្រដៀង និងដូចគ្នាដោយជុំៗទៅនឹងច្បាប់របស់ប្រទេសជប៉ុន។

ដូច្នេះ គោលបំណងសំខាន់នៃសារណានេះ គឺ ***១. ស្តែងឱ្យឃើញពីការអនុវត្តលើបញ្ញត្តិស្តីការចាត់ចែងរក្សាការពារ ក្នុងអំឡុងពេល១៨ឆ្នាំក្រោយពីការចាប់ផ្តើមអនុវត្តទៅលើក្រមនីតិវិធីរដ្ឋប្បវេណីនេះ***។ ដោយសារភាពក្មេងខ្ចីនៃវត្តមាននៃនីតិរដ្ឋមាន និងបញ្ហាធនធានមនុស្ស នេះហើយ កង្វះខាតលើការយល់ដឹងប្រាកដលេចចេញតាមរយៈការប្រើប្រាស់លើប្បញ្ញត្តិនេះ។

*២. ដោយសារតែផ្នត់គំនិតនៃច្បាប់នេះ ទទួលឥទ្ធិពលយ៉ាងសម្បើមពីច្បាប់ជប៉ុន ដូច្នេះការសិក្សាទៅលើគំនិតដើមនៃនីតិនិពន្ធ ក៏ជារឿងមួយមិនអាចរំលងបាន។* ហេតុនេះហើយ យើងខ្ញុំក៏នឹងសិក្សាទៅលើច្បាប់ដើមនៃច្បាប់ស្តីពីការចាត់ចែងរក្សាការពាររបស់ជប៉ុន ព្រមទាំងស្ថានភាពរបស់ជប៉ុនដូចគ្នា។

*៣. ជាចុងក្រោយធ្វើការសំយោគ និងផ្តល់អនុសាសន៍ផ្នែកទ្រឹស្តី ដើម្បីបំពេញបន្ថែមនូវចំណុចខ្វះខាត និងចំណុចដែលត្រូវកែកម្ម។*

ជាវិបាកនៃការតាក់តែងសារណាលើកនេះគឺ **ក**.យើងខ្ញុំមិនមែនមានដុំឯកសារនឹងដៃស្រាប់ហើយធ្វើការសរសេរនោះទេ តែជាការផ្តល់នូវព័ត៌មានដែលទទួលបានតាមតែលទ្ធភាពដើម្បីបង្ហាញលើការស្រាវជ្រាវនេះ។ ព្រោះការដែលទទួលបានទិន្នន័យខាងផ្លូវតុលាការគឺមិនទាន់មានភាពបើកចំហរនៅឡើយ។ **ខ**. វិបាកផ្នែកភាសា ចំពោះឯកសារទាក់ទងនឹងការចាត់ចែងរក្សាការពាររបស់ប្រទេសជប៉ុនគឺតម្រូវឱ្យមានសមត្ថភាពផ្នែកភាសាបច្ចេកទេសជប៉ុន ដើម្បីមានលទ្ធភាពអាននូវឯកសារនានាបាន។

ថ្វីដ្បិតស្នាដៃស្រាវជ្រាវមានការសិក្សាទៅលើអត្ថបទនានាជាច្រើនក្តី ក៏នៅមានភាពខ្វះខាតដោយមិនបានទទួលការណែនាំពីតុលាការ ឬអាជ្ញាសាលាដែលទទួលបន្ទុកលើការងារជាប្រចាំ។ ម្យ៉ាងវិញទៀតទាំងពេលវេលា និងកាលៈទេសៈពិតជាមិនអំណោយផលលើការសិក្សាប្រធានមួយនេះឱ្យបានស៊ីជម្រៅ។

ជាចុងក្រោយ បើទោះបីជាមានការត្រួតពិនិត្យលើអត្ថន័យ ខ្លឹមសារ ព្រមទាំងអក្ខរាវិរុទ្ធជាច្រើនច្រើនសារក្តី ក៏ចៀសមិនផុតពីកំហុសដែលនឹងកើតមានឡើងដោយអចេតនា និងការយល់ដឹងមិនសព្វជ្រុងជ្រោយ។ យើងខ្ញុំមិនរំពឹងអ្វី ក្រៅពីការផ្តល់ជូននូវស្នាដៃស្រាវជ្រាវមួយដល់លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តនិស្សិតអ្នកអានដើម្បីជាជំនួយស្មារតីក្នុងការសិក្សាច្បាប់នោះទេ។ យើងខ្ញុំក៏រីករាយនឹងទទួលនូវមតិរិះគន់ និងស្ថាបនានៅលើស្នាដៃនេះផងដែរ ព្រមទាំងទន្ទឹងរងចាំស្នាដៃទាក់ទងនឹងការចាត់ចែងរក្សាការពារក្រោយៗទៀតដែលមានការធ្វើទំនើបកម្មលើការស្រាវជ្រាវដើមៗកន្លងមក។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម**........................................................................................................១

## ជំពូក ១

## សញ្ញាណទូទៅនៃបទដ្ឋានគតិយុត្តិនៃការចាត់ចែងរក្សាការពារ

**ផ្នែកទី១៖ ការវិវត្តបែបគតិយុត្តិនៃការចាត់ចែងរក្សាការពារ**....................................៣

១. ប្បវត្តិនៃសញ្ញាណគតិយុត្តិលើការចាត់ចែងលើស្ថានភាពអាសន្ន........................................៣

២. វិធានគតិយុត្តិនៃការចាត់ចែងរក្សាការពារ..........................................................................៥

**ផ្នែកទី ២៖ គោលគំនិតនៃការចាត់ចែងរក្សាការពារ**......................................................៥

១. និយមន័យ និងគោលបំណងនៃការចាត់ចែងរក្សាការពារ.......................................................៥

២. ប្រភេទនៃការចាត់ចែងរក្សាការពារ....................................................................................៥

៣.រចនាសម្ព័ន្ធនៃការចាត់ចែងរក្សាការពារក្នុងនីតិវិជ្ជមាន.............................................................៦

## ជំពូកទី ២

## លំហូរនីតិវិធីនៃការចាត់ចែងរក្សាការពារ និងស្ថានភាពនៃការអនុវត្តរបស់ប្រទេសកម្ពុជា

**ផ្នែកទី ១៖ ការរឹបអូសបណ្តោះអាសន្ន**.....................................................................................៨

១.  លក្ខខណ្ឌលើសិទ្ធិដែលត្រូវរក្សាការពារ...............................................................................៨

២. កម្មវត្ថុនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន.................................................................៩

៣. ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន..............................................................................១០

៤. ការអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន................................................................១៥

**ផ្នែកទី២៖ ការចាត់ចែងជាបណ្តោះអាសន្ន**...........................................................................១៧

១. ប្រភេទ លក្ខខណ្ឌនៃការចាត់ចែងរក្សាការពារ...................................................................១៧

២. លក្ខខណ្ឌលើសិទ្ធិដែលត្រូវការពារ.................................................................................១៩

៣. នីតិវិធីនៃដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន..............................................................២១

៤. ការអនុវត្តការចាត់ចែងជាបណ្តោះអាសន្ន...........................................................................២៣

៥. អានុភាពនៃការអនុវត្តចាត់ចែងជាបណ្តោះអាសន្ន...............................................................២៥

**ផ្នែកទី ៣៖ ការធ្វើឧបាស្រ័យចំពោះដីកាសម្រេចរក្សាការពារ** ........ ២៥
១. ការតវ៉ា ........ ២៥
២. ការលុបចោលនូវការរក្សាការពារ ........ ២៦
៣. បណ្ដឹងជំទាស់ ........ ២៨

## ជំពូកទី ៣

## សញ្ញាណនៃវិធានគតិយុត្តិ និងស្ថានភាពនៃការអនុវត្តលើការចាត់ចែងបណ្ដោះអាសន្នរបស់ប្រទេសជប៉ុន

**ផ្នែកទី១៖ សញ្ញាណវិធានគតិយុត្តិនៃការចាត់ចែងរក្សាការពាររបស់ប្រទេសជប៉ុន** . ២៩
១. សញ្ញាណនៃការវិវត្តក្រមច្បាប់ស៊ីវិលរបស់ប្រទេសជប៉ុន ........ ២៩
២. សញ្ញាណនៃវិធានគតិយុត្តិលើការចាត់ចែងរក្សាការពាររបស់ប្រទេសជប៉ុន ........ ៣០
**ផ្នែកទី២៖ ស្ថានភាពទូទៅនៃការអនុវត្តលើការចាត់ចែងរក្សាការពារ រវាងកម្ពុជា និងជប៉ុន** ........ ៣០
១.ការសម្រេចឱ្យដាក់ ឬមិនដាក់ប្រាតិភោគ ........ ៣១
២. ពាក្យសុំឱ្យអនុវត្តការចាត់ចែងរក្សាការពារ ........ ៣២
៣. អនុភាពការចាត់ចែងរក្សាការពារចំពោះអចលនវត្ថុ ........ ៣៥
**ផ្នែកទី៣៖ សំយោគបញ្ហា និងដំណោះស្រាយ** ........ ៣៦
**សន្និដ្ឋាន និងអនុសាសន៍** ........ ៣៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

រដ្ឋធម្មនុញ្ញកម្ពុជា បានប្បញ្ញត្តិទៅលើសេរីភាពរបស់ប្រជាជនក្នុងការប្រើប្រាស់អំណាចរដ្ឋសម្រាប់ការស្វែងរក យុត្តិធម៌ និងផលប្រយោជន៍ដែលខ្លួនគួរនឹងទទួលបាន។ រាល់វិធាននៃសណ្ដាប់សង្គមទាំងអស់សុទ្ធតែត្រូវបានប្បញ្ញត្តិដោយច្បាប់ និងមានអានុភាពជាធរមានដើម្បីអាចយកមកដោះស្រាយលើរឿងក្ដីបុគ្គលឯកជនបាន។ ច្បាប់ត្រូវបានបែងចែកជាច្បាប់សារធាតុ និងច្បាប់នីតិវិធី។ ច្បាប់សារធាតុបានកំណត់ចម្បងអំពីបណ្ដុំនៃទំនាក់ទំនងសិទ្ធិទាំងឡាយដែលទទួលស្គាល់ដោយច្បាប់។ ឯច្បាប់នីតិវិធីវិញជា វិធាន ឬវិធីដើម្បីឱ្យបណ្ដុំសិទ្ធិទាំងនោះអាចកើតមានឡើង។ មានន័យថាច្បាប់សារធាតុជាបញ្ជីរាយមុខម្ហូប ឯច្បាប់នីតិវិធីជាបញ្ជីដែលសរសេរពីគ្រឿងផ្សំ និងវិធីធ្វើម្ហូបទាំងនោះដូចគ្នាដែរ។

ខុសពីខាងផ្នែកព្រហ្មទណ្ឌដែលកំណត់យ៉ាងតឹងរ៉ឹងពីបទល្មើស និងទោសដែលគោរពជាដាច់ខាតលើគោលការណ៍នីត្យានុកូល ផ្នែករដ្ឋប្បវេណីទទួលស្គាល់ និងឱ្យតម្លៃជាសារវន្តដល់គោលការណ៍ស្វ័យភាពបុគ្គលឯកជន មានន័យថាជាការគោរពលើឆន្ទៈរបស់ភាគីជាសំខាន់។ ជាទូទៅការធ្វើសកម្មភាពគតិយុត្តិមួយផ្នែកធំខាងរដ្ឋប្បវេណីមិនទាមទារឱ្យមានការដឹងឮជាសាធារណៈ ឬពីសំណាក់អាជ្ញាធររដ្ឋនោះទេ ត្រឹមតែជាការយល់ព្រមពីភាគី និងលិខិតសម្អាងមួយចំនួនជាការស្រេច។ វិវាទរដ្ឋប្បវេណីជាទូទៅកើតពីភាពមិនស្មោះត្រង់រវាងគ្នានិងគ្នា ក៏ប៉ុន្តែបញ្ហាកាលៈទេសៈ និងហេតុការណ៍ដែលមិនអាចប៉ាន់ស្មានមុនក៏ជាហេតុផលដែលបង្កជាវិវាទដែរដោយសារការបាត់បង់ប្រយោជន៍របស់ភាគីណាមួយ។ នៅពេលដែលវិវាទមួយកើតឡើង ការខ្ចីអំណាចរដ្ឋ គឺអំណាចតុលាការមកអនុវត្តការទាមទារសិទ្ធិជារឿងមួយដែលខានពុំបាន ប្រសិនបើយើងមិនអាចអនុវត្តសិទ្ធិសង្គ្រោះខ្លួនឯងនោះដោយខ្លួនឯងបានទេ។ បើនិយាយពីសិទ្ធិទាមទារលើសិទ្ធិលើបំណុល ឬសិទ្ធិឱ្យប្រគល់វត្ថុ និងសិទ្ធិនានាជាអាទិ៍វិញ ក្រោយពីមានសាលក្រម ឬសាលដីការបស់តុលាការ នោះការអនុវត្តដោយបង្ខំនឹងកើតមានចំពោះកូនបំណុល។ ក៏ប៉ុន្តែដោយសារស្ថានភាពអនាគត ឬគំនិតទុច្ចរិតរបស់មនុស្សដែលពិបាកនឹងទុកចិត្តបាន ការចាត់ចែងលើទ្រព្យទាំងនោះបន្តតាមរូបនៃអនុប្បទានផ្សេងអាចកើតមានឡើង ឬក៏ការខូចខាតដោយសារស្ថានដែលនឹងកើតមានមុនពេលការអនុវត្តដោយបង្ខំកើតឡើងដែលនឹងធ្វើខូតខាតទៅលើសិទ្ធិ ឬវត្ថុទាំងនោះ តែងកើតមានឡើង។ ដូច្នេះទោះមានការអនុវត្តដោយបង្ខំក៏ពិតមែន ក៏នៅតែមិនអាចបញ្ចៀសការខាតបង់របស់ម្ចាស់បំណុលបានដែរ។

ការចាត់ចែងរក្សាការពារ ជាគោលគំនិតដែលកើតឡើងដោយសារបញ្ហាទាំងនេះ។ ការចាត់ចែងរក្សាការពារ ជាការធានានូវការទាមទាររបស់ម្ចាស់បំណុលឱ្យកាន់តែមានប្រសិទ្ធិភាពបន្ថែមទៀត។ បើនិយាយពីប្រវត្តិច្បាប់ប្រទេសកម្ពុជា ដែលឈានចូលប្រព័ន្ធទំនើប គឺចាប់ពីពេលដែលមានវត្តមានបារាំងនៅលើទឹកដីខ្មែរ ហើយក្រោយមកអស្ថេរភាពផ្ទៃក្នុងបន្តអូសបន្លាយទាល់តែមកដល់ចុងទសវត្ស៩០។ ក្រោយមកការយកចិត្តទុកដាក់

លើបញ្ហាធ្វើឱ្យកម្ពុជាទទួលជំនួយច្បាប់ពីគ្រប់ទិសទី។ តួយ៉ាងដូចការចាត់ចែងរក្សាការពារ ទោះបីជាច្បាប់មានយ៉ាងណាក៏ដោយ តែដោយសារវត្តមានក្មេងខ្ចីនៃការអនុវត្តច្បាប់នេះ ព្រមទាំងភាពក្មេងខ្ចីលើទ្រឹស្តីច្បាប់នេះ ទើបបណ្តាលឱ្យមានរូបភាពនៃបញ្ហាផ្សេងកើតមានជាបន្តបន្ទាប់។ ដូច្នេះទន្ទឹមនឹងការពិនិត្យលើបញ្ហាជាក់ស្តែងក្នុងប្រទេស យើងក៏គួរតែសិក្សាទៅលើប្រទេសដែលជាម្ចាស់ជំនួយផ្នែកច្បាប់នោះផងដែរ។ ព្រោះនេះជាបទពិសោធន៍របស់ប្រទេសអនុវត្តប្បញ្ញត្តិនេះបានយូរជាងយើង។

ការអនុវត្តការចាត់ចែងរក្សាការពារនេះមានសន្ទុះខ្លាំងនៅក្នុងស្ថានភាពជាក់ស្តែង ដូច្នេះថាតើក្នុងក្របខណ្ឌច្បាប់ និងការអនុវត្តផ្ទាល់កើតមានបញ្ហាដូចម្តេចខ្លះ? នេះជាចំណោទបញ្ហាមួយដែលនឹងលើកឡើងក្នុងសារណានេះ ហើយក៏ជាបញ្ហាចម្បងនៃសារណានេះផងដែរ។

គោលបំណងនៃសារណានេះ មិនត្រឹមតែស្តែងឱ្យឃើញលើបញ្ហានៃការចាត់ចែងរក្សាការពារនោះទេ តែក៏ស្តែងឱ្យឃើញពីការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រ ទៅលើទ្រឹស្តីច្បាប់ ព្រមទាំងស្ថានភាពជាក់ស្តែងផងដែរ។

អាស្រ័យហេតុដូចខាងលើ សារណានេះ គឺនឹងធ្វើការបកស្រាយទៅលើបីជំពូកសំខាន់ៗ៖

១. សញ្ញាណទូទៅនៃបទដ្ឋានគតិយុត្តិនៃការចាត់ចែងរក្សាការពារ

២. លំហូរនីតិវិធីនៃការចាត់ចែងរក្សាការពាររបស់ប្រទេសកម្ពុជា និងស្ថានភាពនៃការអនុវត្ត

៣. សញ្ញាណនៃវិធានគតិយុត្តិ និងស្ថានភាពនៃការអនុវត្តលើការចាត់ចែងបណ្តោះអាសន្នរបស់ប្រទេសជប៉ុន។

# ជំពូក ១
# សញ្ញាណទូទៅនៃបទដ្ឋានគតិយុត្តិនៃការចាត់ចែងរក្សាការពារ

ការចាត់ចែងរក្សាការពារជានីតិវិធី ដែលមានដែនវិសាលភាពធំទូលាយ។ នីតិវិធីនេះអាចធ្វើទៅបានលុះត្រាមានដីកាសម្រេចរក្សាការពារដែលចេញពីតុលាការមានសមត្ថកិច្ច។ ការចាត់ចែងរក្សាការពារជានិតិវិធីចាំបាច់ ដើម្បីធានានូវការរក្សានៅស្ថានភាពទ្រព្យ និងសិទ្ធិដែលនឹងអាចធ្វើឱ្យការអនុវត្តដោយបង្ខំមិនអាចប្រព្រឹត្តទៅបានដោយរលូន។ ជាការចាប់ផ្តើម យើងគប្បីយល់ដឹងពីការប្រែប្រួលនៃច្បាប់ស្ថិតក្រោមទម្រង់ជាច្រើនមុននឹងឈានដល់ច្បាប់នាពេលបច្ចុប្បន្ន។ អមជាមួយគ្នានោះដែរ យើងនឹងផ្តោតសំខាន់ទៅលើការបកស្រាយសញ្ញាណនៃការចាត់ចែងរក្សាការពារថាតើអ្វីជាការចាត់ចែងរក្សាការពារ ព្រមទាំងលើកឡើងពីបទប្បញ្ញត្តិដែលបានចែងពីការចាត់ចែងរក្សាការពារ។ ដូចនេះនៅក្នុងជំពូកទី ១ យើងនឹងផ្តោតលើចំណុចសំខាន់ ២ គឺ ១. ការវិវត្តបែបគតិយុត្តិនៃការចាត់ចែងរក្សាការពារ និង ២.គោលគំនិតនៃការចាត់ចែងរក្សាការពារ។

## ផ្នែកទី១៖ ការវិវត្តបែបគតិយុត្តិនៃការចាត់ចែងរក្សាការពារ

### ១. ប្រវត្តិនៃសញ្ញាណគតិយុត្តិលើការចាត់ចែងលើស្ថានភាពអាសន្ន

ប្រវត្តិតាំងពីកកើតរដ្ឋកម្ពុជាមកក្នុងសម័យកាលដែលព្រះមហាក្សត្រមានអំណាចផ្តាច់មុខ រាល់ព្រះរាជសារដែលចេញដោយព្រះមហាក្សត្រមានអាទិភាព និងអំណាចប្រៀបដូចជាច្បាប់ដែលប្រជានុរាស្ត្រត្រូវតែគោរព និងប្រតិបត្តិតាម។ ក្រោយមកកម្ពុជាយើងចាប់ផ្តើមបង្កើតនូវច្បាប់មួយចំនួនដែលហៅថា “ក្រមច្បាប់ខ្មែរពីបុរាណ”។ ក្រមច្បាប់នេះទទួលឥទ្ធិពលមកពីគម្រាសាស្ត្រារបស់ឥណ្ឌា ហើយចំណេរក្រោយមកក៏សម្របទៅតាមបរិបទនៃទំនៀមទំលាប់សង្គមខ្មែរ។ បើក្រឡេកទៅមើលនៅពាក់កណ្តាលសតវត្សទី១៧ ព្រះមហាក្សត្រខ្មែរបានធ្វើកំណែទម្រង់ក្រមច្បាប់នានា ហើយបង្កើតបានជា“ក្រមច្បាប់ខ្មែរពីបុរាណ”នេះឡើង។ នៅពេលនៃការធ្វើវិសោធនកម្មនៅពាក់កណ្តាលដើមសតវត្សទី១៧ ចំនួននៃច្បាប់មានចំនួនសរុប២៤ច្បាប់ ហើយក្រោយមកកើនមកដល់៥២ច្បាប់ ហើយ៣៩ច្បាប់ត្រូវបានបោះពុម្ពផ្សាយក្នុងឆ្នាំ១៨៨១។[1]

ការរៀបរាប់ខាងលើនេះគឺគ្រាន់តែជាការលើកបង្ហាញពីទិដ្ឋភាពរួមលើការវិវត្តនៃសង្គមខ្មែរ និងការឈានដល់ការអនុវត្តច្បាប់ដែលមានចារជាលាយលក្ខណ៍អក្សរត្រឹមត្រូវតែប៉ុណ្ណោះ។ ត្រង់ចំណុចនេះត្បិតថាប្រមាណជាង១សតវត្សមុន កម្ពុជាដែលបានទទួលឥទ្ធិពលដោយផ្ទាល់ពីបារាំង មានក្រមច្បាប់ទាក់ទងនឹងរឿងព្រហ្មទណ្ឌ រឿងស៊ីវិលក៏ពិតមែន ក៏ប៉ុន្តែច្បាប់ទាំងនោះនៅមានសភាពមិនគ្រប់ជ្រុងជ្រោយ ព្រមទាំងមិនឯកភាពនោះ

[1] 傘谷祐之 (Kasaya Yuushi) 「植民地期カンボジアにおける法典編纂 (ការចងក្រងក្រមច្បាប់នៅក្នុងប្រទេសកម្ពុជាសម័យអាណានិគមបារាំង)」 បោះពុម្ពដោយICD NEWSលេខ៨១ ចុះថ្ងៃទី១២ ឆ្នាំ២០១៩, ទំព័រទី៣១។ ( ទស្សនាចុងក្រោយថ្ងៃទី១ ខែសីហា ឆ្នាំ២០២១ )
http://www.moj.go.jp/content/001311758.pdf

ទេ មានន័យថាមិនមានការបែងចែងច្បាស់លាស់ទៅលើច្បាប់សារធាតុ ឬច្បាប់នីតិវិធីនោះឡើយ។

ពាក្យថា "ការចាត់ចែងរក្សាការពារ" គឺមិនត្រូវបានប្រើប្រាស់ឡើយ មុនការចាប់កំណើតនៃក្រមនីតិរដ្ឋប្បវេណីបច្ចុប្បន្នចាប់កំណើត។ ផ្ទុយមកវិញយើងឃើញថាមានជំនួសមកវិញនៅការប្រើប្រាស់ពាក្យថា "វិធានការបណ្ដោះអាសន្ន" ឬ"សេចក្ដីសម្រេចមុនអង្គសេចក្ដី" ដែលត្រូវបានបង្កើតឡើងដើម្បីសម្រួលដល់ការអនុវត្តជាក់ស្ដែង។ ប៉ុន្តែវិសាលភាពនៃសេចក្ដីសម្រេចនេះមិនមានក្ខណៈច្បាស់លាស់ទៅលើខ្លឹមសារជាក់លាក់ដូចក្រមនីតិវិធីរដ្ឋប្បវេណីបច្ចុប្បន្ននេះនោះដែរ។ **"វិធានការបណ្ដោះអាសន្ន" ឬ"សេចក្ដីសម្រេចមុនអង្គសេចក្ដី"** មាន៣ប្រភេទគឺ៖ *ក.ដីកាសម្រេចតាមពាក្យសុំ ខ.ដីកាសម្រេចតាមការប្រញាប់* និង *គ.ដីកាបំបែកលំនៅដ្ឋាន*។ ដីកាទាំងបី នេះបើកឱ្យចៅក្រមពេលទទួលពាក្យបណ្ដឹង រហូតដល់ពេលជំនុំជម្រះ ចៅក្រមមានសិទ្ធិចេញដីកាសម្រេច ជាប្រញាប់តាមសំណូមពររបស់គូភាគី ប្រសិនបើយល់ថាចាំបាច់។ មូលហេតុដែលធ្វើឱ្យមានការចាត់ចែងរក្សាការពារ ជាគោលគឺបញ្ហាក្នុងការអនុវត្តដោយបង្ខំ ដូចនេះដីកាសម្រេចរក្សាការពារមានគោលដៅការពារការអន្តរាយផ្សេងៗដែលអាចកើតមានជាយថាហេតុ។ ដីកានេះសម្រេចឱ្យភាគីម្ខាងចិញ្ចឹមកូនដោយបណ្ដោះអាសន្ន។ ដីកាសម្រេចកត់ត្រាទ្រព្យសម្បត្តិ និង ប្រគល់សិទ្ធិដល់ជនណាម្នាក់ឱ្យថែរក្សាជាបណ្ដោះអាសន្ននូវទ្រព្យសម្បត្តិ ដែលមានទំនាស់ដើម្បីការពារផលប្រយោជន៍របស់គូភាគីណាមួយ[2]។

### ២. វិធានគតិយុត្តិនៃការចាត់ចែងរក្សាការពារ

ការចាត់ចែងរក្សាការពារដែលបាននិងកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ននេះ មានវត្តមាននៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីដែលប្រកាសឱ្យប្រើនៅថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ ២០០៦។ ខ្លឹមសារនៃការចាត់ចែងរក្សាការពារ មានចែងក្នុងគន្ថីទី៧ ដោយមានបែងចែកជាបីជំពូកធំៗគឺ៖ ១.បទប្បញ្ញត្តិទូទៅ ២.ដីកាចាត់ចែងរក្សាការពារ និង៣. ការអនុវត្តរក្សាការពារ។ ប៉ុន្តែដើម្បីសិក្សាទៅលើចំណុចទាំងនេះបានលុះត្រាយើងមានសញ្ញាណទាក់ទងនឹងការចាត់ចែងរក្សាការពារជាមុនសិន។

## ផ្នែកទី ២៖ គោលគំនិតនៃការចាត់ចែងរក្សាការពារ

### ១. និយមន័យ និងគោលបំណងនៃការចាត់ចែងរក្សាការពារ

ការចាត់ចែងរក្សាការពារ គឺជានីតិវិធីធានាដល់ការអនុវត្តដោយបង្ខំ ក្នុងករណីបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ឬប្រសិនបើមានការបារម្ភថានឹងមានការខូច

[2] លោក ហ៊ីង ធីឬទ្ធី, 「អត្ថាធិប្បាយ ច្បាប់ភាគ៣ ក្នុងរឿងរដ្ឋប្បវេណី」 បោះពុម្ពលើកទី២ ឆ្នាំ២០០៧, ទំព័រទី២២ ដល់៣១។ គេហទំព័រសៀវភៅអេឡិចត្រូនិច៖ http://www.elibraryofcambodia.org/atha-thibay-chbab-part3/

ខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដល់ឋានៈរបស់ភាគីណាមួយ ដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ បុគ្គលដែលមានបំណងចង់ការពារសិទ្ធិរបស់ខ្លួន អាចទាមទារការចាត់ចែងរក្សាការពារ។ [3] បើយើងស្រម៉ៃទៅលើទិដ្ឋភាពមួយថា ម្ចាស់បំណុលបានប្ដឹងកូនបំណុល ហើយចុងក្រោយតុលាការសម្រេចថាម្ចាស់បំណុលឈ្នះរឿងក្ដី ប៉ុន្តែមុនពេលតុលាការចេញសាលក្រមស្ដីពីការអនុវត្តបង្ខំលើទ្រព្យសម្បត្តិរបស់ចុងចម្លើយ ចុងចម្លើយបែរជាបានលក់ ផ្ទេរ បញ្ចាំ ឬធ្វើប្រទានកម្មលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃវិវាទរួចបាត់ទៅហើយ។ ដោយសារភាពទុច្ចរិតរបស់ជនមួយចំនួននេះហើយ ទើបកើតជាហានិភ័យក្នុងការដោះស្រាយវិវាទ ធ្វើឱ្យរាំងស្ទះនីតិវិធីអនុវត្តដោយបង្ខំ និងប៉ះពាល់ដល់ផលប្រយោជន៍របស់ម្ចាស់បំណុល។

បន្ថែមពីលើគោលបំណងខាងលើ យើងអាចនិយាយបានថា ការចាត់ចែងរក្សាការពារ ធានារក្សាឱ្យបាននូវប្រសិទ្ធភាពក្នុងដំណើរការដោះស្រាយវិវាទភាគីដោយតុលាការ។ ប្រសិនបើសាលក្រមចេញដោយតុលាការហើយ តែបែរជាមិនអាចអនុវត្តបាន នោះមន្ទិលសង្ស័យចំពោះសមត្ថភាពតុលាការក៏នឹងកើតមានឡើង។

## ២. ប្រភេទនៃការចាត់ចែងរក្សាការពារ

ការចាត់ចែងរក្សាការពារត្រូវបានបែងចែកចេញជា ២ រួមមាន៖ (១) ការរឹបអូសជាបណ្ដោះអាសន្ន និង (២)ការចាត់ចែងជាបណ្ដោះអាសន្ន។

ការរឹបអូសជាបណ្ដោះអាសន្ន គឺជាការចាត់ចែងដែលកម្រិតនូវការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីរក្សាការពារការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់។

ការចាត់ចែងជាបណ្ដោះអាសន្ន រួមមានការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ និងការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន។ ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ គឺជាការចាត់ចែងដែលរក្សាទុកនូវស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិ ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ។ ចំណែកឯការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន សំដៅលើការចាត់ចែងដែលកំណត់ស្ថានភាពជាបណ្ដោះអាសន្នរហូតដល់សាលក្រម ឬសាលដីកាចូលជាស្ថាពរ ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុលចំពោះទំនាក់ទំនងគតិយុត្តិដែលមានវិវាទ។[4]

[3] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៥៣០ (ពីពេលនេះតទៅហៅថា ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦)

[4] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦, មាត្រា ៥៣១

**៣.រចនាសម្ព័ន្ធនៃការចាត់ចែងរក្សាការពារក្នុងនីតិវិជ្ជមាន**

ចំពោះព្រះរាជាណាចក្រកម្ពុជា ការចាត់ចែងរក្សាការពារជាប្បញ្ញត្តិមួយដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី គន្ថីទី ៧ មានជំពូក ៣។ ជំពូកទី ១ ប្បញ្ញត្តិទូទៅ (ពីមាត្រា ៥៣០ រហូតដល់ មាត្រា ៥៣៩), ជំពូកទី ២ ដីកាសម្រេចការពារ (មាត្រា ៥៤០ ដល់មាត្រា ៥៦១) និងជំពូកទី ៣ ការអនុវត្តរក្សាការពារ (មាត្រា ៥៦២ ដល់មាត្រា ៥៧១)។ ការចាត់ចែងរក្សាការពារ ក៏ត្រូវបានបកស្រាយក្នុងសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគទី ២ "ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ" ក្នុងជំពូកទី ៤ មាន ៣ ផ្នែក។ ផ្នែកទី ១ គោលគំនិត ផ្នែកទី ២ ការរឹបអូសជាបណ្តោះអាសន្ន ផ្នែកទី ៣ ការចាត់ចែងជាបណ្តោះអាសន្ន។

# ជំពូកទី ២

# លំហូរនីតិវិធីនៃការចាត់ចែងរក្សាការពារ និងស្ថានភាពនៃការអនុវត្តរបស់ប្រទេសកម្ពុជា

នៅក្នុងជំពូកទី ២ យើងនឹងសិក្សាលើប្រភេទនៃការចាត់ចែងរក្សាការពារ និងការចាប់ផ្តើមនីតិវិធីរហូតដល់ការអនុវត្តដីកាសម្រេចរក្សាការពារតាមប្រភេទនៃការចាត់ចែងរក្សាការពារនីមួយៗ។ យើងបានបែងចែកជំពូកនេះជា ៣ ផ្នែក គឺ ១. ការរឹបអូសជាបណ្តោះអាសន្ន ២. ការចាត់ចែងជាបណ្តោះអាសន្ន ៣. ការធ្វើឧបាស្រ័យចំពោះដីកាសម្រេចរក្សាការពារ។

មុននឹងឈានចូលដល់ប្រភេទ និងនីតិវិធីនៃការចាត់ចែងរក្សាការពារ យើងត្រូវដឹងពីលក្ខណៈពិសេសនៃនីតិវិធីក្នុងការចាត់ចែងរក្សាការពារក្នុងន័យសង្ខេបជាមុនសិន។ លក្ខណៈពិសេសនៃការចាត់ចែងរក្សាការពារមានដូចតទៅ៖

- **លក្ខណៈបណ្តោះអាសន្ន៖** ដីកាសម្រេចរក្សាការពារមានលក្ខណៈបណ្តោះអាសន្នប៉ុណ្ណោះព្រោះនៅក្នុងបណ្តឹងអង្គសេចក្តី ដីកាសម្រេចរក្សាការពារពុំមានឥទ្ធិពលលើសាលក្រម ឬសាលដីកាឡើយ ឬអាចនិយាយបានថា ដីកានេះជាការសង្គ្រោះបណ្តោះអាសន្នក្នុងអំឡុងពេលមួយរហូតដល់អាចអនុវត្តដោយបង្ខំចំពោះកូនបំណុលបាន។
- **លក្ខណៈបន្ទាន់បង្ខំ៖** ដីកាសម្រេចរក្សាការពារមានលក្ខណៈបន្ទាន់បង្ខំនៅពេលដែលដីកាសម្រេចរក្សាការពារនោះត្រូវបានធ្វើក្នុងរយៈពេលខ្លី និងមុនពេលកូនបំណុលធ្វើការចាត់ចែងទ្រព្យសម្បត្តិ។ ចៅក្រមមានឆន្ទានុសិទ្ធិក្នុងការសម្រេចថាដីកាសម្រេចរក្សាការពារមានលក្ខណៈបន្ទាន់បង្ខំ លុះត្រាតែការទាមទារចាត់ចែងការរក្សាការពារផ្ញើឡើងក្នុងគោលបំណងដើម្បីការពារផលប្រយោជន៍ស្របច្បាប់ និងការពារការខូចខាតកម្មវត្ថុនៃវិវាទនាពេលអនាគត។ ប្រសិនបើនីតិវិធីនេះមិនត្រូវបានអនុវត្តមុនកូនបំណុលចាត់ចែងទ្រព្យសម្បត្តិនោះទេ នីតិវិធីនេះត្រូវបានចាត់ទុកថា មិនមានផលប្រយោជន៍ឡើយ។
- **លក្ខណៈសម្ងាត់៖** ដីកាសម្រេចរក្សាការពារមានលក្ខណៈសម្ងាត់ត្រង់ថា បន្ទាប់ពីម្ចាស់បំណុល ឬដើមបណ្តឹងបានដាក់ពាក្យសុំរួច តុលាការនឹងមិនផ្តល់ដំណឹងជូនទៅកូនបំណុល ឬចុងចម្លើយពីនីតិវិធីទាំងឡាយនៃការទាមទារឱ្យចាត់ចែងទ្រព្យសម្បត្តិឡើយ។ ការធ្វើបែបនេះគឺក្នុងគោលបំណងបង្ការអំពើទុច្ចរិតរបស់កូនបំណុលមួយចំនួន មានន័យថាប្រសិនបើកូនបំណុលបានដឹងពីការទាមទារឱ្យមានការចាត់ចែងរក្សាការពារ គាត់អាចនឹងធ្វើការចាត់ចែង

ទ្រព្យសម្បត្តិនោះមុនតុលាការចេញដីកាសម្រេច ជាហេតុធ្វើឱ្យមានបញ្ហាក្នុងការដោះស្រាយវិវាទនាពេលអនាគត។

## ផ្នែកទី ១៖ ការរឹបអូសបណ្ដោះអាសន្ន

### ១. លក្ខខណ្ឌលើសិទ្ធិដែលត្រូវរក្សាការពារ

សិទ្ធិដែលត្រូវបានរក្សាការពារដោយការរឹបអូសជាបណ្ដោះអាសន្នចាំបាច់ត្រូវតែជាសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ ឬហៅបានថាជា "សិទ្ធិទាមទារឱ្យសងជាប្រាក់"។ សិទ្ធិទាមទារដែលត្រូវបានរក្សាការពារ អាចជាសិទ្ធិដែលភ្ជាប់នឹងលក្ខខណ្ឌ ឬពេលកំណត់បាន។ ប៉ុន្តែ ចំពោះសិទ្ធិទាមទារដែលភ្ជាប់នឹងលក្ខខណ្ឌបង្អង់ ចាំបាច់មានអត្ថិភាពនៃមូលដ្ឋាននៃសិទ្ធិ ។[5]

ត្រង់ចំណុចនេះបានសេចក្ដីថា ដើម្បីទទួលបានសិទ្ធិដែលត្រូវរក្សាការពារ និងអាចស្នើសុំឱ្យតុលាការធ្វើការរឹបអូសទ្រព្យសម្បត្តិជាបណ្ដោះអាសន្នបាន លុះត្រាតែការទាមទារមានគោលបំណងសងជាប្រាក់ បើទោះបីសិទ្ធិនោះមានជាប់លក្ខខណ្ឌ ឬពេលកំណត់ក៏ដោយ។ មូលហេតុដែលនាំឱ្យមានការរឹបអូសបណ្ដោះអាសន្ន គឺដើម្បីការពារកុំឱ្យកូនបំណុលធ្វើការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួន ក្នុងករណីដែលកូនបំណុលមិនអាចសងប្រាក់ជូនម្ចាស់បំណុលវិញបានតាមការព្រមព្រៀង។ មិនតែប៉ុណ្ណោះ ការរឹបអូសបណ្ដោះអាសន្នក៏ជាវិធានការណ៍មួយដើម្បីអនុវត្តសាលក្រមឱ្យមានប្រសិទ្ធិភាព ព្រោះនៅពេលសាលក្រមស្ដីពីការអនុវត្តដោយបង្ខំចូលជាស្ថាពរនាពេលអនាគត មិនប្រាកដថាកូនបំណុលអាចមានលទ្ធភាពសងនោះឡើយ។ ដូចនេះក្នុងករណីបើគាត់មានទ្រព្យសម្បត្តិដែលអាចចាត់ចែងបាន តែកូនបំណុលនៅតែមិនព្រមទូទាត់ប្រាក់សងម្ចាស់បំណុលនោះឡើយ ការរឹបអូសជាបណ្ដោះអាសន្នជាវិធីសាស្ត្រការពារពីបញ្ហានេះ។ កត្តាមួយទៀតដែលនាំឱ្យមានការរឹបអូសទ្រព្យសម្បត្តិ គឺដើម្បីការពារពីអំពើខិលខូចរបស់កូនបំណុលមួយចំនួនដែលមិនព្រមសងបំណុល ហើយបែរជាធ្វើការលក់ ផ្ទេរ បញ្ចាំ ដាក់ហ៊ីប៉ូតែក ឬធ្វើប្រទានកម្ម ឬសកម្មភាពនានាចាត់ចែងលើទ្រព្យសម្បត្តិនោះ ដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់សិទ្ធិក្នុងការទាមទារបំណុលរបស់ម្ចាស់បំណុល។

ឧទាហរណ៍ បុគ្គល "ក" បានឱ្យបុគ្គល "ខ" ខ្ចីប្រាក់ចំនួន ៥០០០០$ ដោយធ្វើការសងក្នុងមួយខែ ១០០០$ ហើយបង់ជារៀងរាល់ខែ ក្នុងរយៈពេល ៥០ខែ ស្មើនឹង ៤ ឆ្នាំ ២ ខែ ដោយមិនគិតការប្រាក់។ ក៏ប៉ុន្តែក្រោយពីបង់បានរយៈពេល ៥ ខែ បុគ្គល "ខ" បានគេចវេសមិនសងប្រាក់។ តែបុគ្គល "ក" បានដឹងថា បុគ្គល "ខ" មានដីមួយកន្លែងនៅខេត្តស្វាយរៀង ដូចនេះបុគ្គល "ក" ក៏ស្នើសុំទៅតុលាការខេត្តស្វាយរៀង ដើម្បីរឹបអូសជាបណ្ដោះអាសន្នដោយសារបុគ្គល "ក" បារម្ភថាបុគ្គល "ខ" មិនសងប្រាក់របស់ខ្លួន។

[5] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦, មាត្រា ៥៤៥

ចំពោះសិទ្ធិទាមទារដែលភ្ជាប់នឹងលក្ខខណ្ឌបង្អង់ចាំបាច់មានអត្ថិភាពនៃមូលដ្ឋាននៃសិទ្ធិ សិទ្ធិដែលមានលក្ខខណ្ឌបង្អង់ សំដៅលើប្រាក់ប្រដាប់ក្តី ដែលដើមបណ្តឹងធ្វើការបង់ជាមុនសិន ប៉ុន្តែអ្នកដែលទទួលខុសត្រូវលើប្រាក់ប្រដាប់ក្តីនោះ គឺភាគីដែលចាញ់។

មួយវិញទៀត ទោះបីជាបណ្តឹងអង្គសេចក្តីអំពីសិទ្ធិដែលមានការពាក់ព័ន្ធនោះ មិនអាចដាក់ទៅតុលាការបាន ដូចជាករណីនៃសិទ្ធិទាមទារដែលភ្ជាប់នឹងកិច្ចសន្យាមជ្ឈត្តកម្ម ឬ សិទ្ធិទាមទារដែលស្ថិតក្រោមសិទ្ធិជម្រះក្តីរបស់តុលាការបរទេស ជាអាទិ៍ ក៏ដោយ ក៏អាចធ្វើការរឹបអូសជាបណ្តោះអាសន្នបានដែរ ដោយយោងទៅលើភាពចាំបាច់នៃការចាត់ចែងរក្សាការពារ។ ចំពោះសិទ្ធិទាមទារដែលកើតចេញពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង (ការទាមទារឱ្យផ្តល់អាហារកាតព្វកិច្ច ការទាមទារឱ្យបែងចែកទ្រព្យសម្បត្តិ ជាអាទិ៍) ក៏ត្រូវអនុវត្តដូចគ្នាដែរ។[6]

### ២. កម្មវត្ថុនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

កម្មវត្ថុនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន មានដូចជា អចលនវត្ថុ ចលនវត្ថុនិង សិទ្ធិលើបំណុល និងទ្រព្យសម្បត្តិ និងនាវា។

- ❖ អចលនវត្ថុ គឺជាដីធ្លី និងវត្ថុជាប់នឹងដី ហើយមិនអាចផ្លាស់ទីកន្លែងបានមានដូចជា ដី អគារ សំណង់ ។ល។
- ❖ ចលនវត្ថុ សំដៅលើវត្ថុទាំងឡាយក្រៅពីអចលនវត្ថុ[7] ឬអាចនិយាយបានថាជាវត្ថុទាំងឡាយណាដែលអាចផ្លាស់ទីបាន ដូចជាម៉ូតូ ឡាន ទូរស័ព្ទជាអាទិ៍។
- ❖ សិទ្ធិលើបំណុល និងទ្រព្យសម្បត្តិ កើតមានឡើងនៅពេលដែលម្ចាស់បំណុលមានទំនាក់ទំនងគតិយុត្តិជាមួយនឹងកូនបំណុល។
- ❖ នាវាសំដៅលើជលយានដែលមានចំណុះសរុបជាតោនស្មើនឹង និងលើសពី ២០ (ម្ភៃ) តោន ទោះជាមិនបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជាក៏ដោយ និងជលយានដែលមានចំណុះសរុបក្រោម ២០ (ម្ភៃ) តោន ហើយដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា។[8]

---

[6] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគទី ២៖ ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ, ទំព័រ ១៩៥ (ពីពេលនេះតទៅហៅថា សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគទី ២)

[7] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ខែធ្នូ ឆ្នាំ ២០០៧, មាត្រា ១២០ (ពីពេលនេះតទៅហៅថា ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧)

[8] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧, មាត្រា ៤៥៤

## ៣. នីតិវិធីសម្រេចរឹបអូសជាបណ្ដោះអាសន្ន

### ៣.១. ដែនសមត្ថកិច្ចលើរឿងក្ដីនៃការរឹបអូសជាបណ្ដោះអាសន្ន

តុលាការដែលមានសមត្ថកិច្ចផ្ដាច់មុខលើរឿងក្ដីនៃការរឹបអូសជាបណ្ដោះអាសន្ន គឺតុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី ឬសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុត្រូវរឹបអូសជាបណ្ដោះអាសន្នស្ថិតនៅ។ សូមបញ្ជាក់ថា មានតែតុលាការប៉ុណ្ណោះដែលមានសមត្ថកិច្ចផ្ដាច់មុខចំពោះរឿងក្ដីនៃការរឹបអូសបណ្ដោះអាសន្ន។[9] យោងតាមក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៥៤០ ចំពោះទ្រព្យសម្បត្តិក្រៅពីចលនវត្ថុ ៖

(១) មុនការដាក់ពាក្យបណ្ដឹងអង្គសេចក្ដី តុលាការដែលមានសមត្ថកិច្ច គឺ “តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី" សំដៅលើតុលាការនៃការជំនុំជម្រះលើកទី១ ឬសាលាដំបូងរាជធានី-ខេត្ត។ សាលាដំបូងមានសមត្ថកិច្ចតាមអង្គសេចក្ដី អនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណីមានចែងចាប់ពីមាត្រា ៧ ដល់មាត្រា ២២។ ក្នុងករណីប្រសិនបើមានតុលាការច្រើនមានសមត្ថកិច្ច នោះភាគីអាចដាក់ពាក្យសុំទៅតុលាការណាមួយក្នុងចំណោមតុលាការដែលមានសមត្ថកិច្ចទាំងនោះដោយវិនិច្ឆ័យលើការចំណេញទាំងពេលវេលា និងថវិកា។

(២) ក្រោយការដាក់ពាក្យបណ្ដឹងអង្គសេចក្ដី សាលាដំបូងដែលកំពុងធ្វើការសម្រេចសេចក្ដីលើបណ្ដឹងអង្គសេចក្ដីជាអ្នកមានសមត្ថកិច្ច។ ប៉ុន្តែបើអង្គសេចក្ដី ត្រូវបានចាត់ការក្នុងនីតិវិធីនៃបណ្ដឹងឧទ្ធរណ៍ តុលាការដែលមានសមត្ថកិច្ចគឺ តុលាការនៃការជំនុំជម្រះឧទ្ធរណ៍។

ចំពោះទ្រព្យសម្បត្តិដែលជានាវា ឬចលនវត្ថុវិញ សាលាដំបូងដែលមានសមត្ថកិច្ច គឺតុលាការដែលស្ថិតនៅទីកន្លែងនៃវត្ថុដែលត្រូវរឹបអូសជាបណ្ដោះអាសន្ន ទីតាំងទីស្នាក់ការរបស់ធនាគារ ឬ ទីតាំងដែលចលនវត្ថុស្ថិតនៅជាដើម។[10] ក្នុងករណីប្រសិនបើកម្មវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្ដោះអាសន្ន ឬកម្មវត្ថុនៃវិវាទ ជាសិទ្ធិលើបំណុលត្រូវចាត់ទុកថា សិទ្ធិលើបំណុលស្ថិតនៅកន្លែងរបស់កូនបំណុលទី ៣ ដែលបានកំណត់ក្នុងមាត្រា ៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីអំពី សមត្ថកិច្ចសាលាជម្រះក្ដីដែលបានកំណត់ទៅតាមលំនៅឋានជាអាទិ៍។[11] តើនរណាជា កូនបំណុលទី ៣ ? យោងតាមមាត្រា ៤០២ នៃក្រមនីតិវិធីរដ្ឋប្បវេណី កូនបំណុលទី ៣ ជាកូនបំណុលនៃសិទ្ធិលើបំណុលដែលនឹងត្រូវរឹបអូស។ ឧទាហរណ៍ បុគ្គល “ក” បានឱ្យ បុគ្គល “ខ” ខ្ចីប្រាក់។ រីឯ បុគ្គល “ខ” បានឱ្យ បុគ្គល “គ” ខ្ចីប្រាក់បន្ត។ នោះបុគ្គល “គ” ត្រូវបានចាត់ទុកថាជា កូនបំណុលទី ៣ របស់បុគ្គល “ក” ជាម្ចាស់បំណុល។

---

[9] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦, មាត្រា ៥៣៣

[10] លោក MAEDA YUTA, បទបង្ហាញនៅសាលាដំបូងរាជធានីភ្នំពេញស្ដីពី ការរក្សាការពារ, ថ្ងៃទី២៥ ខែមេសា ឆ្នាំ ២០១៨

[11] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦, មាត្រា ៥៤០

ប្រសិនបើពាក្យសុំត្រូវបានដាក់ទៅតុលាការដែលគ្មានសមត្ថកិច្ច តុលាការមានឆន្ទានុសិទ្ធិក្នុងការបញ្ជូនទៅតុលាការមានសមត្ថកិច្ច [12] ឬណែនាំឱ្យដើមបណ្តឹងដកពាក្យសុំ ហើយឱ្យកែតម្រូវទៅដាក់នៅតុលាការដែលមានសមត្ថកិច្ច។

## ៣.២. នីតិវិធីនៃការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

### ក. ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

ជាដំបូងដើមបណ្តឹងត្រូវដាក់ពាក្យសុំចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នទៅតុលាការ ហើយទម្រង់នៃពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវធ្វើជាលាយលក្ខណ៍អក្សរដើម្បីធានានូវភាពច្បាស់លាស់។ ពន្ធនៃការដាក់ពាក្យសុំ ត្រូវបានកំណត់ចំនួន ៥០០០ រៀល។ ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវសរសេរបញ្ជាក់នូវចំណុចដូចខាងក្រោម៖

- ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី និងអ្នកតំណាងដែលច្បាប់បានកំណត់ (ចាំបាច់ត្រូវមានអ្នកតំណាងដែលច្បាប់បានកំណត់ចំពោះអនីតិជន ជនស្ថិតក្រោមអាណាព្យាបាល ជនស្ថិតក្រោមហិតូបត្ថម្ភ)
- ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ ៖ ជាគោលការណ៍ កម្មវត្ថុនៃការ រឹបអូសជាបណ្តោះអាសន្ន ត្រូវកំណត់ឱ្យបានជាក់លាក់។ ក៏ប៉ុន្តែក្នុងករណីដែលកម្មវត្ថុនោះគឺជាចលនវត្ថុ មិនចាំបាច់កំណត់ជាក់លាក់អំពីចលនវត្ថុនីមួយៗនោះទេ តែត្រូវបញ្ជាក់អំពីទីកន្លែងនៃចលនវត្ថុនោះ។ បើវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជា បណ្តោះអាសន្ន គឺជាវត្ថុក្រៅពីចលនវត្ថុ នោះត្រូវបញ្ជាក់អំពីវត្ថុដែលជាកម្មវត្ថុនោះ។
- សិទ្ធិ ឬទំនាក់ទំនងគតិយុត្តិដែលនឹងត្រូវបានរក្សាការពារត្រូវរៀបរាប់អំពីមូលហេតុ និង ចំនួនទឹកប្រាក់ នៃសិទ្ធិទាមទារ។
- ភាពចាំបាច់នៃការរក្សាការពារ

ចំពោះចំណុចសិទ្ធិ ឬទំនាក់ទំនងគតិយុត្តិដែលនឹងត្រូវបានរក្សាការពារ និងភាពចាំបាច់នៃការរក្សាការពារត្រូវសរសេរឱ្យបានច្បាស់លាស់ និង ត្រូវសរសេរនូវភស្តុតាងតាមហេតុនីមួយៗដែលត្រូវបញ្ជាក់។[13]

### ខ. ដំណាក់កាលក្នុងការសម្រេចសេចក្តី

តុលាការមានឆន្ទានុសិទ្ធិក្នុងការកំណត់ថាមានភាពចាំបាច់ក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ឬមួយក៏មិនចាំបាច់ ព្រោះនីតិវិធីនៃដីកាសម្រេចរក្សាការពារគឺធ្វើតាមនីតិវិធីនៃការចេញដីកាសម្រេច មិនមែនធ្វើ

[12] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦, មាត្រា ១៨

[13] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦, មាត្រា ៥៤១

តាមនីតិវិធីនៃបណ្តឹងឡើយ។ [14] ពោលគឺនីតិវិធីនៃបណ្តឹងទាំងឡាយទាមទារឱ្យមានការទាញហេតុផលដោយផ្ទាល់មាត់ ចំណែកឯនីតិវិធីនៃដីកាសម្រេចមិនមានភាពចាំបាច់ក្នុងការទាញហេតុផលដោយផ្ទាល់មាត់ឡើយ កាលបើតុលាការយល់ឃើញថាមានភស្តុតាង និងទឡ្ហីករណ៍គ្រប់គ្រាន់។ ជាទូទៅដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវបានចេញដោយគ្រាន់តែសួរម្ចាស់បំណុល ឬដើមបណ្តឹង ប្រសិនបើម្ចាស់បំណុលទាមទារឱ្យធ្វើឡើងជាសម្ងាត់។ សរុបមក ការសម្រេចសេចក្តីអាចធ្វើឡើងដោយមិនចាំបាច់មានការទាញហេតុផលផ្ទាល់មាត់ ឬសាកសួរភាគីឡើយ។

នៅក្នុងដំណាក់កាលនេះផងដែរ តុលាការពិចារណា និងពិនិត្យលើឯកសារដែលម្ចាស់បំណុលបានដាក់ ហើយសម្រេចថា តើបានបំពេញលក្ខខណ្ឌហើយ ឬនៅ ថាតើមានសេចក្តីបញ្ជាក់ដំបូងអំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តិ ដែលនឹងត្រូវបានរក្សាការពារ និងភាពចាំបាច់នៃការរក្សាការពារដែរឬទេ។ ចំពោះសេចក្តីបញ្ជាក់ដំបូងចាំបាច់ជាភស្តុតាងដែលអាចពិនិត្យភ្លាមៗបាន។ ជាពិសេស តុលាការចាំបាច់ធ្វើការពិចារណាលើចំពោះចំនួននៃកម្មវត្ថុ (សិទ្ធិលើបំណុលជាដើម) ដែលអាចបែងចែកបាន មិនអាចអនុញ្ញាតឱ្យធ្វើការរឹបអូសជាបណ្តោះអាសន្ននូវផ្នែកដែលលើសពីចំនួន នៃសិទ្ធិដែលនឹងត្រូវបានរក្សាការពារទេ។ នៅពេលដែលកម្មវត្ថុ គឺជាសិទ្ធិលើបំណុល ចាំបាច់ត្រូវតែកំណត់ឱ្យបានច្បាស់អំពីចំនួនទឹកប្រាក់ដើម្បីកុំឱ្យលើសពីចំនួននៃសិទ្ធិដែលនឹងត្រូវបានរក្សាការពារ។ ក្នុងករណីដែលយកសិទ្ធិលើបំណុលដែលមានចំនួនច្រើនមកធ្វើជាកម្មវត្ថុ ត្រូវបែងចែកនូវចំនួនសិទ្ធិដែលនឹងត្រូវបានរក្សាការពារនោះទៅតាមសិទ្ធិលើបំណុលនីមួយៗ។[15]

**គ. ដំណាក់កាលការដាក់ប្រាក់ប្រាតិភោគ ឬដីកាសម្រេចអំពីប្រាតិភោគ**

ម្ចាស់បំណុល ជាអ្នកដាក់តម្កល់ប្រាតិភោគ។ ប្រាតិភោគនៃការរក្សាការពារ គឺការធានានូវការខូចខាតដែលកូនបំណុលនឹងទទួលរងដោយសារតែការអនុវត្តដីកាសម្រេចរក្សាការពារខុស។ ក្នុងករណីដែលតុលាការឱ្យដាក់ប្រាតិភោគ ជាដំបូងត្រូវកំណត់អំពីចំនួននៃប្រាតិភោគ និង កំណត់ពេលដោយដីកាសម្រេច។ ម៉្យាងទៀត ជំនួសឱ្យការបង្គាប់ឱ្យដាក់ប្រាតិភោគជាមុន តុលាការក៏អាចបង្គាប់ឱ្យដាក់ប្រាតិភោគជាលក្ខខណ្ឌសម្រាប់ការអនុវត្តការរឹបអូសជាបណ្តោះអាសន្នដែរ។ ប្រសិនបើតុលាការបានបញ្ជាក់អំពីការដាក់ប្រាតិភោគរួចហើយ តុលាការនឹងចេញដីកាសម្រេចរក្សាការពារ នោះអ្នកដាក់ប្រាតិភោគត្រូវតម្កល់ ឬ ផ្ញើប្រាក់ជាអាទិ៍នៅកន្លែងតម្កល់ (តុលាការ) រហូតដល់កំណត់ពេល ប្រសិនបើប្រាតិភោគមិនត្រូវបានដាក់ទេ តុលាការនឹងលើកចោលនូវពាក្យសុំចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។

[14] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគទី ២, ទំព័រទី ១៩៨

[15] លោក MAEDA YUTA, បទបង្ហាញនៅសាលាដំបូងរាជធានីភ្នំពេញស្តីពី ការរក្សាការពារ, ថ្ងៃទី២៥ ខែមេសា ឆ្នាំ ២០១៨

ចំនួននៃប្រាតិភោគ គឺកំណត់ដោយយកមូលដ្ឋានតាមតម្លៃរបស់កម្មវត្ថុដែលត្រូវរឹបអូស។ ក្នុងករណីអចលនវត្ថុដែលភ្ជាប់សិទ្ធិប្រាតិភោគប្រត្យក្ស ត្រូវកំណត់ដោយយកមូលដ្ឋាន តាមចំនួនដែលបានដកចំនួនប្រាតិភោគចេញ ចំនួនប្រាតិភោគក៏មានភាពខុសគ្នាទៅតាមកម្មវត្ថុផងដែរ។ ជាធម្មតា បើកម្រិតដែលកូន បំណុលនឹងត្រូវទទួលរងឥទ្ធិពលកាន់តែធំនោះ ចំនួនប្រាតិភោគក៏កាន់តែច្រើនដែរ។

**ឃ. ដំណាក់កាលចេញដីកាសម្រេចសេចក្តី**

នៅពេលដែលចេញដីកាសម្រេច តុលាការត្រូវតែកំណត់អំពីប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន។[16] កូនបំណុលអាចទទួលបានការលុបចោលនូវការអនុវត្តការរឹបអូសជាបណ្តោះអាសន្នបាន (ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ននឹងត្រូវមកជំនួសឱ្យកម្មវត្ថុ។) ប្រសិនបើបានផ្ញើប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន ។ ការរឹបអូសជាបណ្តោះអាសន្ន មានគោលបំណងរក្សាការពារនូវការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ ហេតុដូច្នេះប្រសិនបើចំនួនទឹកប្រាក់ស្មើនឹងចំនួនទឹកប្រាក់នៃសិទ្ធិទាមទារ ដែលពាក់ព័ន្ធ ត្រូវបានផ្ញើម្ចាស់បំណុលនឹងមិនទទួលការខូចខាតទេ។ ម្យ៉ាងទៀត វាអាចនឹងនាំឱ្យមានការបាត់បង់ផលប្រយោជន៍មួយចំនួនដល់កូនបំណុល ប្រសិនបើកូនបំណុលត្រូវបានហាមឃាត់ក្នុងការចាត់ចែងទ្រព្យសម្បត្តិ ដោយសារការរឹបអូសជាបណ្តោះអាសន្ននោះ ។ ហេតុនេះហើយបានជាច្បាប់អនុញ្ញាតឱ្យមាន ការរំដោះខ្លួនចេញពីការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ដោយផ្ញើប្រាក់ដែលស្មើនឹងចំនួនទឹកប្រាក់នៃសិទ្ធិទាមទារ។ ប្រាក់ដែលផ្ញើនោះ នឹងជំនួសឱ្យទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន ហើយនៅពេលដែលម្ចាស់បំណុលបានទទួលលិខិតអនុវត្តហើយម្ចាស់បំណុលអាចរឹបអូសសិទ្ធិទាមទារឱ្យប្រគល់ប្រាក់ដែលផ្ញើបាន ។

ក្នុងករណីបើខ្វះលក្ខខណ្ឌចាំបាច់សម្រាប់ការធ្វើបណ្តឹង ដែលអនុវត្តដូចគ្នាចំពោះនីតិវិធីនៃដីកាសម្រេចរក្សាការពារ (ដូចជាសមត្ថភាពភាគី និង លក្ខណៈសម្បត្តិជាភាគី) នោះពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននឹងត្រូវបានលើកចោល ប៉ុន្តែមុននឹងលើកចោល តុលាការអាចណែនាំឱ្យដើមបណ្តឹងកែតម្រូវចំណុចខ្វះខាត។ ប្រសិនបើដើមបណ្តឹងនៅតែមិនធ្វើការអនុវត្តតាមការណែនាំនោះទេ តុលាការមានសិទ្ធិក្នុងការលើចោលបណ្តឹង។[17]

បើខ្វះលក្ខខណ្ឌទាមទារសម្រាប់ការរឹបអូសជាបណ្តោះអាសន្ន ពាក្យសុំក៏នឹងត្រូវបានលើកចោលដែរ។ ចំពោះដីកាសម្រេចដែលលើកចោលពាក្យសុំនេះ អាចប្តឹងជំទាស់បាន។ អំឡុងពេលធម្មតានៃការប្តឹងជំទាស់ គឺមានរយៈពេល ១សប្តាហ៍[18] ប៉ុន្តែអំឡុងពេលនៃការប្តឹងជំទាស់ នៅក្នុងករណីនេះ ត្រូវបានកំណត់ដល់ទៅ ២ ស

[16] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦, មាត្រា ៥៤៧

[17] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦, មាត្រា ៣០៣

[18] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦, មាត្រា ៧៨

ប្ដាហ៍ ដោយយោងទៅលើភាពស្មុគស្មាញរបស់វា ។ រាល់ដីកាសម្រេចលើកចោលទាំងអស់ មិនចាំបាច់បញ្ជូនទៅកាន់កូនបំណុលទេ (មាត្រា ៥៤៣ ក្រមនីតិវិធីរដ្ឋប្បវេណី)។[19] ប៉ុន្តែ នៅក្នុងដីកាសម្រេចដែលបានលើកចោលមួយផ្នែក ក៏មានផ្នែកដែលតុលាការបានទទួលស្គាល់ក្នុងនោះដែរ ដូច្នេះចាំបាច់ត្រូវតែបញ្ជូនឱ្យទៅកូនបំណុល។

ជាទូទៅ នៅក្នុងដំណាក់កាលនេះ តុលាការមិនជូនដំណឹងទៅកូនបំណុល ឬ ស្តាប់ការលើកឡើងរបស់កូនបំណុលជាអាទិ៍ទេ។ ការសម្រេចសេចក្ដីលើពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវធ្វើឡើងដោយដីកាសម្រេច។[20] ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវចេញនៅពេលដែលលក្ខខណ្ឌទាមទារសម្រាប់ការរឹបអូសជាបណ្ដោះអាសន្ន ក៏ដូចជាលក្ខខណ្ឌចាំបាច់ផ្សេងទៀតសម្រាប់ការធ្វើបណ្ដឹង ត្រូវបានបំពេញសព្វគ្រប់។ ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន អាចធ្វើដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគបាន (មាត្រា ៥៤២)។ ជាគោលការណ៍ តុលាការត្រូវចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដោយកំណត់ជាក់លាក់នូវកម្មវត្ថុ ។ ប៉ុន្តែ ចំពោះដីកាសម្រេចរឹបអូសចលនវត្ថុជាបណ្ដោះអាសន្ន អាចចេញបាន ដោយមិនចាំបាច់កំណត់កម្មវត្ថុទេ។ តុលាការត្រូវបញ្ជូនដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នទៅភាគី។[21]

### ៤. ការអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

ការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ជាមូលដ្ឋានត្រូវធ្វើទៅតាមការអនុវត្តការរឹបអូសនៅក្នុងករណីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យសងជាប្រាក់ដែរ ។ ក៏ប៉ុន្តែ ជាគោលការណ៍ ការអនុវត្តនេះ មិនឈានចូលទៅដល់ដំណាក់កាលនៃការប្តូរជាប្រាក់ទេ។

#### ៤.១ ចំពោះចលនវត្ថុ

ជាមូលដ្ឋាន ត្រូវធ្វើតាមវិធីដូចគ្នាទៅនឹងការរឹបអូសនៅក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុដែរ។[22] ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះ ចលនវត្ថុត្រូវធ្វើឡើងតាមរបៀបកាន់កាប់វត្ថុដែលជាកម្មវត្ថុ ដោយអាជ្ញាសាលានៃសាលាដំបូងដែលមាន សមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលជាកម្មវត្ថុនោះស្ថិតនៅ។[23] ក្នុងករណីដែលកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្ន ជាប្រាក់ អាជ្ញាសាលាមិនដកហូតទុក[24] ឬ ឱ្យកូនបំណុលរក្សាទុកប្រាក់នោះទេ[25] តែអាជ្ញាសាលាត្រូវផ្ញើប្រាក់នៅតុលាការដែលខ្លួនស្ថិតនៅ។[26] វត្ថុផ្សេងទៀតក្រៅពីប្រាក់ត្រូវដក

---

[19] លោក MAEDA YUTA, បទបង្ហាញនៅសាលាដំបូងរាជធានីភ្នំពេញស្តីពី ការក្សាការពារ, ថ្ងៃទី២៥ ខែមេសា ឆ្នាំ ២០១៨

[20] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគទី ២, ទំព័រ ១៩៩ ចំណុចទី ៤ វាក្យខ័ណ្ឌទី ១

[21] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគទី ២, ទំព័រទី ១៩៩ ចំណុចទី ៤ វាក្យខ័ណ្ឌទី ៣

[22] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦, មាត្រា ៥៦៥, មាត្រា ៣៨៤, និង បញ្ញត្តិចាប់ពីមាត្រា ៣៨៥ ដល់មាត្រា ៣៩២

[23] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦, មាត្រា ៥៦៥

[24] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦, មាត្រា ៣៨៥

[25] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦, មាត្រា ៣៨៥

[26] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦, មាត្រា ៥៦៥ កថាខណ្ឌទី ២

ហូត និង រក្សាទុកដោយអាជ្ញាសាលា ។ ក៏ប៉ុន្តែ ប្រសិនបើមានការបារម្ភថា ចលនវត្ថុដែលត្រូវបានរឹបអូសជាបណ្តោះអាសន្ននោះ នឹងចុះតម្លៃយ៉ាងខ្លាំង ឬ បើត្រូវការសោហ៊ុយច្រើនហួសហេតុដើម្បីរក្សាទុកចលនវត្ថុនោះ អាជ្ញាសាលាអាចលក់ចលនវត្ថុនោះ តាមនីតិវិធីនៃការលក់នៅក្នុងការអនុវត្តដោយបង្ខំចំពោះ ចលនវត្ថុបាន តាមពាក្យសុំរបស់ម្ចាស់បំណុល ឬ កូនបំណុល។[27] នៅក្នុងករណីនេះ ប្រាក់ដែលទទួលបានពីការលក់ ត្រូវយកទៅផ្ញើនៅតុលាការដែលអាជ្ញាសាលានោះស្ថិតនៅ។ មាត្រា ៣៨៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះរថយន្ត ឬ ទោចក្រយានយន្តដែលត្រូវបានចុះបញ្ជី ។ មានន័យថា អាជ្ញាសាលាដែលធ្វើការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ត្រូវផ្តុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ច សរសេរនូវហេតុការណ៍នៃការរឹបអូសជាបណ្តោះអាសន្ន ចូលទៅ ក្នុងសៀវភៅបញ្ជី ហើយការរឹបអូសជាបណ្តោះអាសន្ននោះនឹងត្រូវមានអានុភាព នៅពេលដែលបានសរសេរ ចូលក្នុងសៀវភៅបញ្ជីនោះ ។

### ៤.២ ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ចំពោះអចលនវត្ថុ

ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ត្រូវធ្វើតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន។ ចំពោះនីតិវិធីនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុមិនមានភាពខុសគ្នាពីការរឹបអូសក្នុងការអនុវត្តដោយបង្ខំដែរ។ តុលាការដែលមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ គឺតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។[28] ក្រឡាបញ្ជី ត្រូវផ្តុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចគឺរដ្ឋបាលសុរិយោដី រាជធានីខេត្ត ចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន។ ប្រសិនបើអចលនវត្ថុដែលត្រូវបានរឹបអូសមិនទាន់បានចុះបញ្ជី ក្រឡាបញ្ជីត្រូវស្នើឱ្យស្ថាប័នមានសមត្ថកិច្ចចុះបញ្ជីលើអចលនវត្ថុ និងចុះបញ្ជីលើការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ។[29] អានុភាពនៃការរឹបអូសមានទៅលើវត្ថុដែលភ្ជាប់នឹងអចលនវត្ថុ និងជាផ្នែកមួយនៃអចលនវត្ថុ ព្រមទាំងវត្ថុចំណុះ និងសិទ្ធិចំណុះនៃអចលនវត្ថុនោះ។

### ៤.៣ ចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

ការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ត្រូវធ្វើតាមរបៀបដែលតុលាការអនុវត្តចំពោះការចាត់ចែងរក្សាការពារ ចេញដីកាសម្រេចដែលហាមឃាត់មិនឱ្យកូនបំណុលទី៣ សងទៅ កូនបំណុល។[30] តុលាការដែលមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ គឺតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។ នៅក្នុងករណីដែលការរឹបអូសជាបណ្តោះអាសន្ន ត្រូវ

[27] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦, មាត្រា ៥៦៥ កថាខណ្ឌទី ៣

[28] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦, មាត្រា ៥៦៧

[29] សំណួរដែលត្រូវបានគេសួរញឹកញាប់ស្តីពីការចាត់ចែងរក្សាការពារ, បោះពុម្ពខែឧសភា ឆ្នាំ២០០៩។ (ជាភាសាខ្មែរ និងជប៉ុន) (ខេមរភាសា)៖ http://www.moj.go.jp/content/000032475.pdf

[30] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦, មាត្រា ៥៦៦ កថាខណ្ឌទី ១ និង ទី ៤

បានអនុវត្តចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ប្រសិនបើកូនបំណុលទី ៣ បានផ្ញើប្រាក់ដែលស្មើនឹងចំនួនទឹកប្រាក់ទាំងអស់ ឬ មួយផ្នែកនៃសិទ្ធិលើបំណុលនៅតុលាការនោះនៅក្នុងចំនួនទឹកប្រាក់ទាំងអស់ដែលបានផ្ញើ ភាគដែលស្មើនឹងប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន ត្រូវចាត់ទុកថា ជាប្រាក់ដែលកូនបំណុលបានផ្ញើជាប្រាក់រំដោះ ហើយ ភាគដែលលើស ត្រូវចាត់ទុកថាជាការសងចំពោះកូនបំណុលនៃការអនុវត្ត។[31]

### ៤.៤ ចំពោះនាវា

ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះនាវា ត្រូវធ្វើតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ឬ តាមរបៀបដែលបង្គាប់ឱ្យអាជ្ញាសាលាដកហូត លិខិតបញ្ជាក់សញ្ជាតិនាវាជាអាទិ៍ ហើយផ្តល់លិខិតនោះទៅតុលាការអនុវត្តរក្សាការពារ ហើយរបៀបទាំងពីរនេះអាចអនុវត្តរួមគ្នាបាន។[32] ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន តុលាការដែលមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ គឺតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន រីឯចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នតាមរបៀបដែលបង្គាប់ឱ្យដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ តុលាការដែលមានសមត្ថកិច្ចគឺជាតុលាការអនុវត្តរក្សាការពារ គឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវានោះស្ថិតនៅ។[33] ក្រឡាបញ្ជី ត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ច ចុះបញ្ជី អំពីការរឹបអូសជាបណ្តោះអាសន្ន។ នីតិវិធីនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះនាវាជាមូលដ្ឋាន មានលក្ខណៈដូចគ្នាទៅនឹងការរឹបអូសនៅក្នុងការអនុវត្តដោយបង្ខំ ចំពោះនាវា ។

### ៤.៥ ការផ្អាកការអនុវត្តរឹបអូសជាបណ្តោះអាសន្ន

ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន អាចត្រូវបានផ្អាកក្នុងលក្ខណៈជាការផ្អាកការអនុវត្តដោយសារមានពាក្យសុំតវ៉ា ឬ ពាក្យសុំទាមទារឱ្យលុបចោលនូវដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន និង ពាក្យបណ្តឹងជំទាស់ចំពោះដីកាសម្រេចអំពីពាក្យសុំតវ៉ា ឬ ពាក្យសុំលុបចោលនោះ។ ការផ្អាកការអនុវត្តដោយសារមានការតវ៉ាចំពោះការអនុវត្ត និង ដោយសារមានការដាក់ពាក្យបណ្តឹងជំទាស់ ការផ្អាកការអនុវត្តដោយសារមានបណ្តឹងតវ៉ារបស់តតិយជនជាអាទិ៍ ។ ការផ្អាកនៅក្រោយការអនុវត្ត មិនសូវមានអត្ថន័យទេ ព្រោះថាការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ត្រូវបានបញ្ចប់នៅត្រឹមដំណាក់កាលនៃការរឹបអូសតែប៉ុណ្ណោះ។

---

[31] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦, មាត្រា ៥៦៦

[32] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦, មាត្រា ៥៦៨

[33] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦, មាត្រា ៥៦៨

### ៤.៦ ការបំលែងពីការរឹបអូសជាបណ្តោះអាសន្ន ទៅជាការអនុវត្តដោយបង្ខំ

នៅក្រោយពេលដែលការរឹបអូសជាបណ្តោះអាសន្ន ត្រូវបានអនុវត្ត ប្រសិនបើគ្រប់លក្ខខណ្ឌចាំបាច់សម្រាប់ការអនុវត្តដោយបង្ខំត្រូវបានបំពេញ ហើយម្ចាស់បំណុលបានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ដោយផ្អែកលើលិខិតអនុវត្ត នោះការរឹបអូសជាបណ្តោះអាសន្នត្រូវបំលែងទៅជាការអនុវត្តដោយបង្ខំវិញ ត្រឹមទំហំនៃការអនុវត្តនោះ។ ហេតុនេះហើយ នីតិវិធីនេះអាចឈានបន្តទៅដំណាក់កាលនៃការប្តូរជាប្រាក់បាន ដោយមិនបាច់ធ្វើនីតិវិធីដដែលសម្រាប់ការអនុវត្តដោយបង្ខំទេ ។ ប៉ុន្តែយ៉ាងណាក៏ដោយ ការអនុវត្តដោយបង្ខំ ចំពោះអចលនវត្ថុដែលតម្រូវឱ្យមានការចុះបញ្ជីអំពីការរឹបអូសដាច់ដោយឡែកពីការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន នោះត្រូវមានដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំរបស់តុលាការដែលមានសមត្ថកិច្ច ។ ក្នុងករណីដែលម្ចាស់បំណុលមានការធ្វេសប្រហែសមិនបានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ បើទោះបីជាគ្រប់លក្ខខណ្ឌចាំបាច់សម្រាប់ការអនុវត្តដោយបង្ខំ ត្រូវបានបំពេញហើយក៏ដោយនោះ កូនបំណុលអាចដាក់ពាក្យសុំឱ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដោយសារការផ្លាស់ប្តូរស្ថានភាពបាន ដោយសំអាងទៅលើ ការរលត់នៃភាពចាំបាច់នៃការរឹបអូសជាបណ្តោះអាសន្ន (មាត្រា ៥៥៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា)។[34]

## ផ្នែកទី២៖ ការចាត់ចែងជាបណ្តោះអាសន្ន

### ១. ប្រភេទ លក្ខខណ្ឌនៃការចាត់ចែងរក្សាការពារ

#### ១.១. ប្រភេទនៃការចាត់ចែងរក្សាការពារ

ខុសពីការរឹបអូសបណ្តោះអាសន្ន ដែលការពារដល់ការអនុវត្តដោយបង្ខំ ហើយអនុវត្តក្នុងគោលបំណងទាមទារឱ្យមានការសងប្រគល់ជាប្រាក់ ការចាត់ចែងបណ្តោះអាសន្នគឺធ្វើឡើងដើម្បីធានាដល់ការអនុវត្តដោយបង្ខំដូចគ្នា តែមិនមានគោលបំណងឱ្យសងជាប្រាក់នោះទេ។ បើក្រឡេកទៅមើលមាត្រា៥៣១នៃក្រមនីតិវិធីរដ្ឋប្បវេណីដែលកំណត់ពីនិយមន័យនៃការចាត់ចែងរក្សាការពារ មានទៅដល់៣ប្រភេទដាច់ពីគ្នា។

- ទី១ គឺការរឹបអូសជាបណ្តោះអាសន្ន
- ទី២ គឺ ការចាត់ចែងបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទ
- ទី៣ គឺការចាត់ចែងបណ្តោះអាសន្នដែលកំណត់ឋានៈបណ្តោះអាសន្ន។

ដោយឡែកនៅក្នុង សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២វិញបានបែងចែកប្រភេទនៃការចាត់ចែងរក្សាការពារជា ពីរ [35] គឺការរឹបអូសជាបណ្តោះអាសន្ន និងការចាត់ចែងជាបណ្តោះអាសន្ន។ ហើយនៅ

[34] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគទី ២, ទំព័រទី ២០៩

[35] សូមអាន 「សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២」 រៀបចំក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី រក្សាសិទ្ធិដោយ ក្រសួងយុត្តិធម៌ បោះពុម្ពឆ្នាំ២០០៩ ទំព័រ២១០។

ក្នុងការចាត់ចែងបណ្តោះអាសន្ននោះបែងចែងជា២ផ្នែកតូចៗទៀតគឺ ការចាត់ចែងបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទ និងការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន។ ដូច្នេះក្នុងសារណានេះយើងខ្ញុំសម្រេចបែងចែកជាពីរផ្នែកធំៗ និងពីរតូចៗដើម្បីធ្វើការបកស្រាយ។

### ១.២. ការចាត់ចែងបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទ

#### ក.ការចាត់ចែងបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់

ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ គឺជាការចាត់ចែងដែលនឹងត្រូវហាមឃាត់នូវការកែប្រែស្ថានភាពនៃអង្គហេតុដែលជាការកាន់កាប់លើវត្ថុដែលជាកម្មវត្ថុនៃវិវាទ ហើយរក្សាការពារដើម្បីអនុវត្តដោយបង្ខំនៅពេលអនាគត។ ប្រសិនបើជាការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ កូនបំណុលនៃការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ គឺជាអ្នកដែលកាន់កាប់ដោយផ្ទាល់លើវត្ថុដែលជាកម្មវត្ថុនៃវិវាទ (អ្នកដែលកាន់កាប់ដោយផ្ទាល់ ឬ អ្នកដែលជួយកាន់កាប់ ត្រូវតែមិនមែនជាកូនបំណុល)។

ឧទាហរណ៍ បុគ្គល “ក” ប្តឹងទៅ បុគ្គល “ខ” ទាមទារឱ្យប្រគល់ម៉ូតូ ហើយសាលក្រមសម្រេចថា បុគ្គល “ក” ឈ្នះក្តី ប៉ុន្តែមុនពេលតុលាកាចេញសាលក្រម បុគ្គល “ខ” នោះបានធ្វើអនុប្បទានទៅឱ្យ បុគ្គល “គ” កាន់កាប់ម៉ូតូនោះ ជាហេតុធ្វើឱ្យរាំងស្ទះការអនុវត្តដោយបង្ខំ។ ដើម្បីចៀសវាងពីបញ្ហានេះ និងការពារកុំឱ្យបញ្ហានេះកើតឡើង ទើបភាគីត្រូវទាមទារឱ្យមានការចាត់ចែងរក្សាការពារហាមឃាត់ការផ្ទេរការកាន់កាប់។

#### ខ. ការចាត់ចែងបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង

ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងដែលបានយក សិទ្ធិទាមទារឱ្យធ្វើនីតិវិធីចុះបញ្ជីមកធ្វើជាសិទ្ធិដែលត្រូវបានរក្សាការពារ គឺនឹងត្រូវហាមឃាត់កូនបំណុលកុំឱ្យលក់អចលនវត្ថុបន្តឱ្យទៅអ្នកដទៃ ហើយត្រូវចុះបញ្ជីអំពីគោលបំណងទាំងនេះចំពោះអចលនវត្ថុដែលនឹងត្រូវចាត់ចែងជាបណ្តោះអាសន្ន។ ក្នុងករណីដែលបានយកសិទ្ធិទាមទារឱ្យធ្វើនីតិវិធីចុះបញ្ជីមកធ្វើជាសិទ្ធិដែលត្រូវបានរក្សាការពារនោះ កូនបំណុលនៃការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងអចលនវត្ថុគឺ ជាបុគ្គលដែលបានចុះក្នុងបញ្ជីបច្ចុប្បន្ន។

ឧទាហរណ៍ បុគ្គល “ក” ជាម្ចាស់ដី ហើយបានលក់ដីឱ្យបុគ្គល “ខ” ក៏ប៉ុន្តែនៅពេលចុះបញ្ជីផ្ទេរកម្មសិទ្ធិរួច បុគ្គល “ខ” បែរជាមិនបានបង់ប្រាក់គ្រប់ចំនួន។ បន្ទាប់មក បុគ្គល “ក” ប្តឹងទៅ បុគ្គល “ខ” ឱ្យលុបចោលការចុះបញ្ជីផ្ទេរកម្មសិទ្ធិ តែមុនពេលតុលាការចេញសាលក្រម បុគ្គល “ខ” បានផ្ទេរកម្មសិទ្ធិទៅឱ្យបុគ្គល “គ” រួចទៅហើយ។ ដើម្បីរក្សាស្ថានភាពបច្ចុប្បន្ន និងការពារកុំឱ្យមានការចុះបញ្ជីផ្ទេរទៅតតិយជន ភាគីត្រូវស្នើសុំទៅតុលាការឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការចាត់ចែង។

## ២. លក្ខខណ្ឌលើសិទ្ធិដែលត្រូវការពារ

### ២.១ ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

សិទ្ធិត្រូវបានការពារ ត្រូវមានគោលបំណងនៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ គឺដើម្បីរក្សាស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនោះ។ ហេតុនេះហើយ សិទ្ធិទាមទារដែលត្រូវបានរក្សាការពារដោយការចាត់ចែងជាបណ្ដោះអាសន្ននេះ ត្រូវមានខ្លឹមសារជាការផ្លាស់ប្ដូរ ឬមិនផ្លាស់ប្ដូរនូវស្ថានភាពជាក់ស្ដែង ឬទំនាក់ទំនងសិទ្ធិដែលមាននៅលើវត្ថុដែលជាកម្មវត្ថុនៃវិវាទ។ សិទ្ធិដែលត្រូវបានរក្សាការពាររួមមាន សិទ្ធិទាមទារឱ្យប្រគល់វត្ថុ សិទ្ធិទាមទារឱ្យបណ្ដេញបុគ្គលចេញពីបុគ្គល សិទ្ធិទាមទារឱ្យដកចេញនូវការសាងសង់ សិទ្ធិទាមទារឱ្យចុះបញ្ជីអំពីសិទ្ធិដែលមានលើវត្ថុ សិទ្ធិទាមទារមិនឱ្យធ្វើសកម្មភាពដែលពាក់ព័ន្ធនឹងការប្រើប្រាស់វត្ថុជាអាទិ៍។ សិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេង ដែលមានគោលបំណងជាការចាត់ចែងដូចជា អនុប្បទាន និងការប្រមូលត្រូវចាត់ទុកដូចជាវត្ថុ ហើយដោយហេតុនេះអាចក្លាយជាកម្មវត្ថុនៃការចាត់ចែងជាបណ្ដោះអាសន្នប្រភេទនេះបាន។ [36] លក្ខខណ្ឌទីពីរ គឺភាពចាំបាច់នៃរក្សាការពារ។ ភាពចាំបាច់នេះ ត្រូវបានទទួលស្គាល់ក្នុងករណីដែលបារម្ភថាម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ។

យើងអាចនិយាយបានថា សិទ្ធិដែលនឹងត្រូវបានរក្សាការពារចំពោះការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ សំដៅលើសិទ្ធិទាមទារឱ្យប្រគល់វត្ថុ ឬ រើចេញពីវត្ថុ។ ចំណែកឯ សិទ្ធិដែលនឹងត្រូវបានរក្សាការពារនៃការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែង គឺសិទ្ធិទាមទារឱ្យផ្ដល់តាវកាលិកចំពោះវត្ថុដែលបានកំណត់ជាក់លាក់ដែលភាគច្រើន គឺសិទ្ធិទាមទារឱ្យចុះបញ្ជី។ ក្នុងចំណុចនេះ មិនចាំបាច់កំណត់ឱ្យបានច្បាស់លាស់ហើយលម្អិតជាងការរឹបអូសជាបណ្ដោះអាសន្នទេ ប៉ុន្តែ ចាំបាច់ត្រូវមានការអះអាង និង សេចក្ដីបញ្ជាក់ដំបូងអំពីមូលហេតុនៃការកើតឡើងលម្អិត។[37]

### ២. ២ ការចាត់ចែងបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន

យោងតាមមាត្រា៥៣១ចំណុច“គ”នៃក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់ អំពីការចាត់ចែងបណ្ដោះអាសន្នដែលកំណត់ឋានៈបណ្ដោះអាសន្នថា ជាការចាត់ចែងដែលកំណត់ស្ថានភាពជាបណ្ដោះអាសន្នរហូតដល់មានសាលក្រម ឬសាលដីកាចូលជាស្ថាពរ ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជាចៀសវាងការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដែលនឹងកើតមានដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តិដែលមានវិវាទ។ ខុសស្រឡះពីប្រភេទនៃការចាត់ចែងរក្សាការពារ.***ក.ការរឹបអូសជាបណ្ដោះអាសន្ន*** និង***ខ.ការចាត់ចែងជាបណ្ដោះ***

---

[36] សេចក្ដីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគទី ២, ទំព័រ ២១០

[37] លោក MAEDA YUTA, បទបង្ហាញនៅសាលាដំបូងរាជធានីភ្នំពេញស្ដីពី ការរក្សាការពារ, ថ្ងៃទី២៥ ខែមេសា ឆ្នាំ ២០១៨

***អាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ***ដែលមានការកំណត់ច្បាស់លាស់ ការចាត់ចែងរក្សាការពារប្រភេទ ***គ.ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ននេះ*** មានច្រើនយ៉ាង ហើយមិនមានការកំណត់ច្បាស់ទេ។ ត្រង់នេះអាចនិយាយបានមួយបែបទៀតថា ក្រៅពីប្រភេទ **"ក"** និង**"ខ"** រាល់ការចាត់ចែងរក្សាការពារទាំងអស់ចាត់បញ្ចូលជាប្រភេទ**"គ"**។

ដូច្នេះសិទ្ធិដែលត្រូវបានរក្សាការពារ គឺអាចរាប់បានចាប់ពីសិទ្ធិលើទ្រព្យសម្បត្តិ រហូតដល់សិទ្ធិដែលទាក់ទងនឹងឋានៈបុគ្គល។[38]

ដើម្បីឱ្យមានភាពងាយយល់ថាតើការចាត់ចែងរក្សាការពារប្រភេទ **"គ"** មានរូបភាពបែបណា យើងពិនិត្យទៅមើលឧទាហរណ៍ជាក់ស្តែងខ្លះដែលនិយមកើតមាននៅក្នុងសង្គម។

(១) ការបង់ប្រាក់ជាបណ្តោះអាសន្ន។

ឧទាហរណ៍ នៅពេលបុគ្គលិកម្នាក់ប្តឹងចៅហ្វាយរបស់ខ្លួនអំពីការបញ្ឈប់ការងារដោយអយុត្តិធម៌ បុគ្គលិកនោះទាមទារការបង់ប្រាក់ខែជាបណ្តោះអាសន្ន ដោយសារភាពលំបាកខាងជីវភាពរបស់គាត់ មុនពេលសាលក្រមស្តាពរនៃអង្គសេចក្តីចេញ។

ឧទាហរណ៍ នៅពេលជនរងគ្រោះ ដោយគ្រោះថ្នាក់ចរាចរណ៍ម្នាក់ធ្វើពាក្យបណ្តឹងចំពោះជនប្រព្រឹត្តិខុស ជនរង គ្រោះនោះ ទាមទារការបង់ប្រាក់ជាបណ្តោះអាសន្នដែលជាផ្នែកមួយនៃសំណងជំងឺចិត្តដោយសារភាពលំបាក ខាងជីវភាពរបស់គាត់ មុនពេលសាលក្រមនៃបណ្តឹងអង្គសេចក្តីចេញ។

(២) ការហាមឃាត់ការសាងសង់អាគារ។

ឧទាហរណ៍ នៅពេលកូនបំណុលម្នាក់ចាប់ផ្តើមការសាងសង់អាគារលើដីមួយកន្លែងដោយមិនមានសិទ្ធិអនុញ្ញាត ហើយកម្មសិទ្ធិនៃដីនោះជារបស់ម្ចាស់បំណុលម្ចាស់បំណុលនោះទាមទារការផ្អាកការសាងសង់ដោយផ្អែកលើ កម្មសិទ្ធិរបស់គាត់។

(៣) ការបណ្តេញចេញដោយបង្ខំ

ឧទាហរណ៍ នៅពេលរថយន្តមួយបានចតលើកន្លែងចតរបស់ភោជនីយដ្ឋានមួយកន្លែងអស់រយៈពេលច្រើនសប្តាហ៍ ម្ចាស់ភោជនីយដ្ឋាននោះទាមទារការយកឡានចេញជាបន្ទាន់ ដោយសារវាមានផលប៉ះពាល់អវិជ្ជមានលើមុខជំនួញ របស់គាត់។

(៤) ការហាមឃាត់នូវការបិទផ្លូវចេញចូល។ នៅពេលមានវិវាទកើតឡើងរវាងអ្នកជិតខាងអំពីសិទ្ធិចេញចូល ហើយមានអ្នកជិតខាងម្នាក់ បិទច្រកមិនឱ្យអ្នកជិតខាងម្នាក់ទៀតចេញចូលបានដោយសាងសង់របង

[38] សូមអានបន្ថែម 「សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២」 រៀបចំក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី រក្សាសិទ្ធិដោយ ក្រសួងយុត្តិធម៌ បោះពុម្ពឆ្នាំ២០០៩ ទំព័រ២១១ ដល់ ២១២។

បិទ អ្នកជិតខាងនោះទាមទារឱ្យរុះរើរបងនោះចេញ។

(៥) ការហាមឃាត់សំលេងរំខាន។

(៦) ការហាមឃាត់មិនឱ្យជួបជនណាម្នាក់។

ឧទាហរណ៍ វិធានការទប់ស្កាត់ចំពោះការប្រមូលបំណុលដោយកំពាលពីសំណាក់ជនអ្នកលេង។ វិធានការទប់ស្កាត់ចំពោះដៃគូទំនាក់ទំនងស្នេហាដែលមានបញ្ហាជំពាក់ជំពិន ដែលបង្ខំចង់ជួបគ្នា។ល។

(៧) បញ្ហាហាមមិនឱ្យបោះពុម្ពផ្សាយ

ដោយសារសិទ្ធិដែលត្រូវបានការពារមានសភាពមិនជាក់លាក់ដូច្នេះហើយ ទើបធ្វើឱ្យការចាត់ចែងរក្សាការពារប្រភេទ“គ”នេះ មានលក្ខណៈប្រាកចាកពីខុសពីប្រភេទ“ក” និង“ខ”លើការធានាដល់ការអនុវត្តដោយបង្ខំនាពេលអនាគតដើម្បីធានាសិទ្ធិរបស់ម្ចាស់បំណុល។ តែផ្ទុយមកវិញ ការចាត់ចែងរក្សាការពារប្រភេទ“គ” នេះគឺដើម្បីទប់ស្កាត់ និងដកចេញនូវគ្រោះថ្នាក់ ឬការខូចខាតពិសេសដែលកើតមានឡើងពីការមិនអនុវត្តកាតព្វកិច្ចនៃសិទ្ធិទាមទារ ដោយសារមានវិវាទអំពីអត្ថិភាពនៃសិទ្ធិទាមទារនោះដែលគេអាចទាមទារឱ្យផ្តល់តាវការលិកទាំងស្រុង ឬមួយផ្នែក តាមនីតិវិធីនៃការចាត់ចែងបណ្តោះអាសន្នបាន។ នេះហើយជាភាពចំបាច់នៃការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ននេះ។

## ៣. នីតិវិធីនៃដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន

### ៣.១ តុលាការដែលមានសមត្ថកិច្ច

មុនការដាក់ពាក្យបណ្តឹងអង្គសេចក្តី តុលាការដែលមានសមត្ថកិច្ច គឺ “តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី" សំដៅលើតុលាការនៃការជំនុំជម្រះលើកទី១ ឬសាលាដំបូងរាជធានីខេត្ត។ សាលាដំបូងមានសមត្ថកិច្ចតាមអង្គសេចក្តី អនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណីមានចែងចាប់ពីមាត្រា ៧ តទៅ។ ក្នុងករណីប្រសិនបើមានតុលាការច្រើនមានសមត្ថកិច្ច នោះភាគីអាចដាក់ពាក្យសុំទៅតុលាការណាមួយក្នុងចំណោមតុលាការដែលមានសមត្ថកិច្ចទាំងនោះដោយវិនិច្ឆ័យលើការចំណេញទាំងពេលវេលា និងថវិកា។ ក្រោយការដាក់ពាក្យបណ្តឹងអង្គសេចក្តី សាលាដំបូងដែលកំពុងធ្វើការសម្រេចសេចក្តីលើបណ្តឹងអង្គសេចក្តី ជាអ្នកមានសមត្ថកិច្ច។ ប៉ុន្តែបើអង្គសេចក្តី ត្រូវបានចាត់ការក្នុងនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ តុលាការដែលមានសមត្ថកិច្ចគឺ សាលាឧទ្ធរណ៍។

ចំពោះការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន មានតែតុលាការនៃបណ្តឹងអង្គសេចក្តីទេដែលមានសមត្ថកិច្ចផ្តាច់មុខ។

### ៣.២ ពាក្យសុំឱ្យចេញដីកាសម្រេច

យោងតាមមាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំៈ

- ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់

- ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ
- សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តិដែលនឹងត្រូវបានរក្សាការពារ
- ភាពចាំបាច់នៃការរក្សាការពារ
- អំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តិដែលត្រូវបានរក្សាការពារ និង ភាពចាំបាច់នៃ

ការរក្សាការពារ គប្បីសរសេរឱ្យបានច្បាស់លាស់ និង បញ្ជាក់នូវភស្តុតាងតាមហេតុនីមួយៗ។

### ៣.៣ ការសម្រេចសេចក្តី

ចំពោះការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ដោយសារតែជានីតិវិធីនៃដីកាសម្រេច ដូច្នេះមិនចាំបាច់ធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬ ការសួរទេ។[39] តុលាការធ្វើការពិចារណាលើឯកសារដែលម្ចាស់បំណុលបានដាក់ ហើយធ្វើការសម្រេចថាតើបានបំពេញលក្ខខណ្ឌហើយ ឬនៅ។ ជាទូទៅនៅក្នុងដំណាក់កាលនេះ តុលាការមិនជូនដំណឹងទៅកូនបំណុល ឬ ស្តាប់ការលើកឡើងរបស់ កូនបំណុលនោះទេ។ ចំណុចប្រុងប្រយ័ត្នអំពីការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់អំពីភាពចាំបាច់នៃការចាត់ចែងជាបណ្តោះអាសន្ន មានត្រឹមតែសេចក្តីបញ្ជាក់ដំបូងដែលអាចបញ្ជាក់ថា "មានការបារម្ភថា កូនបំណុលនឹងធ្វើសកម្មភាពផ្ទេរការកាន់កាប់" ក្នុងករណីដែលអនុញ្ញាតឱ្យកូនបំណុលប្រើប្រាស់វត្ថុដែលជាកម្មវត្ថុនៃវិវាទក៏បានដែរ។ ប៉ុន្តែ ករណីក្រៅពីនេះ ដោយសារតែនឹងធ្វើឱ្យកូនបំណុលទទួលរងឥទ្ធិពលធ្ងន់ធ្ងរ ដូច្នេះ ត្រូវមានសេចក្តីបញ្ជាក់ដំបូងដែលបញ្ជាក់ថា គោលបំណងនៃការរក្សាការពារសម្រាប់ការអនុវត្តដោយបង្ខំនៅពេលអនាគតមិនអាចសម្រេចបានទេ បើគ្រាន់តែផ្អែកទៅលើអានុភាពនៃការកំណត់ភាគីតែប៉ុណ្ណឹង។ បន្ថែមពីនេះទៀត ក្នុងករណីដែលតុលាការអនុញ្ញាតឱ្យម្ចាស់បំណុលប្រើប្រាស់វត្ថុដែលជាកម្មវត្ថុនៃវិវាទ ចាំបាច់ត្រូវមានសេចក្តីបញ្ជាក់ដំបូងអំពីភាពត្រឹមត្រូវក្នុងការអនុញ្ញាតឱ្យម្ចាស់បំណុលប្រើប្រាស់។

បើទោះបីជាមូលដ្ឋាន ការចាត់ចែងជាបណ្តោះអាសន្នត្រូវធ្វើឡើងជាសម្ងាត់ដូចដីកាសម្រេចរឹបអូស តែចំពោះការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន តុលាការអាចចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្នបាន លុះត្រាតែបានឆ្លងកាត់តាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬតាមកាលបរិច្ឆេទនៃការសួរដែលកូនបំណុលអាចចូលរួមបាន។

### ៣.៤ ដំណាក់កាលការដាក់ប្រាក់ប្រាតិភោគ ឬដីកាសម្រេចអំពីប្រាតិភោគ

យោងតាមក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៥៤២ ក្នុងករណីឱ្យដាក់ប្រាតិភោគ ជាដំបូងតុលាការត្រូវកំណត់អំពីចំនួននៃប្រាតិភោគ និង កំណត់ពេលដោយដីកាសម្រេច ប្រសិនបើតុលាការបានបញ្ជាក់អំពីការដាក់ប្រាតិភោគរួចហើយ និងចេញដីកាសម្រេចរក្សាការពារ។ ប្រាតិភោគនៃការរក្សាការពារ គឺការធានានូវការខូចខាតដែល

[39] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦, មាត្រា ៥៣៩

កូនបំណុលនឹងទទួលរងដោយសារតែការអនុវត្តដីកាសម្រេចរក្សាការពារខុស។ ចំនួននៃប្រាតិភោគ គឺកំណត់ដោយយកមូលដ្ឋានតាមតម្លៃរបស់កម្មវត្ថុដែលត្រូវរឹបអូស។ នៅក្នុងការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ ចំនួនប្រាតិភោគ នឹងត្រូវកំណត់ដោយយកមូលដ្ឋានតាមចំនួនថ្លៃឈ្នួល។ ប៉ុន្តែសម្រាប់ប្រទេសជប៉ុន ស្ទើរតែគ្មានការចេញដីកាសម្រេចណាដែលមិនបានបង្គាប់ឱ្យដាក់ប្រាតិភោគនោះទេ។

អ្នកដាក់ប្រាតិភោគត្រូវតម្កល់ ឬ ផ្ញើប្រាក់ជាអាទិ៍នៅកន្លែងតម្កល់នៅតុលាការ។ រហូតដល់កំណត់ពេលប្រសិនបើប្រាតិភោគមិនបានដាក់ទេ តុលាការនឹងលើកចោលពាក្យសុំចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន។[40]

### ៣.៥ ដំណាក់កាលចេញដីកាសម្រេចសេចក្តី

ក្នុងការចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ពុំមានកំណត់លក្ខខណ្ឌប្រាក់រំដោះដូចដីកាសម្រេចរឹបអូសបណ្តោះអាសន្នដើម្បីលុបចោលការអនុវត្តការចាត់ចែងឡើយ ព្រោះគោលបំណងនៃការចាត់ចាត់ជាបណ្តោះអាសន្នមិនមែនដើម្បីរក្សាការពារការអនុវត្តដោយបង្ខំក្នុងគោលបំណងសងជាប្រាក់ឡើយ។ រាល់ដីកាសម្រេចលើកចោលទាំងអស់មិនចាំបាច់បញ្ជូនទៅកាន់កូនបំណុលទេ (មាត្រា៥៤៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា)។ ប៉ុន្តែ នៅក្នុងដីកាសម្រេចដែលបានលើកចោលមួយផ្នែក ក៏មានផ្នែកដែលតុលាការបានទទួលស្គាល់ក្នុងនោះដែរ ដូច្នេះចាំបាច់ត្រូវតែបញ្ជូនឱ្យទៅកូនបំណុល។

### ៤. ការអនុវត្តការចាត់ចែងជាបណ្តោះអាសន្ន

ការចាត់ចែងជាបណ្តោះអាសន្ន ត្រូវអនុវត្តតាមវិធីដូចគ្នាទៅនឹងវិធីអនុវត្តរឹបអូសជាបណ្តោះដោយបង្ខំដែរ (មាត្រា ៥៧០នៃក្រមនីតិធីរដ្ឋប្បវេណី) ។ ដោយសារថាវិធីចាត់ចែងជាបណ្តោះអាសន្នមានច្រើន ដូច្នេះទើបពុំមានច្បាប់ណាចែងឱ្យបានជាក់លាក់អំពីវិធីនៃការអនុវត្តទេ ។ វិធីនៃការអនុវត្តវិធីមួយៗ ត្រូវអនុលោមទៅតាមវិធីដែលមានកំណត់ច្បាស់លាស់នៅក្នុងសេចក្តីសម្រេចបញ្ចប់នៃដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន។

ចំពោះការអនុវត្តចាត់ចែងជាបណ្តោះអាសន្នដែលបង្គាប់ឱ្យសងជាប្រាក់ ត្រូវអនុលោមទៅតាមវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់។ ការអនុវត្តចាត់ចែងជាបណ្តោះអាសន្នដែលបង្គាប់ឱ្យប្រគល់ ឬ បណ្តេញចេញពីអចលនវត្ថុ និង ចលនវត្ថុ ត្រូវអនុលោមទៅតាមវិធីនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ និង ចលនវត្ថុ។ ចំណែកឯការអនុវត្តចាត់ចែងជាបណ្តោះអាសន្នដែលបង្គាប់ឱ្យកូនបំណុលធ្វើ ឬ មិនធ្វើសកម្មភាពអ្វីមួយ ត្រូវអនុលោមទៅតាមវិធីនៃការអនុវត្តជំនួស (មាត្រា ៥២៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី) និង វិធានបង្ខំដោយប្រយោល (មាត្រា ៥២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ចំណែកឯកម្រិត និងវិធីសាស្ត្រនៃការចាត់ចែងជាបណ្តោះអាសន្ន ត្រូវស្ថិតក្នុងទំហំដែលចាំបាច់ដើម្បីសម្រេចនូវគោលបំណងនៃពាក្យសុំ

[40] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦, មាត្រា ៧១

ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន។ ចំពោះវិធីសាស្ត្រជាក់ស្តែងនៃការអនុវត្តការចាត់ចែងជាបណ្តោះអាសន្នមាន ៤ គឺៈ (១) ការចាត់ចែងឱ្យកូនបំណុលធ្វើ ឬមិនធ្វើអំពើណាមួយជាក់លាក់ (២) ការចាត់ចែងឱ្យកូនបំណុលផ្តល់តាវកាលិក (៣) ការចាត់ចែងឱ្យអ្នកថែរក្សាគ្រប់គ្រង វត្ថុដែលជាកម្មវត្ថុនៃការចាត់ចែងជាបណ្តោះអាសន្ន (៤) ការចាត់ចែងចាំបាច់ផ្សេងទៀត។

ការអនុវត្តចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងវត្ថុអ្វីមួយ ត្រូវអនុលោមទៅតាមវិធីនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ន។ បើដីកាសម្រេចដែលហាមឃាត់មិនឱ្យកូនបំណុលផ្ទេរការកាន់កាប់វត្ថុ និង បង្គាប់ឱ្យកូនបំណុលប្រគល់វត្ថុទៅអាជ្ញាសាលា ដោយដកហូតការកាន់កាប់នោះ ហើយបង្គាប់ឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុនោះ ដើម្បីរក្សាការពារសិទ្ធិទាមទារឱ្យប្រគល់វត្ថុនោះ អាជ្ញាសាលាត្រូវប្រកាសជាសាធារណៈថា កូនបំណុលត្រូវបានហាមឃាត់ការផ្ទេរការកាន់កាប់នោះ ហើយអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុនោះ ដោយបិតលិខិតប្រកាសជាសាធារណៈតាមរបៀបដែលពុំងាយបកចេញ ឬ ប្រកាសជាសាធារណៈ តាមរបៀបសមរម្យ ផ្សេងទៀត មាត្រា ៥៧១ នៃក្រមនីតិវិធីរដ្ឋប្បវេណីខ្មែរ) ។ មានន័យថា បើបិតប្រកាសជាសាធារណៈនៅផ្នែកខាងក្នុង នៃអាគារដែលជាកម្មវត្ថុ ប្រកាសនោះ ត្រូវបិទភ្ជាប់ទៅនឹងជញ្ជាំងនៃអាគារនោះ ឬ នៅកន្លែងណាផ្សេងដែលងាយនឹងមើលឃើញ។ បើបិទប្រកាសជាសាធារណៈនៅផ្នែកខាងក្រៅនៃអាគារ ឬ ប្រកាសជាសាធារណៈលើដីវិញក្តារប្រកាសដែលរៀបរាប់អំពីខ្លឹមសារនៃការប្រកាសជាសាធារណៈនោះត្រូវដំភ្ជាប់នឹងសសរឈើ ដោយប្រើដែកគោល ឬ ត្រូវដាក់ភ្ជាប់នឹងជញ្ជាំងខាងក្រៅនៃអាគារដោយដំដែកគោល ឬ វិធីផ្សេងៗទៀត ភ្ជាប់នឹងជញ្ជាំង ខាងក្រៅនៃអាគារ។

## ៥. អានុភាពនៃការអនុវត្តចាត់ចែងជាបណ្តោះអាសន្ន

ចំពោះការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង បើការចាត់ចែងជាបណ្តោះអាសន្នមានខ្លឹមសារជាការហាមឃាត់ការចាត់ចែងរបស់កូនបំណុលលើវត្ថុដែលជាកម្មវត្ថុនៃវិវាទ នោះស្រដៀងគ្នាទៅនឹងករណីនៃការរឹបអូសជាបណ្តោះអាសន្នដែរ ការចាត់ចែងរបស់កូនបំណុលដែលធ្វើផ្ទុយនឹងការហាមឃាត់នេះ មិនអាចតតាំងជាមួយនឹងម្ចាស់បំណុលនៃការចាត់ចែងជាបណ្តោះអាសន្នបានឡើយ ។ មានន័យថា តតិយជនដែលបានទទួលសិទ្ធិពីការចាត់ចែងនេះមិនអាចយកលទ្ធកម្មនេះ ទៅតតាំងជាមួយនឹងម្ចាស់បំណុលបានឡើយ ហើយលទ្ធកម្មនេះនឹងត្រូវបានចាត់ទុកថាពុំមានអត្ថិភាព នៅក្នុងការអនុវត្តដោយបង្ខំនៅពេលបន្ទាប់ ។

ចំពោះការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់វិញ ចំពោះការចាត់ចែងជាបណ្តោះអាសន្នណាដែលមានការប្រកាសជាសាធារណៈ បើមានការផ្ទេរការកាន់កាប់ដែលផ្ទុយនឹងការហាមឃាត់នេះ ការផ្ទេរនោះមិនអាចតតាំងជាមួយនឹងម្ចាស់បំណុលនៃការចាត់ចែងជាបណ្តោះអាសន្នបានឡើយ ។ ហេតុ

នេះហើយ ម្ចាស់បំណុលអាចធ្វើការអនុវត្តដោយបង្ខំឱ្យប្រគល់វត្ថុបាន ដោយផ្អែកលើលិខិតអនុវត្តនៃអង្គសេចក្តី (មាត្រា ៥៧១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា)។

ការចាត់ចែងជាបណ្តោះអាសន្នដោយឡែកណា ដែលរារាំងអានុភាពនៃការចាត់ចែងជាបណ្តោះអាសន្ន ឬ ដែលផ្អាកការចាត់ចែងជាបណ្តោះអាសន្នមិនត្រូវបានអនុញ្ញាតទេ ។ ដើម្បីដកចេញនូវការចាត់ចែងជាបណ្តោះអាសន្ន កូនបំណុលត្រូវដាក់ពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ឬ ការអនុវត្តការចាត់ចែងជាបណ្តោះអាសន្ន ចំណែកឯតតិយជនត្រូវដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជន ឬ ដាក់ពាក្យសុំតវ៉ាចំពោះការអនុវត្ត។ ទោះជាយ៉ាងណាក៏ដោយ ករណីដែលមានការចាត់ចែងជាបណ្តោះអាសន្នច្រើនលើកម្មវត្ថុតែមួយ មិនត្រូវបានហាមឃាត់ទេ ប្រសិនបើខ្លឹមសារនៃការចាត់ចែងជាបណ្តោះអាសន្នទាំងនោះ មិនមានខ្លឹមសារផ្ទុយគ្នា (ឧទាហរណ៍ ករណីដែលការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែង និង ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ ត្រូវបានអនុវត្តចំពោះអចលនវត្ថុតែមួយ)។[41]

## ផ្នែកទី ៣៖ ការធ្វើឧបាស្រ័យចំពោះដីកាសម្រេចរក្សាការពារ

### ១. ការតវ៉ា

ការតវ៉ាចំពោះការរក្សាការពារគឺជា វិធីនៃការធ្វើឧបាស្រ័យចំពោះដីកាសម្រេចរក្សាការពារ។ [42] ការដាក់ពាក្យសុំតវ៉ាជាសិទ្ធិមួយរបស់កូនបំណុលដើម្បីស្នើសុំឱ្យតុលាការធ្វើការវិនិច្ឆ័យរកភាពត្រឹមត្រូវនៃដីកាសម្រេចរក្សាការពារ ព្រោះមិនប្រាកដថាឱ្យតែម្ចាស់បំណុលសុទ្ធតែត្រូវឡើយឱ្យតែកូនបំណុលមានភស្តុតាងផ្ទុយមកសំអាង។ ពាក្យសុំតវ៉ា ត្រូវតែធ្វើជាលាយលក្ខណ៍អក្សរ និងមិនមានការកំណត់អំឡុងពេលឡើយឱ្យតែដីកាសម្រេចរក្សាការពារនៅមានសុពលភាព។[43] អ្នកមានសិទ្ធិដាក់ពាក្យសុំ គឺកូនបំណុលដែលទទួលបាននូវការបង្គាប់រក្សាការពារ។ សមត្ថកិច្ច គឺតុលាការដែលបានចេញដីកាសម្រេចរក្សាការពារ។[44] ឧទាហរណ៍ បើដីកាសម្រេចរក្សាការពារចេញនៅសាលាដំបូងរាជធានីភ្នំពេញ នោះកូនបំណុលដែលទទួលការបង្គាប់រក្សាការពារត្រូវដាក់ពាក្យសុំតវ៉ានៅសាលាដំបូងរាជធានីភ្នំពេញ។ ក្នុងការដាក់ពាក្យសុំតវ៉ាមិនផ្អាកការអនុវត្តនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នឡើយ លុះត្រាមានសេចក្តីសម្រេចបណ្តោះអាសន្នដោយឡែកដែលបង្គាប់ឱ្យផ្អាកការអនុវត្តរក្សាការពារ ឬលុបចោលការចាត់ចែងអនុវត្ត។[45]

[41] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគទី ២, ទំព័រទី២១៨, ២១៩ និង២២០
[42] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦, មាត្រា ៥៥០
[43] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគទី ២, ទំព័រទី ២០០, ២០១ និង២០២
[44] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦,មាត្រា ៥៥០
[45] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦, មាត្រា ៥៥១

ការវិនិច្ឆ័យចាំបាច់ត្រូវឆ្លងកាត់តាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ តាមកាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន (មាត្រា៥៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ដើម្បីអាចបញ្ចប់ការការវិនិច្ឆ័យបាន ចាំបាច់ត្រូវសម្រេចថ្ងៃបញ្ចប់ការវិនិច្ឆ័យ ដោយកំណត់អំឡុងពេលអនុគ្រោះដ៏សមរម្យ ឬ ត្រូវប្រកាសអំពីការបញ្ចប់ការវិនិច្ឆ័យនៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការសួរ ដែលភាគីទាំងសងខាងអាចចូលរួមបាន (មាត្រា៥៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

ដីកាសម្រេចចំពោះពាក្យសុំតវ៉ាដីកាសម្រេចរក្សាការពារ មាន៣ប្រភេទគឺ ការទទួលស្គាល់ (ករណីដែលរក្សានូវដីកាសម្រេចរក្សាការពារ) ការផ្លាស់ប្តូរ ឬការលុបចោលដីកាសម្រេចរក្សាការពារ។[46] ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥៥១ ក្រមនីតិវិធីរដ្ឋប្បវេណីបានចែងថា តុលាការអាចដាក់លក្ខខណ្ឌឱ្យកូនបំណុលដាក់ប្រាតិភោគបាន ក្នុងករណីដែលសម្រេចថាលុបចោលនូវដីកាសម្រេចរក្សាការពារ។ ដីកាសម្រេច នៅពេលដែលសម្រេចលុបចោលនូវដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន តុលាការអាចបង្គាប់ឱ្យធ្វើបដិទានបានតាមពាក្យសុំរបស់កូនបំណុល (មាត្រា ៥៥៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ដីកាសម្រេចដែលលុបចោលនូវដីកាសម្រេចរក្សាការពារពុំមានអានុភាពទេ បើមិនទាន់បានចូលជាស្ថាពរ ប៉ុន្តែ បើយល់ឃើញថា ចាំបាច់ពិសេស តុលាការអាចប្រកាសថា ដីកាសម្រេចនោះមានអានុភាពភ្លាមៗ (មាត្រា៥៥៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ដីកាសម្រេចចំពោះពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ត្រូវតែបញ្ជូនទៅភាគី។ ភាគីអាចប្តឹងជំទាស់បាន ប្រសិនបើមានឧបាស្រ័យលើដីកាសម្រេចចំពោះពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ។[47]

### ២. ការលុបចោលនូវការរក្សាការពារ

ប្រភេទនៃការលុបចោលការរក្សាការពារ៖ (១) ការលុបចោលការរក្សាការពារដោយសារមិនដាក់ពាក្យបណ្តឹងអង្គសេចក្តី[48] (២) ការលុបចោលការរក្សាការពារដោយសារការផ្លាស់ប្តូរស្ថានភាព[49] (៣) ការលុបចោលការរក្សាការពារដោយសារស្ថានភាពពិសេស។[50]

សូមបញ្ជាក់ថាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ការលុបចោលការរក្សាការពារអាចធ្វើបានដោយសារមិនដាក់ពាក្យបណ្តឹងអង្គសេចក្តី និងដោយសារការផ្លាស់ប្តូរស្ថានភាពប៉ុណ្ណោះ។

[46] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦, មាត្រា ៥៥៤
[47] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦, មាត្រា៥៦១
[48] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦, មាត្រា ៥៥៧
[49] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦, មាត្រា ៥៥៨
[50] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦, មាត្រា ៥៥៩

### ២.១ ការលុបចោលការរក្សាការពារដោយសារមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដី

តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ត្រូវបង្គាប់ឱ្យម្ចាស់បំណុលដាក់ពាក្យបណ្ដឹងអង្គសេចក្ដីហើយឱ្យដាក់ឯកសារបញ្ជាក់អំពីការដាក់ពាក្យបណ្ដឹងអង្គសេចក្ដីនោះ ដោយកំណត់អំឡុងពេលមិនតិចជាង ២សប្ដាហ៍ តាមពាក្យសុំរបស់កូនបំណុល។ បើម្ចាស់បំណុលមិនដាក់ឯកសារដែលបានកំណត់ខាងលើនេះក្នុងពេលដែលបានកំណត់ទេ តុលាការត្រូវលុបចោលដីកាសម្រេចរក្សាការពារ តាមពាក្យសុំរបស់កូនបំណុល។ យ៉ាងណាមិញ ក្នុងករណីដែលពាក្យបណ្ដឹងអង្គសេចក្ដីត្រូវបានដកវិញ ឬ ត្រូវបានលើកចោល នៅក្រោយពេលដែលឯកសារដែលបាន កំណត់ខាងលើត្រូវបានដាក់ ត្រូវចាត់ទុកថា ឯកសារនោះមិនបានដាក់ឡើយ។

### ២.២ ការលុបចោលការរក្សាការពារដោយសារការផ្លាស់ប្ដូរស្ថានភាព

តុលាការដែលមានសមត្ថកិច្ច គឺតុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ឬ តុលាការនៃបណ្ដឹងអង្គសេចក្ដី។ តុលាការអាចលុបចោលនូវដីកាសម្រេចរក្សាការពារបាន បើមានការរលត់នូវសិទ្ធិដែលត្រូវបានការពារ ឬ ទំនាក់ទំនងគតិយុត្តិដែលនឹងត្រូវបានរក្សាការពារ ឬ ភាពចាំបាច់នៃការរក្សាការពារ និង ស្ថានភាពផ្សេងទៀត។

ឧទាហរណ៍ សិទ្ធិដែលនឹងត្រូវបានរក្សាការពារត្រូវរលត់ដោយសារការសង ឬម្ចាស់បំណុលមិនអនុវត្តដោយបង្ខំ បើទោះបីជាបានបំពេញគ្រប់លក្ខខណ្ឌទាមទារដែលអាចឱ្យអនុវត្តដោយបង្ខំបានហើយក៏ដោយ។

តែចំពោះដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន នៅពេលដែលលុបចោលដីកាសម្រេចរួច តុលាការអាចបង្គាប់ឱ្យម្ចាស់បំណុលបង្វិល ប្រាក់ ឬវត្ថុដែលកូនបំណុលបានបង់ទៅម្ចាស់បំណុលនោះ ទៅកូនបំណុលវិញ។[51]

### ២.៣ ការលុបចោលការរក្សាការពារដោយសារស្ថានភាពពិសេស

ការលុបចោលដោយស្ថានភាពពិសេសអាចធ្វើបានចំពោះតែការចាត់ចែងជាបណ្ដោះអាសន្នតែប៉ុណ្ណោះ។ តុលាការមានសមត្ថកិច្ច គឺតុលាការដែលបានចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ឬ តុលាការនៃបណ្ដឹងអង្គសេចក្ដី។ រីឯលក្ខខណ្ឌ គឺមានការបារម្ភថា ការខូចខាតដែលមិនអាចសងបាន នឹងកើតឡើងដោយសារដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ឬ មានស្ថានភាពពិសេសផ្សេងទៀត។ យោងតាមសេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ករណីទីមួយដែលត្រូវបានចាត់ទុកថាជា ស្ថានភាពពិសេស គឺជាករណីដែលគោលបំណងនៃការចាត់ចែងជាបណ្ដោះអាសន្នអាចសម្រេចបានតាមរយៈការសងជាប្រាក់ទៅឱ្យម្ចាស់បំណុល បើទោះបីជាសិទ្ធិទាមទារគ្មានគោលបំណងឱ្យសងជាប្រាក់ឡើយ ឬមានសិទ្ធិទាមទារឱ្យសងជាប្រាក់

[51] សូមអានបន្ថែមក្នុងសេចក្ដីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគទី ២, ទំព័រទី ២១៥ និង ២១៦

ស្ថិតនៅពីក្រោយការចាត់ចែងជាបណ្ដោះអាសន្ន ដូចនេះតុលាការអាចលុបចោលដីការក្សាការពារបានយោងតាមអង្គហេតុខាងលើ។

ករណីទីពីរ គឺករណីដែលថ្លឹងថ្លែងលើគោលការណ៍សមធម៌រវាងម្ចាស់បំណុល និងកូនបំណុល បានសេចក្ដីថា តុលាការត្រូវពិចារណាទៅលើការខូចខាតរបស់កូនបំណុលពីការចាត់ចែងបណ្ដោះអាសន្ន នឹងការខូចខាតរបស់ម្ចាស់បំណុល ប្រសិនបើមិនអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន។ ក្នុងករណីបើប្រៀបធៀបទំហំនៃការខូចខាតហើយ តុលាការយល់ឃើញថាការខូចខាតរបស់កូនបំណុលនៅពេលមានការចាត់ចែងជាបណ្ដោះអាសន្នមានទំហំធំខ្លាំងជាងការខូចខាតរបស់ម្ចាស់បំណុល ប្រសិនបើមិនអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ហើយតុលាការបានចេញនូវដីកាសម្រេចចាត់ចែងបណ្ដោះអាសន្ន ដូចនេះដីកាសម្រេចនោះ ត្រូវបានចាត់ទុកថា ផ្ទុយនឹងគោលការណ៍សមធម៌។ យោងតាមហេតុផលខាងលើ កូនបំណុលអាចធ្វើសេចក្ដីបញ្ជាក់ដំបូងទៅតុលាការ និងស្នើសុំឱ្យលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នបាន។

នៅពេលដែលចេញដីកាសម្រេច តុលាការត្រូវតែមានលក្ខខណ្ឌដែលតម្រូវឱ្យដាក់ប្រាតិភោគ។

### ៣. បណ្ដឹងជំទាស់

បណ្ដឹងជំទាស់ ផ្ដល់ឱកាសដល់ភាគីដើម្បីទទួលបាននូវការវិនិច្ឆ័យពីតុលាការ ពេលដែលតុលាការចេញដីកាសម្រេច តែភាគីនៅតែមិនសុខចិត្ត។ បណ្ដឹងជំទាស់បានទៅលើដីកាសម្រេចដូចតទៅ៖

- ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ (លើកលែងពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារដែលតុលាការនៃបណ្ដឹងជំទាស់បានចេញ ) ឬ ដីកាសម្រេចអំពីពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរក្សាការពារ។
- ដីកាសម្រេចដែលទទួលស្គាល់ ផ្លាស់ប្ដូរ ឬលុបចោលដីកាសម្រេចរក្សាការពារ តាមរយៈពាក្យសុំតវ៉ា
- ដីកាសម្រេចលើកចោលពាក្យសុំទាមទារឱ្យលុបចោល
- ឬ ដីកាសម្រេចលុបចោល ទៅលើដីកាសម្រេចរក្សាការពារជាបណ្ដោះអាសន្នតាមរយៈពាក្យសុំទាមទារឱ្យលុបចោល។

អំឡុងពេលដែលអាចប្ដឹងជំទាស់បានគឺ ២សប្ដាហ៍ ហើយអំឡុងពេលនេះមិនអាចពន្យារបានឡើយ[52] មានភាពចាំបាច់នូវការទាញហេតុផលដោយផ្ទាល់មាត់ ឬ ការសួរដែលភាគី ទាំងសងខាងអាចចូលរួមបាន។[53] បន្ទាប់ពីតុលាការសម្រេចសេចក្ដីរួច តុលាការត្រូវបញ្ជូនដីកាសម្រេចនេះទៅភាគី។

[52] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦, មាត្រា ៥៦១

[53] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៦, មាត្រា ៥៥២, មាត្រា ៥៥៣ និង មាត្រា ៥៦១

# ជំពូកទី ៣

# សញ្ញាណនៃវិធានគតិយុត្តិ និងស្ថានភាពនៃការអនុវត្តលើការចាត់ចែងបណ្ដោះអាសន្នរបស់ប្រទេសជប៉ុន

នៅក្នុងជំពូកទី៣នេះជាចំណុចស្នូល និងជាចំណុចបញ្ហាដែលសារណានេះព្យាយាមលើកមកបកស្រាយ និងបង្ហាញ។ ការបកស្រាយនៅក្នុងជំពូកនេះ និងផ្ដោតសំខាន់លើស្ថានភាព និងវិធានគតិយុត្តិនៃការចាត់ចែងរក្សាការពាររបស់ប្រទេសជប៉ុន ជាពិសេសពិនិត្យទៅលើភាពខុសគ្នាលើការអនុវត្តរបស់ព្រះរាជាណាចក្រកម្ពុជា និងប្រទេសជប៉ុន។ ដូច្នេះ មុននឹងចូលទៅពិស្ដារនៅចំណុចទាំងនោះបាន យើងនឹងព្យាយាមលើកបង្ហាញខ្លះៗទៅលើ ១. សញ្ញាណនៃវិធានគតិយុត្តិនៃការចាត់ចែងរក្សាការពាររបស់ប្រទេសជប៉ុន ២. ស្ថានភាពទូទៅលើការអនុវត្តការចាត់ចែងរក្សាការពាររវាងកម្ពុជា និងជប៉ុន និង៣. ការសំយោគបញ្ហា និងដំណោះស្រាយ។

## ផ្នែកទី១៖ សញ្ញាណវិធានគតិយុត្តិនៃការចាត់ចែងរក្សាការពាររបស់ប្រទេសជប៉ុន

### ១. សញ្ញាណនៃការវិវត្តក្រមច្បាប់ស៊ីវិលរបស់ប្រទេសជប៉ុន

មុនការពិភាក្សាលើច្បាប់ដែលចែងទាក់ទងនឹងការចាត់ចែងរក្សាការពារ យើងក៏គួរដឹងពីអំពីប្រវត្តិខ្លះៗពីការវិវត្ត និងកំណែទម្រង់ប្រទេសរបស់ជប៉ុនខ្លះៗដែរ។ ដ្បិតថាសារណានេះពុំមានគោលបំណងពន្លាតវិសាលភាពនៃការស្រាវជ្រាវឱ្យឆ្ងាយពីការចាត់ចែងរក្សាការពារក៏ពិតមែន តែការសង្ខេបឱ្យបានយល់ពីស្ថានច្បាប់រដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីរបស់ជប៉ុនដែលជាមាតានៃក្រមសារធាតុ និងនីតិវិធីរបស់ប្រទេសកម្ពុជាយើងពិតជាមានសារៈសំខាន់ និងអាចជាព័ត៌មានសម្រាប់ការស្រាវជ្រាវទៅមុខបន្តបន្ទាប់ទៀត។

នៅប្រទេសជប៉ុន ក្រមនីតិវិធីរដ្ឋប្បវេណីត្រូវបានអនុម័តដោយលេចឡើងក្រោមរូបភាពជាច្បាប់សរសេរនៅឆ្នាំ១៨៩០ (សម័យមេជិឆ្នាំ២៣)។ ក្រមនេះត្រូវបានធ្វើសេចក្ដីព្រាងដំបូងក្រោមគម្រូនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ប្រទេសអាល្លឺម៉ង់នៅឆ្នាំ១៨៧៧ ដោយលោក Hermann Techow ជាជនជាតិអាល្លឺម៉ង់។ មិនបានប៉ុន្មានចលនានៃការវិសោធនកម្មក៏ចាប់មានឡើងជាបន្តបន្ទាប់។ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ១៨៩០នេះ ត្រូវបានធ្វើវិសោធនកម្មទាំងស្រុងពីគន្ថី១ ដល់គន្ថី៥នៅឆ្នាំ១៩២៦(សម័យថៃស្យូឆ្នាំ១៥) ហើយចាប់ផ្ដើមអនុវត្តនៅថ្ងៃទី១ ខែ តុលា ឆ្នាំ១៩២៩ ហើយបន្ទាប់ពីនោះមកក៏មានចំណុចខ្លះត្រូវបានលុបចោលតែម្ដង។ ក្រោយចប់សង្គ្រាមលោកលោកទី២ ជប៉ុនបានធ្វើវិសោធនកម្មខ្លះបន្ថែមទៀតដោយទទួលយកឥទ្ធិពលពីចក្រភពអង់គ្លេស។ ជាងនេះទៅទៀតនៅឆ្នាំ១៩៧៩(សម័យស្យូវ៉ាក់ឆ្នាំ៥៤) តាមរយៈការអនុម័ត**ច្បាប់ស្ដីពីការអនុវត្តដោយបង្ខំ** នាំឱ្យបញ្ញត្តិស្ដីពីការអនុវត្តដោយបង្ខំនៅក្នុងគន្ថី៦ចាស់នៃក្រមនីតិវិធីរដ្ឋប្បវេណី និងក្រោយមកនៅឆ្នាំ១៩៨៩ តាមរយៈ**ច្បាប់ស្ដីការចាត់ចែងរក្សាការពារ**ត្រូវបានអនុម័ត បញ្ញត្តិនៃការរឹបអូសបណ្ដោះអាសន្ន និងការចាត់ចែង

បណ្ដោះអាសន្ននៃគន្ថីទី៦ចាស់នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវបានលុបចោល[54]។

## ២. សញ្ញាណនៃវិធានគតិយុត្តិលើការចាត់ចែងរក្សាការពាររបស់ប្រទេសជប៉ុន

ដូចដែលបានបកស្រាយខ្លះពីខាងលើ សញ្ញាណនៃការចាត់ចែងរក្សាការពារគឺមាននៅក្នុងក្រមរដ្ឋប្បវេណីរបស់ជប៉ុនយ៉ាងប្រត្យក្ស។ ក៏ប៉ុន្តែក្រោយការប្បញ្ញត្តិនៃច្បាប់ស្ដីពីការចាត់ចែងរក្សាការពារ ដែលជាច្បាប់ពិសេសបានអនុម័ត និងចូលជាធរមាន ព្រមទាំងអនុវត្តនៅ២ឆ្នាំបន្ទាប់មក ប្បញ្ញត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីត្រូវបាននិរាករណ៍។

ច្បាប់ស្ដីពីការចាត់ចែងរក្សាការពារ មានរចនាសម្ព័ន្ធដូចខាងក្រោមនេះ។

ច្បាប់ស្ដីពីការចាត់ចែងរក្សាការពារត្រូវបានបែងចែងជា៥ជំពូក និងមានបញ្ញត្តិបន្ថែមមួយ។ ជំពូកទី១ស្ដីពីបទប្បញ្ញត្តិទូទៅ(មាត្រា១ ដល់ មាត្រា៨), ជំពូកទី២ ស្ដីពីនីតិវិធីស្ដីពីការចាត់ចែងរក្សាការពារ (មាត្រា៩ ដល់មាត្រា៤២),ជំពូកទី៣ នីតិវិធីទាក់ទងនឹងការអនុវត្តរក្សាការពារ (មាត្រា៤៣ ដល់ មាត្រា៥៧), ជំពូកទី៤ អានុភាពការចាត់ចែងបណ្ដោះអាសន្ន (មាត្រា៥៨ ដល់ មាត្រា៦៥), ជំពូកទី៥ ទោសបញ្ញតិ (មាត្រា៦៦ ដល់មាត្រា៦៨)។

ត្រង់នេះមិនថាមើលពីរចនាសម្ព័ន្ធទេ ពោលគឺអត្ថន័យនៃប្បញ្ញត្តិនៃការចាត់ចែងរក្សាការពារនៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាមានក្ខណៈស្ទើរតែដូចគ្នា ទៅនឹងច្បាប់ស្ដីពីការចាត់ចែងរក្សាការពាររបស់ប្រទេសជប៉ុន។ នៅលើវិធានផ្នែកគតិយុត្តិគ្មានបញ្ហាចោទចម្បងរវាងប្រទេសទាំងពីរនេះឡើយ។

បន្ទាប់ទៅនេះយើងនឹងទៅពិគ្រោះលើបញ្ហានៃការអនុវត្តរបស់ប្រទេសទាំងពីរ នៅផ្នែកទី២ជាផ្នែកបន្ទាប់។

# ផ្នែកទី២៖ ស្ថានភាពទូទៅនៃការអនុវត្តលើការចាត់ចែងរក្សាការពារ រវាងកម្ពុជា និងជប៉ុន

តាមរយៈរបាយការណ៍របស់លោក **ម៉ាអ៊ិជាក់** ជាអ្នកជំនាញច្បាប់បម្រើការងារនៅអង្គការ JICA (ចៃការ) បានឱ្យដឹងថា នៅឆ្នាំ២០១៦ តុលាការកម្ពុជាទទួលសំណុំរឿងលើការចាត់ចែងរក្សាការពារសរុបចំនួន ២១១៦ករណី។ តួលេខយ៉ាងសម្បើមនេះបើគិតជាមធ្យម តុលាការកម្ពុជាទទួលបានសំណុំរឿងប្រមាណជិត ៥ ទៅ ៦ ករណីក្នុងមួយថ្ងៃ។ ការណ៍បានស្ដែងឱ្យឃើញជារូបភាពនៃការអនុវត្តយ៉ាងសស្រាក់សស្រាំដូចគ្នា។

ដោយហេតុថានៅលើទម្រង់នៃវិធានគតិយុត្តិ របស់ប្រទេសកម្ពុជា និងប្រទេសជប៉ុនមានភាពដូចគ្នា ដូច្នេះយើងនឹងពិនិត្យទៅលើការអនុវត្តជាក់ស្ដែង ថាតើមានលក្ខណៈដូចគ្នា ឬយ៉ាងណាទៅលើស្ថានភាពជាក់

[54] 内田武吉・加藤哲夫(UCHIDA TAKEKICHI KATTO TETSUO)「ក្រមនីតិវិធីរដ្ឋប្បវេណី」គេហទំព័រ コトバンク（KOTOBANK）,ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥។ (ទស្សនាចុងក្រោយ ថ្ងៃទី២ ខែសីហា ឆ្នាំ២០២១) https://kotobank.jp/word/民事訴訟法-140038

ស្តែងដែលប្រើប្រាស់ច្បាប់ដែលមានអត្ថន័យ និងសារធាតុដូចគ្នាដូច្នេះ។

ជាការណ៍ដែលត្រូវបានលើកឡើងជារឿយៗគឺទៅលើ៣ចំនុចសំខាន់ៗ៖

១. ការសម្រេចឱ្យដាក់ប្រាតិភោគ ឬមិនឱ្យដាក់ប្រាតិភោគលើការចាត់ចែងរក្សាការពារ

២. ពាក្យដាក់សុំឱ្យអនុវត្តការចាត់ចែងរក្សាការពារ

៣. អនុភាពការចាត់ចែងរក្សាការពារចំពោះអចលនវត្ថុ

**១.ការសម្រេចឱ្យដាក់ ឬមិនដាក់ប្រាតិភោគ**

មាត្រា៥៤២នៃក្រមនីតិវិធីរដ្ឋប្បវេណីបានចែងអំពី ប្រាតិភោគសម្រាប់ដីការក្សាការពារ ថា “ដីការក្សាការពារ អាចធ្វើដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគ”។ មាត្រានេះដូចគ្នាទៅនឹង មាត្រា១៤នៃច្បាប់ស្តីការចាត់ចែងរក្សាការពារជប៉ុន ដែលចែងថា “ដីកាសម្រេចរក្សាការពារ អាចសម្រេចដោយឱ្យដាក់ប្រាតិភោគ ឬក្រោមលក្ខខណ្ឌនៃភាពសមហេតុផលក្នុងអំឡុងពេលជាក់លាក់ណាមួយដាក់ឱ្យមានប្រាតិភោគ ឬមិនឱ្យប្រាតិភោគ[55]”។ ជាទស្សនទានច្បាប់ត្រង់ចំណុចនេះ ជាគោលការណ៍គឺមិនមានភាពខុសទេ ដ្បិតថាការប្រើប្រាស់ពាក្យពេចន៍ក្នុងមាត្រាមានដូចគ្នាទាំងស្រុងក្តី។

ក្នុងករណីប្រទេសជប៉ុន ករណីចៅក្រមចេញដីកាសម្រេចចាត់ចែងការរក្សាការពារដោយមិនបង្គាប់ឱ្យដាក់ប្រាតិភោគ គឺមានតិចតួចណាស់។

ឧទាហរណ៍ នៅក្នុងករណីការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន ដែលបង្គាប់ឱ្យកូនបំណុលបង់ប្រាក់ខែបណ្តោះអាសន្នដល់អតីតបុគ្គលិក(ម្ចាស់បំណុល) ដែលជាអ្នកប្តឹងសុំបញ្ជាក់នូវឋានៈជាបុគ្គលិក ចៅក្រមអាចចេញដីកាសម្រេចរក្សាការពារដោយមិនចាំបាច់បង្គាប់ឱ្យដាក់ប្រាតិភោគបាន។

ឧទាហរណ៍មួយទៀត នៅក្នុងករណីការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន ដែលបង្គាប់ ឱ្យកូនបំណុលបង់សំណងបណ្តោះអាសន្នដល់ជនរងគ្រោះ (ម្ចាស់បំណុល) ដែលប្តឹងទាមទារសំណងខូចខាតដោយ សារគ្រោះថ្នាក់ចរាចរណ៍ ចៅក្រមអាចចេញដីកាសម្រេចចាត់ចែងរក្សាការពារដោយមិនចាំបាច់បង្គាប់ឱ្យដាក់ ប្រាតិភោគបាន។ ពីព្រោះ ក្នុងឧទាហរណ៍ខាងលើ មូលហេតុនៃការចេញដីកា ឬភាពចាំបាច់នៃដីកា គឺថាម្ចាស់បំណុលមិនអាចរស់នៅ បានទេប្រសិនបើគ្មានប្រាក់ខែ ឬសំណងជាបណ្តោះ

---

55 សម្រង់មាត្រាជាសំណេរដើម និងជាភាសាអង់គ្លេសនៃច្បាប់ស្តីការចាត់ចែងរក្សាការពារជប៉ុន៖

第十四条　保全命令は、担保を立てさせて、若しくは相当と認める一定の期間内に担保を立てることを保全執行の実施の条件として、又は担保を立てさせないで発することができる。

Article 14 (1) An order for a provisional remedy may be issued while requiring provision of security or requiring provision of security within a certain period of time that is found to be reasonable as a condition for implementing the execution of the provisional remedy, or not requiring the provision of security.

http://www.japaneselawtranslation.go.jp/law/detail/?id=2028&vm=&re=

អាសន្ននោះ ហើយការចេញដីកានេះគឺចាំបាច់ណាស់ដើម្បីចៀសវាងនូវការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល។ ក្នុងករណីទាំងនេះ ការបង្គាប់ម្ចាស់បំណុលឱ្យដាក់ប្រាតិភោគ គឺមិនត្រូវនឹងហេតុផលខាងលើទេ ដែលគាំទ្រនូវភាពចាំបាច់នៃដីកាសម្រេចចាត់ចែងរក្សាការពារ។ ដូច្នេះហើយ នៅប្រទេសជប៉ុន តុលាការតែង ចេញនូវដីកាសម្រេចចាត់ចែងរក្សាការពារដោយមិនចាំបាច់បង្គាប់ឱ្យដាក់ប្រាតិភោគនោះទេក្នុងករណីទាំងអស់នេះ។ ប៉ុន្តែ ស្ទើរគ្រប់ករណីទាំងអស់ តុលាការចេញដីកាសម្រេចចាត់ចែងរក្សាការពារដោយបង្គាប់ឱ្យមានការដាក់ប្រាតិភោគ។

ផ្ទុយទៅវិញនៅប្រទេសកម្ពុជាលើការអនុវត្តជាក់ស្តែង ការសម្រេចឱ្យដាក់ប្រាតិភោគដោយដីកាសម្រេចរក្សាការពារ គឺស្ទើរតែគ្មាន[56]។ ហេតុផលទាំងនោះមានដូចជា៖

ក. ក្នុងករណីការរឹបអូសបណ្តោះអាសន្នជាអាទិ៍ ការបំពារបំពានសិទ្ធិរបស់កូនបំណុលគឺមានលក្ខណៈស្រាល ដោយមិនចាំបាច់ដល់ថ្នាក់ធ្វើការសម្រេចឱ្យដាក់ប្រាតិភោគនោះទេ។ ម្យ៉ាងទៀតមានចៅក្រមមិនតិចទេយល់ថា ការសម្រេចដាក់ប្រាតិភោគនេះ ធ្វើឱ្យភាគី ឬប្រជាពលរដ្ឋមានអារម្មណ៍មិនល្អមកលើស្ថាប័នតុលាការ។

ខ. ទាក់ទងនឹងមាត្រា៥៣៦(ការផ្តល់នូវប្រាតិភោគ)វិញ ការសម្រេចឱ្យដាក់ប្រាតិភោគគឺចាំបាច់គួរតែមាននីតិវិធី និងស្ថាប័នដែលគ្រប់គ្រងប្រាក់ទាំងនោះ។ ក៏ប៉ុន្តែមិនមានមាត្រា និងការកំណត់ណាមួយអំពីនីតិវិធីស្ថាប័ន និងការគ្រប់គ្រងប្រាក់នោះឡើយ។ ទាំងនេះគឺវាជះឥទ្ធិពលដល់ការអនុវត្តជាក់ស្តែង។

**សំយោគ**

| | កម្ពុជា | ជប៉ុន |
|---|---|---|
| ការសម្រេចដាក់ប្រាតិភោគ | × | ✓ |
| ការមិនសម្រេចឱ្យដាក់ប្រាតិភោគ | ✓ | × |

## ២. ពាក្យសុំឱ្យអនុវត្តការចាត់ចែងរក្សាការពារ

នៅប្រទេសជប៉ុន ការសុំឱ្យចេញដីកាសម្រេចរក្សាការពារអាចត្រូវបានធ្វើឡើងតាមរយៈពាក្យសុំជាលាយល័ក្ខណ៍អក្សរ(ប្បញ្ញត្តិស្តីពីការចាត់ចែងរក្សាការពារមាត្រា១ ចំណុច៦)[57]។ តែទាក់ទងនឹងការអនុវត្តរក្សា

[56] 前田優太(MAEDAYUTA)「カンボジアにおける民事保全の実状(ស្ថានភាពជាក់ស្តែងនៃការចាត់ចែងបណ្តោះអាសន្នក្នុងប្រទេសកម្ពុជា)」បោះពុម្ពដោយICD NEWSលេខ៧៨ ចុះខែ៣ ឆ្នាំ២០១៩, ទំព័រទី១៨។ (ទស្សនាចុងក្រោយថ្ងៃទី៥ ខែសីហា ឆ្នាំ២០២១)
http://www.moj.go.jp/content/001311758.pdf

[57] សម្រង់មាត្រាជាសំណេរដើម នៃប្បញ្ញត្តិស្តីការចាត់ចែងរក្សាការពារជប៉ុន៖
第一条　次に掲げる申立ては、書面でしなければならない。… 六．保全執行の申立て។
https://www.courts.go.jp/toukei_siryou/kisokusyu/minzi_kisoku/minzi_kisoku_58/index.html

ការពារនៅក្នុងដំណោះស្រាយជាក់លាក់ណាមួយ គឺស្របពេលជាមួយនឹងការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ក៏អាចធ្វើការស្នើសុំអនុវត្តរក្សាការពារបានដែរ(ប្បញ្ញត្តិស្តីពីការចាត់ចែងរក្សាការពារមាត្រា៣១)។ ហើយនៅលើការអនុវត្តជាក់ស្តែងវិញ ភាគច្រើននៃស្ថាប័នអនុវត្ត គឺជាតុលាការដែលចេញសេចក្តីសម្រេចលើពាក្យស្នើសុំរក្សាការពារនោះតែម្តង ដូច្នេះហើយជាគោលការណ៍គឺរាំរំសាយដល់ការដាក់ពាក្យសុំអនុវត្តរក្សាការពាររួចស្រេច ពោលគឺមិនចាំបាច់ធ្វើការដាក់ពាក្យសុំអនុវត្តរក្សាការពារជាថ្មីនោះទេ[58]។

ដោយឡែកនៅក្នុងប្រទេសកម្ពុជា ដូចគ្នានឹងប្រទេសជប៉ុនដែរត្រង់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ គឺការសុំឱ្យចេញដីកាសម្រេចរក្សាការពារអាចត្រូវបានធ្វើឡើងតាមរយៈពាក្យសុំជាលាយល័ក្ខណ៍អក្សរ (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា ៥៣៤ ចំណុច ច)។ ក៏ប៉ុន្តែមិនមានមាត្រាចែងអំពីការដែល អាចស្នើសុំអនុវត្តរក្សាការពារស្របពេលជាមួយនឹងការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារនោះទេ។

ដូច្នេះសួរថាតើប្រទេសកម្ពុជា អាចស្នើសុំអនុវត្តរក្សាការពារស្របពេលជាមួយនឹងការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារបានដែរឬទេ? ចំណុចនេះយើងនឹងទៅសិក្សាលើទ្រឹស្តីចំនួន២៖ ទីមួយទ្រឹស្តីអវិជ្ជមាន និងទីពីរទ្រឹស្តីវិជ្ជមាន។

**ទ្រឹស្តីអវិជ្ជមាន៖**

ចំពោះមាត្រា ៥៣២(២) មាត្រា ៥៣៤(ច) និង មាត្រា៣៤៩(២) អនុវត្តដូចគ្នា តាមមាត្រា ៥៦៤ "ពាក្យសុំឱ្យអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ" គួរតែត្រូវបានដាក់ដាច់ដោយឡែកពី “ពាក្យសុំដីកាសម្រេច រឹបអូសជាបណ្តោះអាសន្នចំពោះអចលវត្ថុ”។

១. គេត្រូវអនុវត្តនូវនីតិវិធីដ៏វែងខាងក្រោម ដែលវាផ្ទុយនឹងភាពចាំបាច់នៃនីតិវិធីចាត់ចែងរក្សាការពារដែលត្រូវធ្វើអោយបានលឿន។ ពោលគឺការ "ការបញ្ជូនដីកាសម្រេច", "ពាក្យសុំឱ្យអនុវត្ត", "ការរៀបចំចុះបញ្ជីការរឹបអូសជាបណ្តោះអាសន្ន" និង"ការចុះបញ្ជីការរឹបអូសជាបណ្តោះអាសន្ន។ គេអាចជូនដំណឹងដល់ម្ចាស់បំណុលអំពីដីកាសម្រេចតាមរយៈទូរសព្ទ័នៅពេលបញ្ជូនដីកានោះ។

២. ករណីដីកាសម្រេចអំពីការរឹបអូសជាបណ្តោះអាសន្ន បានបញ្ជូនទៅឱ្យម្ចាស់បំណុល និង កូនបំណុល ក្នុងពេលប្រហាក់ប្រហែលគ្នា (មាត្រា ៥៤៣) គេខ្លាចថាកូនបំណុលធ្វើការចុះបញ្ជីការផ្ទេរកម្មសិទ្ធិ មុនពេលនីតិវិធីចប់សព្វគ្រប់ "ពាក្យសុំឱ្យអនុវត្ត", "ការរៀបចំចុះបញ្ជីការរឹបអូសជាបណ្តោះអាសន្ន", "ការចុះបញ្ជីការរឹបអូសជា បណ្តោះអាសន្ន”។

ដើម្បីកុំឱ្យមានស្ថានភាពនេះកើតឡើង គេអាចបញ្ជូនដីកាទៅម្ចាស់បំណុលមុនគេ ហើយពន្យា ពេលការបញ្ជូនទៅកូនបំណុលជាបណ្តោះអាសន្ន រហូតដល់ពេលការចុះបញ្ជីអំពីការរឹបអូសជា បណ្តោះអាសន្ន បាន

[58] MAEDAYUTA ស្ថានភាពជាក់ស្តែងនៃការចាត់ចែងបណ្តោះអាសន្នក្នុងប្រទេសកម្ពុជា, ទំព័រទី១៨។

ធ្វើរួចរាល់ហើយ។

ជារួម ទ្រឹស្ដីអវិជ្ជមាននេះមិនគាំទ្រឱ្យមានធ្វើការដាក់ពាក្យសុំឱ្យអនុវត្តចាត់ចែងរក្សាការពារស្របពេលដែលធ្វើការដាក់ពាក្យសុំដីកាសម្រេចចាត់ចែងរក្សាការពារនោះទេ។

**ទ្រឹស្ដីវិជ្ជមានះ**

ចំពោះ ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ គេក៏អាចដាក់ពាក្យសុំឱ្យអនុវត្តដីកាសម្រេចនេះផងដែរ ដើម្បីត្រៀមលក្ខណៈចំពោះករណីពាក្យសុំមុនត្រូវគេផ្ដល់ការយល់ព្រមនៅពេលអនាគត។

១. ទ្រឹស្ដីនេះប្រឆាំងនឹងប្បញ្ញត្តិនៃមាត្រា ៥៦៤ និងមាត្រា ៣៤៩(២) ដែលចែង ថាពាក្យសុំឱ្យអនុវត្តត្រូវភ្ជាប់ជាមួយនឹងលិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត។

ករណីគេអាចបំពេញនូវលក្ខខណ្ឌទាំងអស់ខាងក្រោមនេះ គេអាចបកស្រាយថា តាមការពិចារណាភាពចាំបាច់ក្នុងការអនុវត្តនីតិវិធី ពាក្យសុំឱ្យអនុវត្តអាចធ្វើតាមរយៈពាក្យសុំដីកាសម្រេចរឹបអូសបណ្ដោះអាសន្ន។

ក. មានតម្រូវការខ្ពស់ជាពិសេសការអនុវត្តឱ្យបានលឿន និងការអនុវត្តដោយសំងាត់។

ខ. ស្ថាបន័ទទួលបន្ទុកចេញដីកាសម្រេចចាត់ចែងរក្សាការពារ ក៏ជាស្ថាប័នទទួលបន្ទុកអនុវត្តដីកានោះផងដែរ។

គ. ខ្លឹមសារនៃការអនុវត្តការចាត់ចែងរក្សាការពារ គឺត្រូវច្បាស់លាស់។

២. ប្បញ្ញត្តិច្បាប់ចែងមិនច្បាស់ថា ប្រភេទចាត់ចែងរក្សាការពារណាដែលគេអនុវត្តនូវទ្រឹស្ដីនេះ។ ត្រង់នេះគេអាចបកស្រាយថា ទ្រឹស្ដីនេះអនុវត្តចំពោះករណីទាំងឡាយណាដែលបំពេញតាមតម្រូវការ ទាំងអស់ពីចំណុច(១) ដល់(៣) នៃចំណុច ១ខាងលើ ឬនិយាយម្យ៉ាងវិញទៀត "ការអនុវត្តការចាត់ចែងរក្សាការពារតាមវិធីចុះបញ្ជី ឬវិធីបញ្ជូនដីកាសម្រេចអំពីការចាត់ចែងរក្សាការពារទៅកាន់ កូនបំណុលទី៣ ឬតតិយជនដែលដូចភាគី"។ ឧទាហរណ៍ ទ្រឹស្ដីនេះគេអនុវត្តក្នុងករណីការ ចាត់ចែងជាបណ្ដោះអាសន្នហាមឃាត់ការចាត់ចែងអចលនវត្ថុ ករណីរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុលជាអាទិ៍ ព្រមទាំងការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ។

**សំយោគ**

នៅពេលចាប់ផ្ដើម ជាការប្រសើរត្រូវជ្រើសរើសទ្រឹស្ដីទី១ខាងលើ ដែលស្របតាមប្បញ្ញត្តិច្បាប់។ ទោះបីជាយ៉ាងណាក៏ដោយ បើពិចារណាអំពីភាពចាំបាច់ជាក់ស្ដែង ការបកស្រាយ និងទ្រឹស្ដីទី២ខាងលើ អាចមានលទ្ធភាពច្រើន។ នៅប្រទេសជប៉ុន ប្បញ្ញត្តិច្បាប់អាចបកស្រាយដូចចំណុចទី ២ ខាងលើបាន។ ក្នុងករណីនេះ គេត្រូវចាប់អារម្មណ៍ចំពោះសេចក្ដីណែនាំនៅពេលទទួលពាក្យសុំដីកាសម្រេចចាត់ចែងរក្សាការពារ គឺថាក្នុង

ករណីមានពាក្យសុំដែលបំពេញតាមលក្ខខណ្ឌពីចំណុច(១) ដល់(៣) នៃចំណុចទី២ខាងលើ គេគួរណែនាំឱ្យដាក់ពាក្យសុំ អនុវត្តដីកាសម្រេចនោះផងដែរ ហើយវាមានប្រយោជន៍ក្នុងការរៀបចំគំរូពាក្យសុំជាមុនសំរាប់អ្នកដាក់ពាក្យសុំ។

ថ្វីដ្បិតតែការបកស្រាយផ្នែកទ្រឹស្តីមានការអនុគ្រោះលើការបកស្រាយក្តី ក៏ប៉ុន្តែលើការអនុវត្តក្នុងប្រទេសកម្ពុជា គឺមិនត្រូវបានអនុញ្ញាតឱ្យប្រើទៅតាមទ្រឹស្តីទី២នេះទេ។ ចំណុចតាមច្បាប់ប្រទេសកម្ពុជាមិនមានបញ្ជាក់ក៏ពិតមែន ក៏យើងគួរតែអនុវត្តទៅតាមកាលៈទេសៈដែលមិនមែនជាការអនុវត្តដោយមិនមានភាពបត់បែននោះទេ។ ហើយនេះជាចំណុចមួយដែលនីតិករត្រូវតាមដាន និងយកចិត្តទុកដាក់បន្ថែម។

### ៣. អនុភាពការចាត់ចែងរក្សាការពារចំពោះអចលនវត្ថុ

មាត្រា៥៨ កថាខណ្ឌ១[59]នៃច្បាប់ស្តីពីការចាត់ចែងរក្សាការពារជប៉ុនបានចែងអំពីអនុភាពមិនដាច់ខាតទៅលើការរឹបអូសបណ្តោះអាសន្ន និងការចាត់ចែងបណ្តោះអាសន្នដែលហាមឃាត់ឱ្យមានការចាត់ចែងចំពោះអចលនវត្ថុ ដែលបានធ្វើការចុះបញ្ជីទៅតតិយជនផ្សេងទៀតក៏ដោយ។ មានន័យថាអចលនវត្ថុដែលជាកម្មវត្ថុនៃការធ្វើការរឹបអូសបណ្តោះអាសន្ន និងការចាត់ចែងបណ្តោះអាសន្នដែលហាមឃាត់ឱ្យមានការចាត់ចែង បើទោះបីជាកូនបំណុលនៃការចាត់ចែងរក្សាការពារបានផ្ទេរកម្មសិទ្ធិតាមការចុះបញ្ជីទៅតតិយជនហើយក៏ដោយ ក៏មិនអាចតតាំងជាមួយម្ចាស់បំណុលនៃការរឹបអូសបណ្តោះអាសន្ន ឬម្ចាស់បំណុលនៃការអនុវត្តនោះបានដែរ។

សម្រាប់ប្រទេសកម្ពុជា គោលគំនិតភាពមិនដាច់ខាតនេះគឺដូចគ្នាទៅនឹងប្រទេសជប៉ុន។ តែអ្វីដែលខុសគ្នានឹងប្រទេសជប៉ុននោះគឺ យើងអាចរកឃើញនៅក្នុងមាត្រា៤៣១ ចំណុច៣នៃក្រមនីតិរដ្ឋប្បវេណីកម្ពុជាដែលប្បញ្ញត្តិទាក់ទងការរឹបអូសបណ្តោះអាសន្ន។ ត្រង់នេះដូចគ្នានឹងករណីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ និង ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែរ នៅក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ អានុភាពចម្បងនៃការរឹបអូសគឺការហាមឃាត់មិនឱ្យធ្វើការចាត់ចែង។ នៅខណៈពេលដែលការរឹបអូសបង្កើតអានុភាពដោយការបញ្ជូនដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ទៅឱ្យកូនបំណុលនៃការអនុវត្តដោយការចុះបញ្ជីអំពីការរឹបអូសនោះកូនបំណុលនឹងបាត់បង់សិទ្ធិចាត់ចែងនូវអចលនវត្ថុដែលជាកម្មវត្ថុ ហើយអាជ្ញាធររដ្ឋ ទទួលបាន

[59] សម្រង់មាត្រាជាសំណេរដើម និងជាភាសាអង់គ្លេសនៃច្បាប់ស្តីការចាត់ចែងរក្សាការពារជប៉ុន៖

第五十八条　第五十三条第一項の処分禁止の登記の後にされた登記に係る権利の取得又は処分の制限は、同項の仮処分の債権者が保全すべき登記請求権に係る登記をする場合には、その登記に係る権利の取得又は消滅と抵触する限度において、その債権者に対抗することができない。

Article 58 (1) If the obligee under a provisional disposition set forth in Article 53, paragraph (1) registers a right to claim a registration that must be preserved, the acquisition of a right or a restriction on disposal which is registered after the registration of a prohibition on disposal as referred to in said paragraph may not be duly asserted against such obligee to the extent that it is in conflict with the acquisition or extinction of the registered right.

http://www.japaneselawtranslation.go.jp/law/detail/?id=2028&vm=&re=

នូវសិទ្ធិចាត់ចែងនោះវិញ។

ប្រសិនបើកូនបំណុលនៃការអនុវត្ត ផ្ទេរអនុប្បទាននូវអចលនវត្ថុដែលជាកម្មវត្ថុ ទៅឱ្យតតិយជន នៅក្រោយពេលដែលការរឹបអូសបង្កើតអានុភាពអនុប្បទាននោះត្រូវទុកជាមោឃៈ។ ក៏ប៉ុន្តែ មោឃភាពនេះ គ្រាន់តែមានន័យថាអនុប្បទាននោះមិនអាចយកទៅតតាំងបានជាមួយនឹងម្ចាស់បំណុលដែលបានធ្វើការរឹបអូសតែប៉ុណ្ណោះ ពោលគឺវាជាមោឃភាពមិនដាច់ខាត។ ហេតុនេះហើយ ក្នុងករណីដែលកូនបំណុលនៃការអនុវត្ត ផ្ទេរអនុប្បទាននូវអចលនវត្ថុដែលជាកម្មវត្ថុ ទៅឱ្យតតិយជន នៅក្រោយពេលចុះបញ្ជីអំពីការរឹបអូស នោះគេអាចនឹងចុះបញ្ជីអំពីលទ្ធកម្មនៃកម្មសិទ្ធិដោយតតិយជនដែលជាអនុប្បទានិកនោះបាន។ អនុប្បទានិកមិនអាចដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជនដោយអះអាងចំពោះម្ចាស់បំណុលនៃការអនុវត្តថាអចលនវត្ថុដែលជាកម្មវត្ថុនោះគឺជាកម្មសិទ្ធិរបស់ខ្លួនទេ។

ការណ៍ដែលមិនមានបទប្បញ្ញត្តិណាមួយនៅក្នុងច្បាប់ដែលចែងទាក់ទងនឹង ការហាមឃាត់នៃការចាត់ចែងបណ្តោះអាសន្ននេះ ដោយសារប្រទេសកម្ពុជាបានរៀបចំធ្វើឱ្យប្រព័ន្ធចុះបញ្ជីឱ្យបានល្អនៅឡើយក្នុងដំណាក់កាលតាក់តែងច្បាប់នេះ។

## ផ្នែកទី៣៖ សំយោគបញ្ហា និងដំណោះស្រាយ

ក្រៅពីបញ្ហាដែលបានលើកឡើងទាក់ទងលើភាពងាយភ័ន្តច្រឡំ ព្រមទាំងភាពមិនដាច់ស្រេចនៃប្បញ្ញត្តិច្បាប់ដូចរៀបរាប់ខាងលើ ក៏កើតមានបញ្ហាដែលកើតចេញពីការអនុវត្តរបស់ចៅក្រមផងដែរ។ ក្នុងផ្នែកទី៣[60]នេះ យើងខ្ញុំនឹងបង្ហាញបន្ថែមលើបញ្ហានៃអ្នកអនុវត្តច្បាប់ ដែលកើតចេញពីការមិនទាន់យល់ដឹងច្បាស់អំពីច្បាប់។

ទីមួយ ការភាន់ច្រឡំលើការរឹបអូសបណ្តោះអាសន្ន និងការចាត់ចែងបណ្តោះអាសន្នតែបន្តកើតមាន។ គួយ៉ាងមានមិនតិចទេនៅក្នុងប្រទេសកម្ពុជា ក្នុងករណីសុំឱ្យតុលាការធ្វើការចាត់ចែងបណ្តោះអាសន្នដែលហាមឃាត់មិនឱ្យមានការចាត់ចែងក្នុងករណីរក្សាការពារសិទ្ធិលើបំណុលដែលគិតជាប្រាក់ ហើយតុលាការនោះទៀតសោតក៏អនុញ្ញាតលើការស្នើសុំនោះ។ ត្រង់នេះហើយដែលការចេញការដីកាទៅតាមអ្វីដែលភាគីស្នើសុំដោយមិនបានពិចារណាទៅលើមូលដ្ឋានច្បាប់ សរបង្ហាញថាមន្ត្រីអនុវត្តច្បាប់មិនទាន់យល់ដឹងជាក់ពីច្បាប់ឱ្យបានស៊ីជម្រៅ។

ទីពីរ ដីកាសម្រេចរក្សាការពារនឹងមិនអាចត្រូវបានធ្វើឡើយ លុះត្រាតែមានការបង្ហាញពីសិទ្ធិដែលគួរការពារ។ ទោះយ៉ាងណាក្តី នៅក្នុងប្រទេសកម្ពុជា មានដីកាសម្រេចរក្សាការពារជាច្រើនដែលមិនបានកំណត់ឱ្យបានច្បាស់លាស់ថា សិទ្ធិដែលគួរការពារជាអ្វី និងថាតើសិទ្ធិនោះត្រូវបានបញ្ជាក់ឬទេ។ ឧទាហរណ៍ ក្នុងករណីដូចជា

[60] MAEDAYUTA ស្ថានភាពជាក់ស្តែងនៃការចាត់ចែងបណ្តោះអាសន្នក្នុងប្រទេសកម្ពុជា, ទំព័រទី២០ ដល់២១។

ការចាត់ចែងបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែងចំពោះភាគីទីបីដែលជាអ្នកទទួលវត្ថុ, ការចាត់ចែងបណ្ដោះអាសន្នដែលហាមឃាត់មិនឱ្យចាកចេញពីប្រទេសរបស់កូនបំណុល, ការចាត់ចែងបណ្ដោះអាសន្នបញ្ជាឱ្យកូនបំណុល និងម្ចាស់បំណុលរស់នៅផ្សេងគ្នា, ការចាត់ចែងបណ្ដោះអាសន្នបង្គាប់ឱ្យមន្ត្រីចុះបញ្ជីផ្ទេរកម្មសិទ្ធិ ទោះបីជាគ្មានការបង្ហាញពីឆន្ទៈរបស់បុគ្គលដែលមានកាតព្វកិច្ចចុះឈ្មោះក៏ដោយ, ការចាត់ចែងបណ្ដោះអាសន្នដោយអនុញ្ញាតឱ្យសាងសង់ចំពោះរដ្ឋាភិបាលជាអាទិ៍។ ប្រការនេះត្រូវបានគេយល់ឃើញថាតុលាការកម្ពុជាមិនទាន់យល់ច្បាស់ពីសារសំខាន់នៃ អត្ថិភាព និងនត្ថិភាពនៃសិទ្ធិដែលគួរនឹងត្រូវបានការពារ ព្រមទាំងការបញ្ជាក់ទៅលើសិទ្ធិទាំងនោះឱ្យបានច្បាស់លាស់។

ទីបី មិនអាចចេញដីកាស្ដីពីការចាត់ចែងរក្សាការពារនោះទេ ប្រសិនបើគ្មានភាពចាំបាច់ទៅលើការការពារ (មាត្រា៥៤៥ និងមាត្រា៥៤៨)។ ក៏ប៉ុន្តែត្រូវបានគេមើលឃើញថាដីកាស្ដីពីការរក្សាការពារមិនត្រូវបានត្រួតពិនិត្យបានហ្មត់ចត់ទៅលើភាពចាំបាច់ដែលត្រូវតែធ្វើការរក្សាការពារនោះទេ។ ឧទាហរណ៍ ការចាត់ចែងបណ្ដោះអាសន្នដោយហាមឃាត់មិនឱ្យនីតិបុគ្គលធ្វើអាជីវកម្ម, ការរឹបអូសបណ្ដោះអាសន្នលើទ្រព្យសម្បត្តិទាំងអស់របស់នីតិបុគ្គលជាដើម។

បញ្ហាទាំង៣ខាងលើនេះ ត្រឹមជាការបង្ហាញឱ្យឃើញពីបញ្ហានានាទាក់ទងនឹងមន្ត្រីអនុវត្តច្បាប់ ជាពិសេសចៅក្រមដែលមិនទាន់យល់ច្បាស់ពីអត្ថន័យផ្លូវច្បាប់ទាក់ទងនឹងការចាត់ចែងរក្សាការពារនេះ។ មានកត្តាជាច្រើនដែលអាចឱ្យពិចារណាបានទៅលើបញ្ហាទាំងអស់នេះបានដូចជា៖

- ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាយើង ហាក់បីដូចជាមេរៀនថ្មីមួយនៅឡើយដែលតម្រូវឱ្យអ្នកច្បាប់បន្តសិក្សាស្វែងយល់បន្ថែមទៀត
- វិសមភាពរវាងអ្នកទ្រឹស្ដីច្បាប់ និងអ្នកអនុវត្តច្បាប់
- ការអនុវត្តច្បាប់ទៅតាមទម្លាប់ ជាអាទិ៍។

# សន្និដ្ឋាន និងអនុសាសន៍

ឆ្លងតាមការពន្យល់បកស្រាយ ព្រមទាំងលើកពីទ្រឹស្ដីនានាទាក់ទងនឹងការចាត់ចែងរក្សាការពារ បង្ហាញឱ្យឃើញពីភាពចាំបាច់យ៉ាងសកម្មនៃនីតិវិធីស៊ីវិលមួយនេះ ដើម្បីរក្សានៅចរន្តស្ថិរភាពនៃហានិភ័យលើនីតិវិធីនៃការអនុវត្តដោយបង្ខំ។ ដ្បិតតែការចាត់ចែងរក្សាការពារត្រូវបានចាត់ប្រភេទជា២ធំៗក្ដី, ការរឹបអូសបណ្ដោះអាសន្ន និងការចាត់ចែងបណ្ដោះអាសន្ន, ក៏ភាពស្មុគ្រនៃនីតិវិធីនេះបង្កឱ្យមានភាពយល់ច្រឡំ និងការអនុវត្តមិនបានត្រឹមត្រូវនៅក្នុងការអនុវត្តផងដែរ។ ប្រការនេះជារឿងដែលយើងជាអ្នកសិក្សាច្បាប់ ជាពិសេសទាំងអនុវត្តច្បាប់ ព្រមទាំងនីតិករត្រូវយកចិត្តទុកដាក់លើកង្វះខាតទាំងនេះ។ ច្បាស់ណាស់ គ្មានច្បាប់ណាមួយក្នុងសកលលោកល្អឥតខ្ចោះនោះទេ ដូច្នេះការវិសោធនកម្មទៅលើចំណុចខ្វះខាត ដែលចំណុចខ្វះខាតនេះជាចំណុចដែលចាំបាច់ត្រូវតែបំពេញ ជារឿងចាំបាច់។ ផ្ទុយមកវិញបើទោះជាមានច្បាប់ដែលល្អយ៉ាងណាក្ដី តែប្រសិនបើយើងយកទៅប្រើប្រាស់ដោយមិនត្រឹមត្រូវ ក៏ជារឿងដែលត្រូវកែលម្អ។

ការចាត់ចែងរក្សាការពារជានីតិវិធីដ៏ស្មុគ្រស្មាញ ក៏ព្រោះថាទាំងការអនុវត្តដោយការចេញដីកាសម្រេចរក្សាការពារនោះត្រូវធ្វើដោយសារការមើលឃើញពីហានិភ័យនាពេលអនាគត។ ហើយទោះបីជាមាននីតិវិធីដែលបង្ការមុនការអនុវត្តដោយបង្ខំកើតមានក៏ដោយក៏មិនប្រាកដថា អាចធានាដល់ការទារសិទ្ធិ និងផលប្រយោជន៍ដល់ម្ចាស់បំណុលបានដែរ តែនេះក៏ស្ដែងចេញពីការខិតខំយ៉ាងពេញទំហឹងរបស់ច្បាប់លើការធានាផលប្រយោជន៍របស់បុគ្គលគ្រប់ៗរូប។

ជាអនុសាសន៍ដើម្បីឱ្យមានប្រសិទ្ធិភាពលើការបញ្ហានៃការលើកឡើងខាងលើ៖

**លើកកម្ពស់ការសិក្សាឥតឈប់ឈរ៖** បញ្ហានៃការមិនយល់ច្បាស់ គឺដោយសារតែមិនទាន់សិក្សាឱ្យបានហ្មត់ចត់ និងស៊ីជម្រៅ។ ដ្បិតកម្ពុជាទទួលគម្រូច្បាប់ពីជប៉ុនក្ដី មិនមែនមានន័យថាអ្វីត្រូវតែធ្វើឱ្យស្របតាមបរិបទជនប្រទេសជប៉ុននោះទេ។ ក៏ប៉ុន្តែ ការសិក្សាពីប្រទេសដែលបានឆ្លងកាត់ពិសោធន៍មុននេះជារឿងសំខាន់ណាស់ដើម្បីឱ្យយើងអាចស្វែងរកផ្លូវមួយដែលសាកសមនឹងយើង។ ច្បាប់ជាវិធានដើម្បីគ្រប់គ្រងសង្គម ដូច្នេះចៀសមិនផុតពីការទទួលរងនូវឥទ្ធិពលទំនៀមទំលាប់ វប្បធម៌នៃសង្គមនោះនោះទេ។ ការសិក្សានេះត្រូវតែធ្វើនៅគ្រប់ថ្នាក់ ជាពិសេសអ្នកអនុវត្តផ្ទាល់ឱ្យយល់ថាអត្ថន័យនៃច្បាប់ជាអ្វី ដោយមិនមែនយកការអនុវត្តទម្លាប់ដែលអាចងាយនឹងប្រាសចាកពីគន្លងច្បាប់នោះទេ។

**ពង្រីកគុណភាពនៃការស្រាវជ្រាវ៖** ជាបញ្ហាដែលយើងខ្ញុំសព្វថ្ងៃ ក៏ចែករំលែកបទពិសោធន៍ច្បាប់ពីអ្នកអនុវត្តដូចជា ចៅក្រម មេធាវី ក្រឡាបញ្ជី អាជ្ញាសាលា គឺមានលក្ខណៈសកម្មជាខ្លាំង។ ក៏ប៉ុន្តែ បែរជាពុំសូវឃើញមានសាស្ត្រាចារ្យច្បាប់ អ្នកទ្រឹស្ដីច្បាប់ធ្វើការចូលរួមនៅក្នុងវេទិកាច្បាប់ទាល់តែសោះ។ ការស្រាវជ្រាវគឺមានសារៈសំខាន់ណាស់ទៅលើការឆ្លុះបញ្ចាំបន្ថែមលើចំណុចខ្វះខាតនៃច្បាប់ និងការអនុវត្ត ដើម្បីឱ្យមានលំនឹងក្នុងការឆ្លុះ

គ្នាទៅវិញទៅមករវាងទ្រឹស្តី និងការអនុវត្ត។ បញ្ហានៃការអនុវត្តខុសនេះ អាចបណ្តាលមកពីការមិនទាន់យល់ច្បាស់ពីខ្លឹមសារនៃទ្រឹស្តីច្បាប់ ឬភាពខ្វះចន្លោះនៃច្បាប់ដែលអាចឱ្យចៅក្រមប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនបានដោយសេរី។

**ធ្វើបច្ចុប្បន្នភាពច្បាប់ស្របនឹងកាលៈទេសៈ៖** ជាក់ណាស់ថាច្បាប់មិនមែនតាក់តែងមកម្តងគឺមានភាពល្អគ្មានទាស់នោះទេ ព្រោះភាគច្រើននៃច្បាប់ក៏អាចកើតចេញពីការប្រមើលមើលទុកជាមុនពីបញ្ហាសង្គមដែលនឹងអាចកើតឡើង។ ដូច្នេះព្រឹត្តិការណ៍សង្គមអាចដូចនឹងអ្វីដែលយើងប្រមើលទុក ឬក៏អាចខុសពីនោះ។ ដូច្នេះភាពខ្វះខាតដែលជាបញ្ហាគួរតែមានការដោះស្រាយឱ្យដាច់ស្រេចទើបជាការប្រសើរ។

# ឯកសារយោង

- **ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ ៖**
  - រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។
  - ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។
  - ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។
  - ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១។
  - ច្បាប់ទាំង៦របស់ជប៉ុន（六法）។
  - ច្បាប់ស្តីពីការចាត់ចែងរក្សាការពារ(ប្រទេសជប៉ុន)។
- **ឯកសារយោងជាសៀវភៅ ឬស្លាយ ៖**
  - សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី រៀបចំដោយក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧។
  - សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី រៀបចំដោយគណៈកម្មការទទួលបន្ទុកកិច្ចការផ្នែកច្បាប់រដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណីកម្ពុជា និងក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០១១។
  - សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២, រៀបចំក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី រក្សាសិទ្ធិដោយ ក្រសួងយុត្តិធម៌ បោះពុម្ពឆ្នាំ២០០៩។
  - មេរៀនក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១, រៀបរៀងដោយគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ ក្រសួងយុត្តិធម៌, បោះពុម្ពលើកទី១, រាជធានីភ្នំពេញ ខែធ្នូ ឆ្នាំ២០១៥។
  - មេរៀនក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១, រៀបរៀងដោយគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ ក្រសួងយុត្តិធម៌, បោះពុម្ពលើកទី១, រាជធានីភ្នំពេញ ខែធ្នូ ឆ្នាំ២០១៥។
  - សំណួរដែលត្រូវបានគេសួរញឹកញាប់ស្តីពីការចាត់ចែងរក្សាការពារ, បោះពុម្ពខែឧសភា ឆ្នាំ២០០៩។ (ជាភាសាខ្មែរ និងជប៉ុន)

    (ខេមរភាសា)៖ http://www.moj.go.jp/content/000032475.pdf

(ភាសាជប៉ុន)៖ http://www.moj.go.jp/content/000032474.pdf

- ការរក្សាការពាររដ្ឋប្បវេណី(ទ្រឹស្តីទូទៅ) របស់ក្រសួងយុត្តិធម៌ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់ ដោយសាស្ត្រាចារ្យ Uchiyama Jun។
- លោក ហ៊ីង ធីឫទ្ធី,「អត្ថាធិប្បាយ ច្បាប់ភាគ៣ ក្នុងរឿងរដ្ឋប្បវេណី」បោះពុម្ពលើកទី២ ឆ្នាំ២០០៧។
- បទបង្ហាញនៅសាលាដំបូងរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមេសា ឆ្នាំ ២០១៨ ដោយលោក MAEDA YUTA គ្រូបង្គោលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ និងជាអ្នកជំនាញការនៃក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី និងជាចៅក្រមនៃប្រទេសជប៉ុន។
- បទបង្ហាញនៃសិក្ខាសាលានៅកម្ពុជា ខែកក្កដា ឆ្នាំ ២០១៥ ប្រធានបទ "ការអនុវត្តរក្សាការពារក្នុងផ្នែករដ្ឋប្បវេណី និងការចុះបញ្ជី" របស់ការិយាល័យស្រាវជ្រាវនីតិកម្ម ផ្នែកកិច្ចសហប្រតិបត្តិការអន្តរជាតិនៃក្រសួងយុត្តិធម៌ ដោយសាស្ត្រាចារ្យច្បាប់ YUKAWA RYO

- **ឯកសារយោងក្នុងពត៌មាន និងទស្សនាវដ្ដីច្បាប់ ៖**
  - 傘谷祐之(Kasaya Yuushi)「植民地期カンボジアにおける法典編纂(ការចងក្រងក្រមច្បាប់នៅក្នុងប្រទេសកម្ពុជាសម័យអាណានិគមបារាំង)」បោះពុម្ពដោយICD NEWSលេខ៨១ ចុះថ្ងៃទី១២ ឆ្នាំ២០១៩។
  - 前田優太(MAEDAYUTA)「カンボジアにおける民事保全の実状(ស្ថានភាពជាក់ស្ដែងនៃការចាត់ចែងបណ្ដោះអាសន្នក្នុងប្រទេសកម្ពុជា)」បោះពុម្ពដោយICD NEWSលេខ៧៨ ចុះខែ៣ ឆ្នាំ ២០១៩។

# ឧបសម្ព័ន្ធ

# ព្រះរាជក្រម

នស/រកម/០៧០៦/០២១

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមនីតិវិធីរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០០៦នាសម័យប្រជុំពេញអង្គលើកទី១នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# គន្ថីទី ៧
# ការចាត់ចែងរក្សាការពារ

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ៥៣០.–** គោលគំនិត

ប្រសិនបើមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ឬ ប្រសិនបើមានការបារម្ភថា នឹងមានការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដល់ឋានៈរបស់ភាគីណាមួយ ដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ បុគ្គលដែលមានបំណងចង់ការពារសិទ្ធិរបស់ខ្លួន អាចទាមទារការចាត់ចែងរក្សាការពារ តាមបញ្ញត្តិនៃគន្ថីនេះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ផ្សេង ។

**មាត្រា ៥៣១.–** ប្រភេទនៃការចាត់ចែងរក្សាការពារ

ការចាត់ចែងរក្សាការពារសំដៅទៅលើការចាត់ចែងនីមួយៗ ដែលមានខ្លឹមសារដូចកំណត់នៅក្នុងចំណុចនីមួយៗ ខាងក្រោមនេះ :

ក-ការរឹបអូសជាបណ្ដោះអាសន្ន : ការចាត់ចែងដែលកម្រិតនូវការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីរក្សាការពារការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ។

ខ-ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ : ការចាត់ចែងដែលរក្សាទុកនូវស្ថានភាពបច្ចុប្បន្ន នៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិ ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ ។

គ-ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន : ការចាត់ចែងដែលកំណត់ស្ថានភាពជាបណ្ដោះអាសន្នរហូតដល់សាលក្រម ឬ សាលដីកាចូល

ជាស្ថាពរ ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ ។

**មាត្រា ៥៣២.–** ស្ថាប័នចាត់ចែងរក្សាការពារជាបណ្ដោះអាសន្ន

១-ដីកាសម្រេចក្នុងការចាត់ចែងរក្សាការពារ ត្រូវធ្វើឡើងដោយតុលាការតាមពាក្យសុំ ។

២-ការអនុវត្តការចាត់ចែងរក្សាការពារ ត្រូវធ្វើឡើងដោយតុលាការ ឬ អាជ្ញាសាលាតាមពាក្យសុំ ។

៣-តុលាការដែលត្រូវអនុវត្តការចាត់ចែងរក្សាការពារ តាមបញ្ញត្តិនៃគន្ថីនេះ ត្រូវហៅថា តុលាការអនុវត្តការរក្សាការពារ ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ៤ នៃមាត្រា ៣៣៦ (ស្ថាប័នអនុវត្ត) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តការចាត់ចែងរក្សាការពារ ដែលធ្វើឡើងដោយអាជ្ញាសាលា ។

**មាត្រា ៥៣៣.–** សមត្ថកិច្ចផ្ដាច់មុខ

សមត្ថកិច្ចរបស់តុលាការដែលបានកំណត់នៅក្នុងគន្ថីនេះ គឺជាសមត្ថកិច្ចផ្ដាច់មុខ ។

**មាត្រា ៥៣៤.–** របៀបដាក់ពាក្យសុំ

ពាក្យសុំដែលបានកំណត់ខាងក្រោមនេះ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ :

ក-ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ។

ខ-ពាក្យបណ្ដឹងជំទាស់ចំពោះដីកាសម្រេចលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ។

គ-ពាក្យសុំតវ៉ាចំពោះការរក្សាការពារ ។

ឃ-ពាក្យសុំឱ្យលុបចោលដីកាសម្រេចរក្សាការពារ ។

ង-ពាក្យបណ្ដឹងជំទាស់ដែលបានកំណត់នៅក្នុងមាត្រា ៥៦១ (បណ្ដឹងជំទាស់) នៃក្រមនេះ ។

ច-ពាក្យសុំឱ្យអនុវត្តការរក្សាការពារ ។

**មាត្រា ៥៣៥.–** ការសម្រេចសេចក្ដីចំពោះនីតិវិធីនៃការរក្សាការពារ ជាអាទិ៍

១-ការសម្រេចសេចក្ដីដែលទាក់ទងនឹងនីតិវិធីនៃដីកាសម្រេចរក្សាការពារ និង នីតិវិធីដែលតុលាការធ្វើចំពោះការអនុវត្តរក្សាការពារ ត្រូវធ្វើឡើងដោយដីកាសម្រេច ។

២-បើយល់ឃើញថាចាំបាច់ នៅពេលចាត់ចែងធ្វើការអនុវត្ត តុលាការអនុវត្តការរក្សាការពារ អាចសួរជនដែលមានផលប្រយោជន៍ពាក់ព័ន្ធ ឬ ជនដែលពាក់ព័ន្ធផ្សេងទៀតបាន ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសាលាដំបូងត្រូវសម្រេចសេចក្ដីអំពីឧបាស្រ័យចំពោះការចាត់ចែងការអនុវត្ត ដែលធ្វើឡើងដោយអាជ្ញាសាលា ។

**មាត្រា ៥៣៦.–** ការផ្ដល់នូវប្រាតិភោគ

ដើម្បីដាក់ប្រាតិភោគតាមបញ្ញត្តិនៃគន្ថីនេះ ភាគីត្រូវធ្វើតាមវិធីធ្វើប្រាក់ ឬ ឧបករណ៍អាចជួញដូរបាន ដែលតុលាការទទួលស្គាល់ថាសមរម្យ ទៅតុលាការដែលបង្គាប់ឱ្យដាក់ប្រាតិភោគនោះ ឬ តុលាការអនុវត្តការរក្សាការពារ ។

**មាត្រា ៥៣៧.–** សោហ៊ុយនៃការចាត់ចែងរក្សាការពារ ជាអាទិ៍

១-ក្នុងករណីដែលដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ អ្នកដែលដាក់ពាក្យសុំ ត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀល ទៅតុលាការ ។

២-ពេលដាក់ពាក្យសុំឱ្យធ្វើការអនុវត្តការរក្សាការពារទៅតុលាការអនុវត្តការរក្សាការពារ អ្នកដែលដាក់ពាក្យសុំ ត្រូវបង់ជាមុននូវចំនួនទឹកប្រាក់ដែលកំណត់ដោយតុលាការអនុវត្តការរក្សាការពារ ដែលជាសោហ៊ុយចាំបាច់សម្រាប់នីតិវិធីអនុវត្តការរក្សាការពារ ។

៣-ប្រសិនបើអ្នកដែលដាក់ពាក្យសុំមិនបានបង់សោហ៊ុយនោះទុកជាមុនទេ តុលាការអនុវត្តការរក្សាការពារ អាចលើកចោលពាក្យសុំឱ្យធ្វើការអនុវត្តការរក្សាការពារ ឬ អាចលុបចោលនូវនីតិវិធីអនុវត្តការរក្សាការពារបាន ។

៤-ចំពោះដីកាសម្រេចលើកចោលនូវពាក្យសុំ តាមបញ្ញត្តិនៃកថាខណ្ឌទី ៣ អាចប្ដឹងជំទាស់បាន ។

៥-ក្នុងករណីដែលដាក់ពាក្យសុំឱ្យអនុវត្តការរក្សាការពារចំពោះអាជ្ញាសាលា អ្នកដែលដាក់ពាក្យសុំត្រូវបង់ពន្ធ តាមបញ្ញត្តិដែលបានកំណត់ផ្សេង ។

**មាត្រា ៥៣៨.-** ការមើលសំណុំរឿងនៃការចាត់ចែងរក្សាការពារ ជាអាទិ៍

១-ជនដែលបានធ្វើសេចក្តីបញ្ជាក់ដំបូងអំពីការពាក់ព័ន្ធនឹងផលប្រយោជន៍ ចំពោះនីតិវិធីទាក់ទងនឹងដីកាសម្រេចរក្សាការពារ ឬ នីតិវិធីដែលតុលាការធ្វើឡើងចំពោះការអនុវត្តរក្សាការពារ អាចទាមទារមើលសំណុំរឿង ថតចម្លងសំណុំរឿង ឱ្យប្រគល់ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬ ឯកសារដកស្រង់នៃសំណុំរឿង ឬ អាចទាមទារឱ្យប្រគល់លិខិតបញ្ជាក់អំពីចំណុចដែលពាក់ព័ន្ធនឹងរឿងក្តី ពីតុលាការបាន ដោយបង់ពន្ធ ។

២-ជនដែលបានធ្វើសេចក្តីបញ្ជាក់ដំបូងអំពីការពាក់ព័ន្ធនឹងផលប្រយោជន៍ ចំពោះការអនុវត្តរក្សាការពារដែលធ្វើឡើងដោយអាជ្ញាសាលា អាចទាមទារមើលសំណុំរឿង ថតចម្លងសំណុំរឿង ឱ្យប្រគល់ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬ ឯកសារដកស្រង់នៃសំណុំរឿង ឬ អាចទាមទារឱ្យប្រគល់លិខិតបញ្ជាក់អំពីចំណុចដែលពាក់ព័ន្ធនឹងរឿងក្តី ពីអាជ្ញាសាលាបាន ដោយបង់ពន្ធ ។

**មាត្រា ៥៣៩.-** ការអនុវត្តដូចគ្នា តាមបញ្ញត្តិពីគន្ថីទី ២ ដល់គន្ថីទី ៤

បញ្ញត្តិពីគន្ថីទី ២ ដល់គន្ថីទី ៤ នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការចាត់ចែងរក្សាការពារ លើកលែងតែមានបញ្ញត្តិពិសេស ។

## ជំពូកទី ២
## ដីកាសម្រេចរក្សាការពារ

### ផ្នែកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ៥៤០.-** តុលាការដែលមានសមត្ថកិច្ច

១-រឿងក្តីនៃដីកាសម្រេចរក្សាការពារ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី ឬ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្តោះអាសន្ន ឬវត្ថុដែលជាកម្មវត្ថុនៃវិវាទ ស្ថិតនៅ ។

២-តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី គឺជាតុលាការនៃការជំនុំជម្រះលើកទី ១ ។ ប៉ុន្តែ បើអង្គសេចក្តី ត្រូវបានចាត់ការ ក្នុងនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី គឺជាតុលាការនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ។

៣-បើកម្មវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្តោះអាសន្ន ឬ កម្មវត្ថុនៃវិវាទ ជាសិទ្ធិលើបំណុល ត្រូវចាត់ទុកថា សិទ្ធិលើបំណុលនោះ ស្ថិតនៅកន្លែងរបស់កូនបំណុលទី ៣ ដែលបានកំណត់នៅក្នុងមាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅតាមលំនៅឋានជាអាទិ៍) នៃក្រមនេះ ។ ប៉ុន្តែ ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងប្រគល់នាវា ឬ ចលនវត្ថុ ត្រូវចាត់ទុកថា សិទ្ធិលើបំណុលនោះស្ថិតនៅទីកន្លែងដែលវត្ថុនោះស្ថិតនៅ ។

៤-បញ្ញត្តិនៃវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកម្មវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្តោះអាសន្ន ឬ កម្មវត្ថុនៃវិវាទ ជាសិទ្ធិលើទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងមាត្រា ៤១៦ (ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត) នៃក្រមនេះ ហើយមានកូនបំណុលទី ៣ ឬ បុគ្គលដែលមានលក្ខណៈដូចជាកូនបំណុលទី ៣ ។

**មាត្រា ៥៤១.-** ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ និង សេចក្តីបញ្ជាក់ដំបូង

១-ក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ត្រូវសរសេរបញ្ជាក់នូវចំណុចដូចបានកំណត់ខាងក្រោមនេះ :

ក-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ-ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ ។

គ-សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ ។

ឃ-ភាពចាំបាច់នៃការរក្សាការពារ ។

២-ចំពោះចំណុច គ និង ឃ នៃកថាខណ្ឌទី ១ ខាងលើនេះ អ្នកដែលដាក់ពាក្យសុំ គប្បីសរសេរឱ្យបានច្បាស់លាស់ និង សរសេរនូវភស្តុតាង តាមហេតុនីមួយៗដែលត្រូវបញ្ជាក់ ។

៣-ចំពោះចំណុច គ និង ឃ នៃកថាខណ្ឌទី ១ ខាងលើនេះ អ្នកដែលដាក់ពាក្យសុំត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង ។

**មាត្រា ៥៤២.-** ប្រាតិភោគសម្រាប់ដីកាសម្រេចរក្សាការពារ

ដីកាសម្រេចរក្សាការពារ អាចធ្វើដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគបាន ។

**មាត្រា ៥៤៣.-** ការបញ្ជូន

តុលាការត្រូវបញ្ជូនដីកាសម្រេចរក្សាការពារទៅភាគី ។

**មាត្រា ៥៤៤.-** បណ្តឹងជំទាស់ចំពោះសេចក្តីសម្រេចលើកចោល

១-ចំពោះសេចក្តីសម្រេចដែលលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ម្ចាស់បំណុលអាចប្តឹងជំទាស់បាន ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ចាប់ពីថ្ងៃដែលខ្លួនបានទទួលការជូនដំណឹង ។

២-អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចពន្យារបានឡើយ ។

## ផ្នែកទី ២
## ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

**មាត្រា ៥៤៥.-** ភាពចាំបាច់នៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

១-ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន អាចចេញបានចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ក្នុងករណីដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ។

២-ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន អាចចេញបាន ទោះបីជាសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ភ្ជាប់នឹងល័ក្ខខ័ណ្ឌ ឬ ពេលកំណត់ក៏ដោយ ។

**មាត្រា ៥៤៦.-** កម្មវត្ថុនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

តុលាការត្រូវចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដោយកំណត់ជាក់លាក់នូវកម្មវត្ថុ ។ ប៉ុន្តែ ចំពោះដីកាសម្រេចរឹបអូសចលនវត្ថុជាបណ្តោះអាសន្ន អាចចេញបាន

ដោយមិនចាំបាច់កំណត់កម្មវត្ថុ ។

**មាត្រា ៥៤៧.–** ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន

១-ក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តុលាការត្រូវកំណត់ចំនួនទឹកប្រាក់ដែលកូនបំណុលត្រូវផ្ញើ ដើម្បីទទួលបាននូវការលុបចោលការអនុវត្តការរឹបអូសជាបណ្តោះ-អាសន្ន ។

២-ការផ្ញើប្រាក់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ ត្រូវធ្វើឡើងនៅតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬ តុលាការអនុវត្តការរក្សាការពារ ។

## ផ្នែកទី ៣
## ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន

**មាត្រា ៥៤៨.–** ភាពចាំបាច់នៃដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ជាអាទិ៍

១-តុលាការអាចចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទបាន ក្នុងករណីដែលមានការ បារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ ។

២-តុលាការអាចចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៥៤៥ (ភាពចាំបាច់នៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ។

៤-តុលាការមិនអាចចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បានឡើយ បើមិនឆ្លងកាត់តាមកាលបរិច្ឆេទនៃការ

ទាញហេតុផលដោយផ្ទាល់មាត់ ឬ តាមកាលបរិច្ឆេទនៃការសួរដែលកូនបំណុលអាចចូលរួមបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានស្ថានភាពពិសេស ដែលនាំឱ្យពុំអាចសម្រេចគោលបំណងនៃពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដោយសារឆ្លងកាត់តាមកាលបរិច្ឆេទនោះ ។

**មាត្រា ៥៤៩.-** វិធីចាត់ចែងជាបណ្ដោះអាសន្ន

តុលាការអាចចាត់ចែងឱ្យកូនបំណុលធ្វើ ឬ មិនធ្វើអំពើណាមួយជាកំណត់ ឬ ឱ្យកូនបំណុលផ្ដល់តាវកាលិក ឬ ឱ្យអ្នកថែរក្សាគ្រប់គ្រង ថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃការចាត់ចែងជាបណ្ដោះអាសន្ន ឬ ធ្វើការចាត់ចែងផ្សេងទៀតបាន តាមកម្រិតនៃភាពចាំបាច់ដើម្បីសម្រេចគោលបំណងនៃពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ។

## ផ្នែកទី ៤
## ការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

**មាត្រា ៥៥០.-** ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

កូនបំណុលអាចដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ទៅតុលាការដែលបានចេញដីកាសម្រេចនោះ ។

**មាត្រា ៥៥១.-** ការសម្រេចសេចក្ដីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍

១-ក្នុងករណីដែលមានពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការអាចបង្គាប់ឱ្យផ្អាកការអនុវត្តរក្សាការពារ ឬ លុបចោលការចាត់ចែងការអនុវត្ត តាមពាក្យសុំដោយឱ្យដាក់ប្រាតិភោគបាន រហូតដល់ធ្វើការសម្រេចសេចក្ដី តាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងក្រោមនេះ ក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ លុះត្រាតែមានសេចក្ដីបញ្ជាក់ដំបូងអំពីស្ថានភាពដែលច្បាស់ថា នឹងក្លាយជាមូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារ និង អំពីការដែលមានការបារម្ភថា ការខូចខាតដែលមិនអាចសងបាន នឹងកើតឡើងដោយសារការអនុវត្តរក្សាការពារ ។

២-ក្នុងករណីដែលតុលាការនៃបណ្ដឹងជំទាស់បានចេញដីកាសម្រេចរក្សាការពារ បើមានសំណុំរឿងនៅតុលាការដើម តុលាការដើមនោះក៏អាចធ្វើការសម្រេចសេចក្ដី តាម

បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះបានដែរ ។

៣-នៅក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវលុបចោល ផ្លាស់ប្តូរ ឬ ទទួលស្គាល់នូវសេចក្តីសម្រេចដែលបានធ្វើរួចហើយ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៥៥២.-** ការវិនិច្ឆ័យអំពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

តុលាការមិនអាចចេញដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារបានឡើយ បើមិនបានឆ្លងកាត់តាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ តាមកាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន ។

**មាត្រា ៥៥៣.-** ការបញ្ចប់ការវិនិច្ឆ័យ

ដើម្បីបញ្ចប់ការវិនិច្ឆ័យអំពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវសម្រេចថ្ងៃបញ្ចប់ការវិនិច្ឆ័យ ដោយកំណត់អំឡុងពេលអនុគ្រោះដ៏សមរម្យ ។ ប៉ុន្តែ នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន តុលាការអាចប្រកាសដោយភ្លាមៗថា បញ្ចប់ការវិនិច្ឆ័យ ។

**មាត្រា ៥៥៤.-** ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

១-នៅក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវទទួលស្គាល់ ផ្លាស់ប្តូរ ឬ លុបចោលនូវដីកាសម្រេចរក្សាការពារ ។

២-ចំពោះដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារដែលធ្វើឡើងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការអាចដាក់ល័ក្ខខ័ណ្ឌឱ្យកូនបំណុលដាក់ប្រាតិភោគបាន ។

៣-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ ។

**មាត្រា ៥៥៥.-** ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន

បើម្ចាស់បំណុលបានទទួលការប្រគល់វត្ថុ ឬ ការបង់ប្រាក់ ឬ ប្រើប្រាស់ឬថែរក្សាគ្រប់គ្រងវត្ថុ ដោយផ្អែកលើដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន តុលាការអាចបង្គាប់

ឱ្យម្ចាស់បំណុលបង្វិលសងវត្ថុដែលកូនបំណុលបានប្រគល់ ឬ សងប្រាក់ដែលកូនបំណុលបានបង់ ឬ បង្វិលសងវត្ថុដែលម្ចាស់បំណុលកំពុងប្រើប្រាស់ឬថែរក្សាគ្រប់គ្រងបាន តាមពាក្យសុំរបស់កូនបំណុល នៅក្នុងដីកាសម្រេចដែលលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន តាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥៤ (ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ។

**មាត្រា ៥៥៦.-** អានុភាពនៃដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារ

ដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៥៥៤ (ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ពុំមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរ ។ ប៉ុន្តែ បើយល់ឃើញថា ចាំបាច់ពិសេស តុលាការអាចប្រកាសថា ដីកាសម្រេចនោះមានអានុភាពភ្លាមៗ ។

## ផ្នែកទី ៥
## ការលុបចោលដីកាសម្រេចរក្សាការពារ

**មាត្រា ៥៥៧.-** ការលុបចោលដីកាសម្រេចរក្សាការពារដោយសារមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ជាអាទិ៍

១-តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ត្រូវបង្គាប់ឱ្យម្ចាស់បំណុលដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ហើយឱ្យដាក់ឯកសារដែលបញ្ជាក់អំពីការដាក់ពាក្យបណ្ដឹងនោះ ក្នុងអំឡុងពេលដែលទទួលស្គាល់ថាសមរម្យ តាមពាក្យសុំរបស់កូនបំណុល ។

២-អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវមានរយៈពេលមិនតិចជាង ២ (ពីរ) សប្ដាហ៍ ។

៣-បើម្ចាស់បំណុលមិនដាក់ឯកសារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្នុងអំឡុងពេលដែលត្រូវបានកំណត់ តាមបញ្ញត្តិនៃកថាខណ្ឌដដែលនោះ តុលាការត្រូវលុបចោលដីកាសម្រេចរក្សាការពារ តាមពាក្យសុំរបស់កូនបំណុល ។

៤-ក្នុងករណីដែលពាក្យបណ្ដឹងអង្គសេចក្ដីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានដកវិញ ឬ ត្រូវបានលើកចោល នៅក្រោយពេលដែលឯកសារដែល

បានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនោះ ត្រូវបានដាក់ ត្រូវចាត់ទុកថា ឯកសារនោះមិនបានដាក់ឡើយ ។

៥-ចំពោះការអនុវត្តបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ៣ ខាងលើនេះ បើមានកិច្ចសន្យាមជ្ឈត្តកម្មអំពីអង្គសេចក្ដី ការចាប់ផ្ដើមនីតិវិធីមជ្ឈត្តកម្ម ត្រូវចាត់ទុកជាការដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ។

៦-បើនីតិវិធីមជ្ឈត្តកម្មដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៥ ខាងលើនេះ បានចប់មិនមែនដោយសេចក្ដីសម្រេចមជ្ឈត្តករ ម្ចាស់បំណុលត្រូវដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ក្នុងអំឡុងពេលដូចគ្នានឹងអំឡុងពេលដែលបានកំណត់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ចាប់ពីថ្ងៃដែលនីតិវិធីមជ្ឈត្តកម្មនោះបានចប់ ។

៧-បញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់បំណុលមិនបានដាក់ពាក្យបណ្ដឹងអង្គសេចក្ដីតាមបញ្ញត្តិនៃកថាខណ្ឌទី ៦ ហើយបញ្ញត្តិនៃកថាខណ្ឌទី ៤ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបណ្ដឹងអង្គសេចក្ដីត្រូវបានដាក់តាមបញ្ញត្តិនៃកថាខណ្ឌទី ៦ តែក្រោយមកត្រូវបានដកវិញ ឬ ត្រូវបានលើកចោល ។

៨-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចតាមកថាខណ្ឌទី ៣ និង ទី ៧ ។

**មាត្រា ៥៥៨.–** ការលុបចោលដីកាសម្រេចរក្សាការពារ ដោយសារការផ្លាស់ប្ដូរស្ថានភាព

១-បើមានការរលត់សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ ឬ ភាពចាំបាច់ក្នុងការរក្សាការពារ ឬ ការផ្លាស់ប្ដូរផ្សេងទៀតនៃស្ថានភាព តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ឬ តុលាការនៃបណ្ដឹងអង្គសេចក្ដី អាចលុបចោលដីកាសម្រេចរក្សាការពារ តាមពាក្យសុំរបស់កូនបំណុលបាន ។

២-ចំពោះការផ្លាស់ប្ដូរស្ថានភាពដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ កូនបំណុលត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូង ។

៣-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) និង កថាខណ្ឌទី ២ នៃមាត្រា ៥៥៤ (ដីកា

សម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ត្រូវយកមកអនុវត្ត ដូចគ្នាផងដែរ ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៥៥៩.-** ការលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដោយសារស្ថានភាពពិសេស

១-ប្រសិនបើមានការបារម្ភថា ការខូចខាតដែលមិនអាចសងបាន នឹងកើតឡើងដោយសារដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ឬ មានស្ថានភាពពិសេសផ្សេងទៀត តុលាការដែលបានចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ឬ តុលាការនៃបណ្ដឹងអង្គសេចក្ដី អាចលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ននោះបាន ដោយមានល័ក្ខខ័ណ្ឌតម្រូវឱ្យដាក់ប្រាតិភោគ តាមពាក្យសុំរបស់កូនបំណុល ។

២-ចំពោះស្ថានភាពពិសេសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ កូនបំណុលត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូង ។

៣-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៥៦០.-** ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្ដីពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ជាអាទិ៍

១-បញ្ញត្តិពីមាត្រា ៥៥១ (ការសម្រេចសេចក្ដីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) ដល់មាត្រា ៥៥៣ (ការបញ្ចប់ការវិនិច្ឆ័យ) មាត្រា ៥៥៥ (ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន) និង មាត្រា ៥៥៦ (អានុភាពនៃដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការសម្រេចសេចក្ដីអំពីការលុបចោលដីកាសម្រេចរក្សាការពារ លើកលែងតែចំពោះការសម្រេចសេចក្ដី តាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥៧ (ការលុបចោលដីកាសម្រេចរក្សាការពារដោយសារមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ជាអាទិ៍) ។

២-ចំពោះការសម្រេចសេចក្ដីតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥១ (ការសម្រេចសេចក្ដីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) នៃក្រមនេះ ដែលត្រូវយកមកអនុវត្ត

ដូចគ្នា នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្នុងករណីដែលពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារ ត្រូវបានដាក់ទៅតុលាការនៃបណ្ដឹងអង្គសេចក្ដី ផ្សេងពីតុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ហើយមានសំណុំរឿងនៅតុលាការដែលបានចេញដីកាសម្រេចរក្សាការពារ តុលាការដែលបានចេញដីកាសម្រេចរក្សាការពារនោះ ក៏អាចធ្វើការសម្រេចសេចក្ដី តាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥១ នោះបានដែរ ។

## ផ្នែកទី ៦
## បណ្ដឹងជំទាស់

**មាត្រា ៥៦១.-** បណ្ដឹងជំទាស់

១-ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ អាចប្ដឹងជំទាស់ក្នុងអំឡុងពេល២ (ពីរ) សប្ដាហ៍ ចាប់ពីថ្ងៃដែលបានទទួលការបញ្ជូននោះ :

ក-ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ឬ ពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរក្សាការពារ ។

ខ-ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃមាត្រា ៥៥៥ (ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន) នៃក្រមនេះ ។

គ-ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃមាត្រា ៥៥៥ (ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន) នៃក្រមនេះ ដែលត្រូវយកមកអនុវត្តដូចគ្នា នៅក្នុងកថាខណ្ឌទី ១ មាត្រា ៥៦០ (ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្ដីពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ជាអាទិ៍) ។

ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសេចក្ដីសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ដែលបានធ្វើឡើងដោយតុលាការនៃបណ្ដឹងជំទាស់ ។

២-អំឡុងពេលដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ ពុំអាចពន្យារបានទេ ។

៣-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) និង មាត្រា ៥៥៤ (ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចអំពីបណ្ដឹងជំទាស់ ហើយបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៥៥១ (ការសម្រេចសេចក្ដីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) មាត្រា ៥៥២ (ការវិនិច្ឆ័យអំពីការតវ៉ា

ចំពោះដីកាសម្រេចរក្សាការពារ) មាត្រា ៥៥៣ (ការបញ្ចប់ការវិនិច្ឆ័យ) និង មាត្រា ៥៥៥ (ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការសម្រេចសេចក្ដីដែលពាក់ព័ន្ធនឹងបណ្ដឹងជំទាស់ ហើយបញ្ញត្តិនៃមាត្រា ៣១៧ (ពាក្យសុំឱ្យជំនុំជម្រះសាជាថ្មីចំពោះដីកាសម្រេច) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសេចក្ដីសម្រេចដែលអាចប្ដឹងជំទាស់បាន បានចូលជាស្ថាពរ ។

៤-ចំពោះការសម្រេចសេចក្ដីតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥១ (ការសម្រេចសេចក្ដីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) នៃក្រមនេះ ដែលត្រូវយកមកអនុវត្តដូចគ្នា នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ក្នុងករណីដែលមានសំណុំរឿងនៅតុលាការដើម តុលាការដើមនោះក៏អាចធ្វើការសម្រេចសេចក្ដីតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥១ នោះបានដែរ ។

## ជំពូកទី ៣
## ការអនុវត្តរក្សាការពារ

**មាត្រា ៥៦២.-** លក្ខខណ្ឌនៃការអនុវត្តរក្សាការពារ

១-ការអនុវត្តរក្សាការពារត្រូវធ្វើឡើងដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារ ។ ប៉ុន្តែ ការអនុវត្តរក្សាការពារចំពោះ ឬ សម្រាប់ជនក្រៅពីភាគី ដែលត្រូវបានកំណត់នៅក្នុងដីកាសម្រេចរក្សាការពារ ត្រូវធ្វើឡើង ដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារដែលភ្ជាប់នឹងរូបមន្តអនុវត្ត ។

២-ការអនុវត្តរក្សាការពារ មិនត្រូវធ្វើឡើយ បើអំឡុងពេល ២ (ពីរ) សប្ដាហ៍ បានកន្លងហួស ចាប់ពីថ្ងៃដែលដីកាសម្រេចរក្សាការពារ ត្រូវបានបញ្ជូនទៅម្ចាស់បំណុល ។

៣-ទោះបីនៅមុនពេលដែលដីកាសម្រេចរក្សាការពារ ត្រូវបានបញ្ជូនទៅកូនបំណុលក៏ដោយ ក៏ការអនុវត្តរក្សាការពារ អាចធ្វើបានដែរ ។

**មាត្រា ៥៦៣.–** ករណីពិសេសនៃតុលាការដែលមានសមត្ថកិច្ចលើបណ្តឹងតវ៉ារបស់តតិយជន

ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣៦៥ (បណ្តឹងតវ៉ារបស់តតិយជន) នៃក្រមនេះក៏ដោយ ក៏បណ្តឹងតវ៉ារបស់តតិយជន ចំពោះដីកាសម្រេចរក្សាការពារដែលសាលាឧទ្ធរណ៍បានធ្វើ ក្នុងនាមជាតុលាការអនុវត្តរក្សាការពារ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែង ដែលវត្ថុត្រូវរឹបអូសជាបណ្តោះអាសន្ន ឬ វត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ ។

**មាត្រា ៥៦៤.–** ការអនុវត្តដូចគ្នា តាមបញ្ញត្តិនៃគន្ថីទី ៦

លើកលែងតែករណីដែលមានបញ្ញត្តិពិសេសក្នុងជំពូកនេះ បញ្ញត្តិពីមាត្រា ៣៣៨ (ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលា ជាអាទិ៍) ដល់មាត្រា ៣៤៥ (បណ្តឹងជំទាស់ចំពោះដីកាសម្រេចលុបចោល ជាអាទិ៍) បញ្ញត្តិនៃមាត្រា ៣៤៨ (អ្នកតំណាងដោយអាណត្តិក្នុងនីតិវិធីទាក់ទងនឹងការអនុវត្តដោយបង្ខំ) បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៣៤៩ (របៀបដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ នៃមាត្រា ៣៥១ (វិសាលភាពនៃអ្នកដែលអាចអនុវត្តដោយបង្ខំ) កថាខណ្ឌទី ២ នៃមាត្រា ៣៥៤ (ភាពចាំបាច់នៃរូបមន្តអនុវត្ត និង ស្ថាប័នផ្តល់រូបមន្តអនុវត្ត) កថាខណ្ឌទី ១ និង ទី ៣ នៃមាត្រា ៣៥៥ (ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត) ពីកថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៤ នៃមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស) ពីមាត្រា ៣៥៧ (ចំណុចដែលត្រូវសរសេរក្នុងរូបមន្តអនុវត្ត) ដល់មាត្រា ៣៥៩ (ការសរសេរចូលទៅក្នុងច្បាប់ដើមនៃលិខិតអនុវត្ត) មាត្រា ៣៦២ (ពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត ជាអាទិ៍) បញ្ញត្តិនៃមាត្រា ៣៦៤ (បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត) និង មាត្រា ៣៦៥ (បណ្តឹងតវ៉ារបស់តតិយជន) និង បញ្ញត្តិពីមាត្រា ៣៦៧ (ការសម្រេចសេចក្តីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ជាអាទិ៍) ដល់មាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) នៃក្រមនេះ ត្រូវយកមកអនុវត្ត ដូចគ្នាផងដែរ ចំពោះការអនុវត្តរក្សាការពារ ។

**មាត្រា ៥៦៥.–** ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុ

១-ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុ ត្រូវធ្វើតាមរបៀបកាន់កាប់វត្ថុដែលជាកម្មវត្ថុ ដោយអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុដែលជាកម្មវត្ថុនោះស្ថិតនៅ ។

២-អាជ្ញាសាលាត្រូវធ្វើប្រាក់ដែលបានមកពីការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន នៅតុលាការដែលខ្លួនស្ថិតនៅ ។

៣-បើមានការបារម្ភថា ចលនវត្ថុដែលការរឹបអូសជាបណ្ដោះអាសន្នត្រូវបានអនុវត្តនឹងចុះតម្លៃយ៉ាងខ្លាំង ឬ បើត្រូវការសោហ៊ុយច្រើនហួសហេតុដើម្បីរក្សាទុកចលនវត្ថុនោះ អាជ្ញាសាលាត្រូវលក់ចលនវត្ថុនោះ តាមនីតិវិធីលក់នៃការអនុវត្តចំពោះចលនវត្ថុដែលបានកំណត់នៅក្នុងផ្នែកទី ២ ជំពូកទី ២ នៃគន្ថីទី ៦ នៃក្រមនេះ តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការរឹបអូសជាបណ្ដោះអាសន្ន ឬ កូនបំណុល ហើយធ្វើប្រាក់ដែលបានមកពីការលក់នោះនៅតុលាការដែលខ្លួនស្ថិតនៅ ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣៨៤ (ការចាប់ផ្ដើមអនុវត្តចំពោះចលនវត្ថុ) ពីមាត្រា ៣៨៥ (ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត) ដល់មាត្រា ៣៩២ (ការហាមឃាត់មិនឱ្យរឹបអូសក្នុងករណីដែលប៉ាន់ប្រមាណឃើញថា គ្មានចំនួនសេសសល់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុ ។

**មាត្រា ៥៦៦.–** ការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

១-ការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ចំពោះសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងមាត្រា ៤០២ (អត្ថន័យនៃការអនុវត្តចំពោះសិទ្ធិលើបំណុល និង តុលាការអនុវត្ត) នៃក្រមនេះ ត្រូវធ្វើតាមរបៀបដែលតុលាការអនុវត្តរក្សាការពារ ចេញដីកាសម្រេចដែលហាមឃាត់មិនឱ្យកូនបំណុលទី ៣ សងទៅកូនបំណុល ។

២-ចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្នដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការដែលបានចេញដីកាសម្រេចរឹបអូសបណ្ដោះអាសន្ន ត្រូវមានសមត្ថ-

កិច្ចជាតុលាការអនុវត្តរក្សាការពារ ។

៣-ក្នុងករណីដែលការរឹបអូសជាបណ្តោះអាសន្ន ត្រូវបានអនុវត្តចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ បើកូនបំណុលទី៣បានផ្ញើប្រាក់ដែលស្មើនឹងចំនួនប្រាក់នៃសិទ្ធិលើបំណុលនៅតុលាការ ត្រូវចាត់ទុកថា កូនបំណុលបានផ្ញើប្រាក់ដែលស្មើនឹងចំនួនប្រាក់ដែលត្រូវបានកំណត់តាមបញ្ញត្តិនៃមាត្រា ៥៤៧ (ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន) នៃក្រមនេះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះភាគដែលលើសពីចំនួនប្រាក់នោះ ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ។

៥-បញ្ញត្តិនៃកថាខណ្ឌទី ២ ទី ៣ ទី ៦ ទី៧ ទី ៨ ទី ១០ និង កថាខណ្ឌទី ១១ នៃមាត្រា ៤០៣ (ដីកាសម្រេចរឹបអូស) បញ្ញត្តិពីមាត្រា ៤០៤ (ទំហំនៃការរឹបអូស) ដល់មាត្រា ៤០៨ (ការជូនដំណឹងអំពីការដកពាក្យសុំ ជាអាទិ៍) មាត្រា ៤១១ (ការផ្ញើប្រាក់ទុកដោយកូនបំណុលទី ៣) និងមាត្រា ៤១៦ (ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្តោះ-អាសន្នចំពោះសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ។

**មាត្រា ៥៦៧.–** ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

១-ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤១៧ (កម្មវត្ថុ និង វិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ) នៃក្រមនេះ ត្រូវធ្វើតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ។

២-ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្ន តុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ ។

៣-ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៤២០ (ការផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូស

ជាអាទិ៍) វាក្យខណ្ឌទី ១ កថាខណ្ឌទី ៣ នៃមាត្រា ៤២១ (អានុភាពនៃការរឹបអូស) កថាខណ្ឌទី ១ នៃមាត្រា ៤២៤ (ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា) មាត្រា ៤២៥ (ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា នៃការអនុវត្តសិទ្ធិប្រាតិភោគ និង ការអនុវត្តចំពោះអចលនវត្ថុ) មាត្រា ៤២៧ (ការលុបចោលនីតិវិធីនៃការលក់ដោយបង្ខំដោយសារការបាត់បង់ ជាអាទិ៍ នៃអចលនវត្ថុ) និង មាត្រា ៤២៨ (ការផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស) នៃក្រមនេះ ត្រូវយកមកអនុ-វត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ។

**មាត្រា ៥៦៨.–** ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះនាវា

១-ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះនាវា ត្រូវធ្វើតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ឬ តាមរបៀបដែលបង្គាប់ឱ្យអាជ្ញាសាលាដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ហើយផ្តល់លិខិតនោះទៅ តុលាការអនុវត្តរក្សាការពារ ។ របៀបទាំងនេះ អាចអនុវត្តរួមគ្នាបាន ។

២-ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន តុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ រីឯការអនុវត្តរឹបអូសជាបណ្តោះអាសន្នតាមរបៀបដែលបង្គាប់ឱ្យដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវានោះស្ថិតនៅ ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ ។

៣-ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៤៥៥ (ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវា និង របៀបអនុវត្ត) មាត្រា ៤៦៥ (ការលុបចោលនីតិវិធីលក់ដោយបង្ខំ ដោយការវិនាសបាត់បង់នាវា ជាអាទិ៍) និង មាត្រា ៤៦៦ (ការផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្តោះ-អាសន្នតាមរបៀបចុះបញ្ជី ហើយបញ្ញត្តិនៃកថាខណ្ឌទី ៣ នៃមាត្រា ៤៥៥ (ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវា និង របៀបអនុវត្ត) កថាខណ្ឌទី ៧ នៃមាត្រា ៤៥៧ (ដីកាសម្រេចចាប់ផ្តើម ជាអាទិ៍) មាត្រា ៤៦០ (ការជ្រើសតាំងអ្នកថែរក្សាគ្រប់គ្រង ជាអាទិ៍) និង

មាត្រា ៤៦២ (ការអនុញ្ញាតឱ្យនាវាធ្វើដំណើរ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផង ដែរ ចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន តាមរបៀបដែលបង្គាប់ឱ្យដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ។

**មាត្រា ៥៦៩.-** ការលុបចោលការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ដោយធ្វើប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន

១-បើកូនបំណុលបានធ្វើប្រាក់ស្មើនឹងចំនួនប្រាក់ដែលបានកំណត់តាមបញ្ញត្តិនៃមាត្រា ៥៤៧ (ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន) នៃក្រមនេះ នៅតុលាការ តុលាការអនុវត្តរក្សាការពារ ឬ សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ ត្រូវលុបចោលនូវការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣៨៥ (បណ្ដឹងជំទាស់ចំពោះដីកាសម្រេចលុបចោល ជាអាទិ៍) នៃក្រមនេះ ដែលត្រូវយកអនុវត្តដូចគ្នា នៅក្នុងមាត្រា ៥៦៤ (ការអនុវត្តដូចគ្នា តាមបញ្ញត្តិនៃគន្ថីទី ៦) ក៏ដោយ ក៏ដីកាសម្រេចដែលធ្វើឡើង តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មានអានុភាពភ្លាមៗដែរ ។

**មាត្រា ៥៧០.-** ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន

ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន ត្រូវអនុវត្តតាមវិធីដូចគ្នានឹងវិធីអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ឬវិធីអនុវត្តដោយបង្ខំ ។

**មាត្រា ៥៧១.-** អានុភាពនៃការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់

១-បើដីកាសម្រេចដែលហាមឃាត់មិនឱ្យកូនបំណុលផ្ទេរការកាប់កាប់វត្ថុ និង បង្គាប់ឱ្យកូនបំណុលប្រគល់វត្ថុទៅអាជ្ញាសាលា ដោយដកហូតការកាន់កាប់នោះ ហើយបង្គាប់ឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុនោះ ដើម្បីរក្សាការពារសិទ្ធិទាមទារឱ្យប្រគល់វត្ថុនោះ ត្រូវបានចេញ អាជ្ញាសាលាត្រូវប្រកាសជាសាធារណៈថា កូនបំណុលត្រូវបានហាមឃាត់ការផ្ទេរការកាប់កាប់វត្ថុនោះ ហើយអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុនោះ ដោយបិទលិខិតប្រកាសជាសាធារណៈ តាមរបៀបដែលពុំងាយបកចេញ ឬ តាមរបៀបសមរម្យផ្សេងទៀត ។

២-បើការចាត់ចែងជាបណ្ដោះអាសន្នដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានអនុវត្ត ម្ចាស់បំណុលអាចធ្វើការអនុវត្តដោយបង្ខំឱ្យប្រគល់វត្ថុបាន ដោយផ្អែកលើលិខិតអនុវត្តនៃអង្គសេចក្ដី ។ ប៉ុន្តែ ម្ចាស់បំណុលអាចអនុវត្តបានតែចំពោះជនដែលកាន់កាប់វត្ថុនោះ ដោយដឹងថា ការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ននោះត្រូវបានធ្វើហើយ ។

៣-ជនដែលកាន់កាប់វត្ថុដែលពាក់ព័ន្ធក្រោយពេលការអនុវត្តចាត់ចែងជាបណ្ដោះ-អាសន្ន ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានសន្មតថា កាន់កាប់វត្ថុនោះ ដោយដឹងថា ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ននោះ ត្រូវបានធ្វើហើយ ។

# សំណួរដែលត្រូវបានគេសួរញឹកញាប់
# ស្តីអំពី
# ការចាត់ចែងរក្សាការពារ

បោះពុម្ពនៅខែ ឧសភា ឆ្នាំ ២០០៩

# ប្រភេទនៃការរក្សាការពារ

| ប្រភេទនៃការរក្សាការពារ | ប្រភេទនៃការរក្សាការពារ | សិទ្ធិដែលត្រូវបានរក្សាការពារ (មាត្រា ៥៤១ កថាខណ្ឌទី១ ចំណុច គ) | ភាពចាំបាច់ដែលត្រូវរក្សាការពារ (មាត្រា ៥៤១ កថាខណ្ឌទី១ ចំណុច ឃ) |
|---|---|---|---|
| ការរឹបអូសជាបណ្ដោះអាសន្ន (មាត្រា ៥៣១ ចំណុច ក) | ការរឹបអូសជាបណ្ដោះអាសន្ន ចំពោះអចលនវត្ថុ | សិទ្ធិលើបំណុលដែលទាមទារឱ្យសងប្រាក់ ( មាត្រា ៥៤៥ កថាខណ្ឌទី១ ) | មានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំង ក្នុងការអនុវត្តដោយបង្ខំ ( មាត្រា ៥៤៥ កថាខណ្ឌទី១ ) |
| | ការរឹបអូសជាបណ្ដោះអាសន្ន ចំពោះចលនវត្ថុ | | |
| | ការរឹបអូសជាបណ្ដោះអាសន្ន ចំពោះសិទ្ធិលើ បំណុល | | |
| ការចាត់ចែងជាបណ្ដោះអាសន្ន ចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ (មាត្រា ៥៣១ ចំណុច ខ) | ការចាត់ចែងជាបណ្ដោះអាសន្នហាមឃាត់ការផ្ទេរ ការកាន់កាប់ | សិទ្ធិលើបំណុលដែលទាមទារឱ្យប្រគល់ នូវវត្ថុដែលជាកម្មវត្ថុនៃវិវាទ | មានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិបាន ឬនឹងមានការលំបាកយ៉ាងខ្លាំង ក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ ( មាត្រា ៥៤៨ កថាខណ្ឌទី១ ) |
| ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ ឋានៈជាបណ្ដោះអាសន្ន (មាត្រា ៥៣១ ចំណុច គ) | ការចាត់ចែងជាបណ្ដោះអាសន្ន ដែលកំណត់ឋានៈជាបណ្ដោះអាសន្ន | សិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលមានវិវាទ | ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាត ធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដែលនឹងកើត ឡើងដល់ម្ចាស់ បំណុល ចំពោះទំនាក់ទំនងគតិយុត្ត ដែលមានវិវាទ ( មាត្រា ៥៤៨ កថាខណ្ឌទី២ ) |

| ប្រភេទនៃការរក្សារការពារ | វិធីចេញដីកាសម្រេច | | វិធីអនុវត្តដីកាសម្រេច | អានុភាពនៃការអនុវត្ត | វិធានការចំពោះការអនុវត្ត ដោយបង្ខំ |
| --- | --- | --- | --- | --- | --- |
| ការរឹបអូសជាបណ្តោះអាសន្ន (មាត្រា ៥៣១ ចំណុច ក) | តុលាការត្រូវ កំណត់ អំពីចំនួនទឹកប្រាក់រំដោះ ពីការរឹបអូសជាបណ្តោះអាសន្ន ( មាត្រ ៥៤៧) | | តាមរបៀបចុះបញ្ជី អំពីការរឹបអូសជាបណ្តោះអាសន្ន ( មាត្រា ៥៦៧ កថាខណ្ឌ ទី១) | ការចាត់ចែងទ្រព្យសម្បត្តិ ចំពោះការរឹបអូសជាបណ្តោះអាសន្នគ្មានអានុភាពឡើយ ចំពោះនីតិវិធីនៃការអនុវត្ត ដោយបង្ខំ | ម្ចាស់បំណុលត្រូវដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ដើម្បីចាប់ផ្តើមអនុវត្តនីតិវិធីនៃការអនុវត្ត ដោយបង្ខំ |
| | | តុលាការមិនចាំបាច់កំណត់ជាក់លាក់អំពីកម្មវត្ថុ ( មាត្រា ៥៤៦) | នៅក្នុងពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុ ត្រូវសរសេរអំពី ទីកន្លែងដែលចលនវត្ថុដែលត្រូវរឹបអូសនោះស្ថិតនៅ ។ ( មាត្រា ៥៦៥ កថាខណ្ឌ ទី៤ មាត្រា ៣៨៤ កថាខណ្ឌទី២) ។<br>ទាមរបៀបកាន់កាប់ វត្ថុដែលជាកម្មវត្ថុ ដោយអាជ្ញាសាលា ( មាត្រា ៥៦៥ កថាខណ្ឌទី១) | ការចាត់ចែងទ្រព្យសម្បត្តិ ចំពោះការរឹបអូសជាបណ្តោះអាសន្នគ្មានអានុភាពឡើយ ចំពោះនីតិវិធីនៃការអនុវត្ត ដោយបង្ខំ | |
| | | | តាមរបៀបដែលតុលាការអនុវត្តរក្សាការពារចេញដីកាសម្រេចដែលហាមឃាត់មិនឱ្យកូន បំណុលទីពាសងទៅកូនបំណុល ( មាត្រា ៥៦៦ កថាខណ្ឌទី១) | ការចាត់ចែងទ្រព្យសម្បត្តិ ចំពោះការរឹបអូសជាបណ្តោះអាសន្នគ្មានអនុភាពឡើយ ចំពោះនីតិវិធីនៃការអនុវត្ត ដោយបង្ខំ | |
| ការចាត់ចែងជាបណ្តោះអាសន្ន ចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ (មាត្រា ៥៣១ ចំណុច ខ) | ដីកាសម្រេចហាមឃាត់មិនឱ្យធ្វើការផ្ទេរការកាន់កាប់វត្ថុ និងបង្គាប់ឱ្យប្រគល់វត្ថុទៅអាជ្ញាសាលា ដោយដកហូតការ កាន់កាប់នោះ ហើយ បង្គាប់ឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុនោះ និង បង្គាប់ឱ្យអាជ្ញា សាលាត្រូវប្រកាសជា សាធារណៈថា កូនបំណុលត្រូវបានហាមឃាត់ ការផ្ទេរការកាន់កាប់វត្ថុនោះ ( មាត្រា ៥៧១ កថាខណ្ឌទី១) | | តាមរបៀបកាន់កាប់វត្ថុដែលជាកម្មវត្ថុ ដោយអាជ្ញាសាលាចំពោះកម្មវត្ថុ ជាដើម ( មាត្រា ៥៧១) | ការផ្ទេរការកាន់កាប់ ចំពោះការចាត់ចែងជាបណ្តោះអាសន្នគ្មានអានុភាពឡើយ ចំពោះ នីតិវិធីនៃការអនុវត្តដោយបង្ខំទេ ដូចេះ កូនបំណុលនៃការអនុវត្តត្រូវបានចង ( មាត្រា ៥៧១) | ការអនុវត្ត ដោយបង្ខំអាចអនុវត្ត ចំពោះបុគ្គល ផ្សេងក្រៅពីភាគីដែលត្រូវបានសរសេរលើ លិខិត អនុវត្ត ដោយមានរូបមន្តអនុវត្តពិសេស ( មាត្រា ៥៦៤ មាត្រា ៣៥៦ កថាខណ្ឌទី២) |
| ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ ឋានៈជាបណ្តោះអាសន្ន (មាត្រា ៥៣១ ចំណុច គ) | ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នមិនអាចចេញបានឡើយ បើមិន បានឆ្លងកាត់តាមកាលបរិច្ឆេទនៃការទាញហេតុផលដោយ ផ្ទាល់មាត់ ឬ តាមកាលបរិច្ឆេទនៃការសួរដែលកូនបំណុលអាចចូល រួមបាន មាត្រា ៥៤៨ កថាខណ្ឌទី៤ ។<br>ប៉ុន្តែ ករណីលើកលែងគឺ មាត្រា ៥៤៨ កថាខណ្ឌទី៤ វាក្យខណ្ឌ | | តាមរបៀបដូចគ្នាទៅនឹងរបៀបនៃការអនុវត្ត ដោយបង្ខំ ដោយ ផ្អែកលើ សាលក្រមនៃបណ្តឹងអង្គសេចក្តី | កំណត់ឋានៈជាបណ្តោះអាសន្ន លក្ខខ័ណ្ឌ ឬសិទ្ធិ ហើយម្ចាស់បំណុលអាចទទួលនូវការពេញចិត្តជាបណ្តោះអាសន្ន | អ្នកមិនចាំបាច់អនុវត្តដោយបង្ខំ ដែលត្រូវបានធ្វើនៅក្នុងការអនុវត្តនៃការចាត់ចែងជាបណ្តោះអាសន្នទេ |

# ប្រាតភោគ និង ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន

| | គោលបំណង | អ្នកដាក់ប្រាតិភោគ | ប្រភេទនៃរឿងក្ដី | ការសម្រេចសេចក្ដី (ត្រូវតែធ្វើ)? | ចំនួនទឹកប្រាក់ដែលត្រូវដាក់ |
|---|---|---|---|---|---|
| *ប្រាតិភោគ (មាត្រា ៥៤២)* | ដើម្បីធានានូវសំណងនៃការខូចខាតដែលកើតមានឡើងចំពោះ កូនបំណុល ដោយសារកំហុសដីកាសម្រេ រក្សាការពារ សូមមើលគូឡោនប្រអប់ចុងក្រោយនៅក្នុងជួរនេះ | ម្ចាស់បំណុល | ទាំងអស់<br>(-ការរឹបអូសជាបណ្ដោះ អាសន្ន។<br>- ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ។<br>- ឬ ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន) | ការសម្រេចសេចក្ដី<br>ដីកាសម្រេចអាចធ្វើ ដោយ*អោយដាក់*ប្រាតិភោគ ឬ*មិនអោយដាក់*ប្រាតិភោគ (មាត្រា ៥៤២) | តុលាការគប្បីធ្វើការប៉ាន់ស្មាន អំពីចំនួនទឹកប្រាក់នៃការខូចខាត។<br>ចំណុចខាងក្រោម គប្បីយកមកពិចារណា<br>- ប្រភេទ និង ចំនួនទឹកប្រាក់នៃសិទ្ធិដែលត្រូវបានរក្សាការពារ<br>- ប្រភេទនៃការរក្សាការពារ<br>- ប្រភេទ និង ចំនួនទឹកប្រាក់នៃកម្មវត្ថុដែលត្រូវរក្សាការពារ<br>- មុខរបរ និងស្ថានភាពសេដ្ឋកិច្ចរបស់កូនបំណុល<br>- កម្រិតនៃការធ្វើសេចក្ដីបញ្ជាក់តំបូង |
| *ទឹកប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន (មាត្រា ៥៤៧)* | ដើម្បីទទួលបាននូវទ្រព្យដែលត្រូវរួចផុតពីការរឹបអូសជាបណ្ដោះអាសន្ន<br>ជំនួសទ្រព្យដែលត្រូវរឹបអូស | កូនបំណុល | មានតែចំពោះករណីនៃការរឹបអូសជាបណ្ដោះអាសន្នប៉ុណ្ណោះ | ត្រូវតែកំណត់<br>តុលាការត្រូវកំណត់ចំនួនទឹកប្រាក់នៅក្នុងដីកាសម្រេច (មាត្រា ៥៤៧) | ចំនួនទឹកប្រាក់នៃទ្រព្យសម្បត្តិដែលត្រូវបានរឹបអូសជាបណ្ដោះ អាសន្ន ឬ ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលត្រូវបានរក្សាការពារ |

| | ពេលវេលាដែលបង្គាប់អោយដាក់ប្រាតិទោគ | ប្រាតិទោគដែលត្រូវដាក់ | តុលាការដែលត្រូវដាក់ប្រាតិទោគ | អានុភាពនៃការដាក់ប្រាតិទោគ | ករណីដែលអ្នកដាក់ប្រាតិទោគអាចទាមទារ*អោយប្រគល់*ប្រាតិទោគត្រឡប់មកវិញ | ករណីអ្នកទទួលផលប្រយោជន៍នីវីប្រាតិទោគអាចទាមទារ*អោយប្រគល់*ប្រាតិទោគត្រឡប់មកវិញ |
|---|---|---|---|---|---|---|
| *ប្រាតិភោគ (មាត្រា ៥៤២)* | តុលាការអាចបង្គាប់អោយដាក់ប្រាតិភោគមុនចេញដីកាសម្រេចរក្សាការពារ ឬ បង្គាប់អោយដាក់ នៅក្នុងដីកាសម្រេចរក្សាការពារតែម្តង (ជាលក្ខខណ្ឌមួយដើម្បីអនុវត្តដីកាសម្រេច) | ប្រាក់ ឬ ឧបករណ៍អាចជួញដូរបាន | តុលាការដែលបង្គាប់អោយដាក់ប្រាតិភោគ ឬ តុលាការអនុវត្តការរក្សាការពារ (មាត្រា ៥៣៦) | តុលាការត្រូវចេញដីកាសម្រេច និង អនុវត្តដីកាសម្រេច | ហេតុដែលត្រូវដាក់ប្រាតិភោគត្រូវបានរលត់ (មាត្រា ៧៣ កថាខណ្ឌទី២)<br>ឧទាហរណ៍ ម្ចាស់បំណុលឈ្នះបណ្តឹងអង្គសេចក្តី<br><br>ម្ចាស់បំណុលបានទទួលការយល់ព្រម ពីកូនបំណុល (មាត្រា ៧៣ កថាខណ្ឌទី៣)<br>កូនបំណុលមិនបានប្រើសិទ្ធិក្នុងអំឡុង ពេល ២សប្តាហ៍ (មាត្រា ៧៣ កថាខណ្ឌទី៤) | ក្នុងករណីកូនបំណុលទទួលនូវការខូចខាតដែលបណ្តាលមកពីកំហុសនៃដីកាសម្រេច កូនបំណុលអាចដាក់ពាក្យបណ្តឹងទាមទារសំណងការខូចខាតពីម្ចាស់បំណុលបាន។ ហើយក្នុងករណីដែលកូនបំណុលឈ្នះក្តី ហើយសាលក្រមបានចូលជាស្ថាពរ កូនបំណុលអាចទទួលការពេញចិត្ត ដោយខ្លួនមានសិទ្ធិ ជាអាទិភាពទៅលើ ម្ចាស់បំណុលផ្សេងទៀត យោងតាមមាត្រា ៧២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ |
| *ទឹកប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន (មាត្រា ៥៤៧)* | នៅក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន | ប្រាក់រំដោះ (មាត្រា ៥៤៧) | តុលាការដែលចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬ តុលាការអនុវត្តការរក្សាការពារ (មាត្រា ៥៤៧ កថាខណ្ឌទី២) | តុលាការត្រូវលុបចោលការអនុវត្ត ការរឹបអូសជាបណ្តោះអាសន្ន (មាត្រា ៥៦៩ កថាខណ្ឌទី១) | ម្ចាស់បំណុលដកពាក្យសុំអោយចេញដីកាសម្រេចរឹបអូសជាបណ្តោះ អាសន្ន ឬ ដកពាក្យសុំអោយអនុវត្តដីកាសម្រេច។ ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវបានលុបចោលដោយយោងតាម ពាក្យសុំតវ៉ា (មាត្រា ៥៥០) ពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារ (មាត្រា ៥៥៧ ៥៥៨ និង មាត្រា ៥៥៩) ឬ បណ្តឹងជំទាស់ (មាត្រា ៥៦១) | ក្នុងករណីម្ចាស់បំណុលឈ្នះបណ្តឹងអង្គសេចក្តី ហើយសាលក្រមបានចូល ជាស្ថាពរ ម្ចាស់បំណុលអាចរឹបអូសសិទ្ធិលើបំណុល ដើម្បីយកប្រាក់ដែលបានដាក់ប្រាតិភោគនោះត្រឡប់មកវិញ ដោយផ្អែកលើ សាលក្រមចុងក្រោយ គឺថា ជាលិខិតអនុវត្ត (មាត្រា ៣៥០ និង មាត្រា៤០២) ។ម្យ៉ាងវិញទៀត ម្ចាស់បំណុលទទួលនូវការពេញចិត្ត តាមរបៀបនៃការអនុវត្តចំពោះ សិទ្ធិលើបំណុល (មាត្រា ៤០២)។ |

# បណ្តឹងតវ៉ា និង បណ្តឹងជំទាស់ ជាអាទិ៍

| | កម្មវត្ថុ | អ្នកដែលដាក់ពាក្យសុំ | មូលហេតុនៃការដាក់ពាក្យសុំ |
|---|---|---|---|
| *ការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ* (មាត្រា ៥៥០) | ដីកាសម្រេចរក្សាការពារ<br>x ដីកាសម្រេចលើកចោលពាក្យសុំ<br>ដីកាសម្រេចរក្សាការពារ | កូនបំណុល | ដីកាសម្រេចរក្សាការពារមិនត្រឹមត្រូវ |
| *បណ្តឹងជំទាស់ ចំពោះ សេចក្តីសម្រេចដែលលើកចោលពាក្យសុំអោយចេញដីកាសម្រេចរក្សាការពារ* (មាត្រា ៥៤២) | ដីកាសម្រេចលើកចោលពាក្យសុំដីកាសម្រេចរក្សាការពារ (មាត្រា ៥៤៥) | ម្ចាស់បំណុល | ដីកាសម្រេចរក្សាការពារមិនត្រឹមត្រូវ |
| *ការលុបចោលដីកាសម្រេចរក្សាការពារ* (មាត្រា ៥៥៧ ៥៥៨ និងមាត្រា ៥៥៩) | ដីកាសម្រេចរក្សាការពារ<br>x ដីកាសម្រេចលើកចោលពាក្យសុំដីកាសម្រេចរក្សាការពារ | កូនបំណុល | ដីកាសម្រេចគឺត្រឹមត្រូវ ប៉ុន្តែស្ថានភាពបានផ្លាស់ប្តូរ បន្ទាប់ពីចេញដីកាសម្រេចរក្សាការពារនោះ |
| *បណ្តឹងជំទាស់* (មាត្រា ៥៦១) | ដីកាសម្រេចដែលទាក់ទងនឹងពាក្យសុំតវ៉ា ឬពាក្យសុំលុបចោលដីកាសម្រេច ជាអាទិ៍ (មាត្រា៥៦១) | ម្ចាស់បំណុល ឬ កូនបំណុល | ដីកាសម្រេចមិនត្រឹមត្រូវ |

| | តុលាការដោះស្រាយបណ្ដឹង | នីតិវិធី | តើភាគីអាចដាក់បណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ចំពោះដីកាសម្រេចម្ដងទៀតបានដែរឬទេ? |
|---|---|---|---|
| *ការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ (មាត្រា ៥៥០)* | តុលាការដែលចេញដីកាសម្រេចដើម (មាត្រា ៥៥០) | តុលាការត្រូវធ្វើការទាញហេតុផល ដោយផ្ទាល់មាត់ ឬ ធ្វើការសួរភាគីទាំងសងខាងដែលអាចចូលរួមបាន (មាត្រា ៥៥២)<br>តុលាការត្រូវសម្រេចថ្ងៃ បញ្ចប់ការវិនិច្ឆ័យ ដោយកំណត់អំឡុងពេលអនុគ្រោះដ៏សមរម្យ (មាត្រា ៥៥៣) | បាន (មាត្រា ៥៦១ កថាខណ្ឌទី១ ចំណុច ក)<br>ករណីលើកលែង: ដីកាសម្រេចអំពី ពាក្យសុំតវ៉ាដែលធ្វើឡើង ដោយតុលាការនៃបណ្ដឹងជំទាស់ (មាត្រា ៥៦១ កថាខណ្ឌទី១ វាក្យខណ្ឌ) |
| *បណ្ដឹងជំទាស់ ចំពោះ សេចក្ដីសម្រេចដែលលើកចោលពាក្យសុំអោយចេញដីកាសម្រេចរក្សាការពារ (មាត្រា ៥៤៤)* | តុលាការនៃបណ្ដឹងជំទាស់ | ដូចនីតិវិធីដែលដីកាសម្រេចដើមត្រូវបានចេញ (មាត្រា ៣០៤ កថាខណ្ឌទី១ មាត្រា ២៧៣)<br>ការសួរភាគី (មាត្រា ១១៤ កថាខណ្ឌទី២) ការសម្រេចសេចក្ដីចំពោះ នីតិវិធីការរក្សាការពារ (មាត្រា ៥៣៥ កថាខណ្ឌ ទី១ មាត្រា ១១៤ កថាខណ្ឌទី១ វាក្យខណ្ឌ) | ទេ (មាត្រា ២៥៩ កថាខណ្ឌទី៣)<br>ប៉ុន្តែមានករណីលើកលែងមួយចំនួន សូមមើលនៅក្នុងតារាង |
| *ការលុបចោលដីកាសម្រេចរក្សាការពារ (មាត្រា ៥៥៧ ៥៥៨ និងមាត្រា ៥៥៩)* | តុលាការដែលចេញដីកាសម្រេចដើម (មាត្រា ៥៥៧ មាត្រា ៥៥៨ មាត្រា ៥៥៩) ឬ<br>តុលាការធ្វើការវិនិច្ឆ័យលើ បណ្ដឹងអង្គសេចក្ដី (មាត្រា ៥៥៨ មាត្រា៥៥៩) | តុលាការត្រូវធ្វើការទាញហេតុផល ដោយផ្ទាល់មាត់ ឬ ធ្វើការសួរភាគី ទាំងសង ខាងដែលអាចចូលរួម បាន (មាត្រា ៥៦០ មាត្រា ៥៥២)<br>តុលាការត្រូវសម្រេចថ្ងៃ បញ្ចប់ការវិនិច្ឆ័យ ដោយកំណត់អំឡុងពេលអនុគ្រោះដ៏សមរម្យ (មាត្រា ៥៦០ មាត្រា ៥៥៣) | បាន (មាត្រា ៥៦១ កថាខណ្ឌទី១ ចំណុច ក) |
| *បណ្ដឹងជំទាស់ (មាត្រា ៥៦១)* | តុលាការនៃបណ្ដឹងជំទាស់ | តុលាការត្រូវធ្វើការទាញហេតុផល ដោយផ្ទាល់មាត់ ឬ ធ្វើការសួរភាគីទាំងសង ខាងដែលអាចចូលរួម បាន (មាត្រា ៥៦១ កថាខណ្ឌទី៣ មាត្រា ៥៥២)។<br>តុលាការត្រូវសម្រេចថ្ងៃបញ្ចប់ការវិនិច្ឆ័យ ដោយកំណត់អំឡុងពេលអនុគ្រោះដ៏សមរម្យ (មាត្រា ៥៦១ កថាខណ្ឌទី៣ មាត្រា ៥៥៣) | ទេ (មាត្រា ២៥៩ កថាខណ្ឌទី៣)<br>ប៉ុន្តែមានករណីលើកលែងមួយចំនួន សូមមើលនៅក្នុងតារាង |

# លំហូរនីតិវិធីនៃពាក្យសុំខួចាស្រ័យចំពោះការចាត់ចែងរក្សាការពារ

កម្រិតតែករណីដែលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារត្រូវបានដាក់ទៅសាលាដំបូង

មិនរាប់បញ្ចូលនីតិវិធីនៃការលុបចោលដីកាសម្រេចរក្សាការពារ ( មាត្រា ៥៥៧ ដល់ មាត្រា ៥៦០)



# カンボジアにおける民事保全の実状

ＪＩＣＡ長期派遣専門家
前　田　優　太

## １　はじめに

カンボジアにおいては，日本の支援の下で民事訴訟法（以下，カンボジアの民事訴訟法を単に「法」という。）が作られ，民事保全も法の中に規定されている（法５３０条ないし５７１条)。２０１６年にカンボジアの裁判所が新規に受理した民事保全事件の総数は２１１６件であり[1]，民事保全はカンボジアにおいても実際に使われているが，カンボジア全土で法が適用されてから１０年以上が経過し，実務上，立法当時想定されていなかったものも含めた問題点が出てきている。条文解釈上の主な論点については法務省法務総合研究所国際協力部のホームページ上にある「民事保全頻出質問集（２００９年)」[2](以下「質問集」という。）で示されているので，本稿では，まずカンボジアにおける民事保全の制度を概観した後で，日本との運用上の違いや実務上発生している問題点について述べることとする。

## ２　制度概観

カンボジアにおける民事保全の概要は以下のとおりである。執行債務者の財産の現状が変更されることによって，強制執行ができなくなり若しくは著しく困難になるおそれがあるとき，又は権利関係につき争いがあることによって，当事者の一方の地位に著しい損害若しくは急迫な危険を生ずるおそれがあるときは，自己の権利を保全しようと思う者は，他の法律に特別の定めがある場合のほか,保全処分を求めることができる（法５３０条)。保全処分には，仮差押え，係争物に関する仮処分及び仮の地位を定める仮処分がある（法５３１条)。仮差押えとは，金銭の支払を目的とする債権の強制執行を保全するために債務者の財産の処分を制限する処分である（同条１号)。係争物に関する仮処分とは，係争物の現状の変更により，債権者が権利を実行することができなくなるおそれがあるとき，又は権利を実行するのに著しい困難を生ずるおそれがあるときにその係争物の現状を維持させる処分である（同条２号)。仮の地位を定める仮処分とは，争いがある法律関係について債権者に生ずる著しい損害又は急迫の危険を避けるために必要があるときに判決の確定までの仮の状態を定める処分である（同条３号)。仮差押決定は，金銭の支払を目的とする債権について，強制執行をすることができなくなるおそれがあるとき，又は強制執行をするのに著しい困難を生ずるおそれがあるときに発することができ（法５４５条１項)，決定において仮差押えの執行の取消しを得るために債務者が寄託すべき金銭（仮差押解放

[1] 内山淳ほか「カンボジア現地調査報告（２）～全国の始審裁判所の実情について～」法律のひろば２０１９年２月号４３頁
[2] http://www.moj.go.jp/content/000032474.pdf

金）の額を定めなければならない（法５４７条１項）。係争物に関する仮処分決定は，係争物の現状の変更により，債権者が権利を実行することができなくなるおそれがあるとき，又は権利を実行するのに著しい困難を生ずるおそれがあるときに発することができる（法５４８条１項）。仮の地位を定める仮処分決定は，争いがある法律関係について債権者に生ずる著しい損害又は急迫の危険を避けるためこれを必要とするときに発することができ（同条２項），決定にあたっては特別の事情のない限り口頭弁論又は債務者が立ち会うことができる審尋の期日を経ることが必要である（同条４項）。仮処分においては，裁判所は，仮処分決定の申立ての目的を達するために必要な限度で，債務者に対し一定の行為を命じ，若しくは禁止し，若しくは給付を命じ，又は保管人に目的物を保管させる処分その他の処分をすることができる（法５４９条）。保全決定に対しては，債務者は，その決定をした裁判所に異議を申し立てることができ（法５５０条），本案の訴えの不提起や事情の変更等を理由とする保全取消の制度も定められている（法５５７条ないし５５９条）。保全決定に対する異議や保全決定の取消しの申立てについての決定等に対しては抗告することができる（法５６１条１項）。保全執行については，総論（法５６２条ないし５６４条）のほか，各論として，動産（法５６５条），債権その他の財産権（法５６６条），不動産（法５６７条）及び船舶（法５６８条）に対する仮差押えの執行並びに仮処分の執行[3]（法５７０条）について規定がおかれている。

以上のとおり，カンボジアにおける民事保全の規定は，日本の民事保全法の規定と似たものとなっている。

### ３　日本との運用上の違い

しかしながら，法律上は日本と同じような規定があるにもかかわらず，カンボジアの実務において日本の実務とは異なった運用がされている点がある。その主なものとして，ここでは，保全決定における担保の要否，保全執行の申立ての要否及び不動産に対する民事保全の効力を取り上げる。

（１）保全決定における担保の要否

日本においては，保全命令は，担保を立てさせて，若しくは相当と認める一定の期間内に担保を立てさせることを保全執行の実施の条件として，又は担保を立てさせないで発することができる（日本民事保全法１４条）。ここでいう担保は，違法・不当な保全命令によって債務者が被る可能性のある損害を担保するものであるが，実際上はこれに加えて，濫用的な民事保全の申立てを抑止する機能や，債務者審尋を経ることなく迅速な保全命令を発することを正当化する機能もあるとされている[4]。もっとも，実務上は，賃金仮払いの仮処分等の例外的な場合を除き，担保を立てさせないで保全命令を発令することはされていない。それは，保全命令の債務者が担保につき他の債権者に先立ち弁

---

3　ただし「仮処分の執行は，仮差押えの執行又は強制執行に準じて行う。」と規定されているのみである。
4　須藤典明ほか「民事保全　三訂版」（以下「民事保全三訂版」という。）６７頁，瀬木比呂志「民事訴訟法　新訂版」７６頁

済を受ける権利を有し（日本民事保全法４条２項，日本民事訴訟法７７条），権利行使が容易だからとされている[5]。

カンボジアにおいても，保全決定は，担保を立てさせて，又は担保を立てさせないですることができる（法５４２条）。すなわち，保全決定を出す際に担保を立てさせるか否かについては，日本と同様，裁判所の裁量に委ねられている。前記のとおり，カンボジアの民事保全に関する規定が日本と似ていることや，実際に口頭弁論等を経ないケースでは申立てから数日程度で決定が出ていること[6]等からすれば，カンボジアにおいても民事保全における担保は日本と同様の機能を果たすものと思われる。しかしながら，カンボジアにおいては，日本とは逆に，実務上保全決定を出す際に担保を立てさせることはほとんどない。その理由としては次のようなことが考えられる。まず，カンボジアにおいては，仮差押え等であれば債務者に対する権利侵害は軽微であり担保を要求するほどでもないとの意見や，保全決定を出す際に担保を要求することにより当事者（国民）の裁判所に対するイメージが悪化することを気にする意見を持つ裁判官が少なからず存在する。また，保全決定の担保を立てるには，当事者が担保を立てるべきことを命じた裁判所に金銭等を寄託する方法によるべきところ（法５３６条），多くの裁判所において寄託された金銭の管理方法が定められていないなど，担保の受入れ先となる裁判所内において担保の受入手続が十分に整っていない[7]。このようなことが上記のような実務に影響しているものと思われる。

（２）保全執行の申立ての要否

日本においては，民事保全の執行は申立てにより行われ（日本民事保全法２条２項），その申立ては書面でしなければならない（日本民事保全規則１条６号）。しかし，一定の方法による保全執行については，保全決定の申立てと同時に保全執行の申立てをすることも可能であり（日本民事保全規則３１条但書），実務上も，保全命令を発した裁判所が執行機関となる事案の多くは，保全決定の申立てと同時にこれが発令されることを停止条件とする保全執行の申立てがされているものと解されており，新たに保全執行の申立ては不要であるとされている[8]。

カンボジアにおいても，日本と同様，民事保全の執行は申立てにより行われ（法５３２条２項），その申立ては書面でしなければならない（法５３４条６号）。しかし，法には上述した日本民事保全規則３１条但書のように明文上保全決定の申立てと同時に保全執行の申立てをすることを認めたと解される条文は存在しない。法の解釈上そのような取扱いを認める余地はあるが[9]，現在の実務では認められておらず，債権者は，保全決定の送達を受けた後２週間以内に保全執行の申立てを改めてする必要がある。その結果，

5　民事保全三訂版６９頁
6　内山淳「カンボジアの司法～始審裁判所～」ＩＣＤ ＮＥＷＳ第７３号４８頁，内山淳ほか「カンボジア現地報告（３）～全国の始審裁判所の実情について～」法律のひろば２０１９年３月号掲載予定
7　内山淳ほか・上記注６の論文
8　民事保全三訂版２０４頁
9　質問集３５頁

執行期間の起算点をいつにするのか，執行期間の中断を認めるのか，執行期間内に何をすればよいのかなどといった問題が日常的に起こっている。

（３）不動産に対する民事保全の効力

日本において，不動産に対する仮差押えや処分禁止の仮処分の執行として登記がされた場合，その効力はいわゆる相対効である（仮差押えにつき，日本民事執行法５９条２項，３項。処分禁止の仮処分につき，日本民事保全法５８条１項）。例えば所有権移転登記請求権を被保全権利とする処分禁止の仮処分につき，債務者所有の不動産に対して処分禁止の仮処分の登記がされた後に債務者が第三者に当該不動産の所有権を譲渡した場合でも，当該譲渡は有効であり，第三者は自らに対する所有権移転登記をすることもできる。ただ，登記にかかる所有権の取得を債権者に対抗することができないにすぎない。

カンボジアにおいても，法は日本と同じく相対効の考え方に立っているが[10]，日本と異なり，相対効であることを明示した条文は，仮差押えの後に仮処分の執行等ができることを前提としたいくつかの条文（法４３１条３項等）が存在するのみであり，処分禁止の仮処分の効力に関する条文は置かれていない。法に処分禁止の仮処分の効力に関する条文が置かれなかったのは，法の起草の段階ではまだカンボジアにおいて登記制度が整備されていなかったという事情に起因するものと推察される。加えて，法改正をするということは従前の法律にミスがあったことを認めることになるとの理由で法改正に消極的な意見が司法省の中には根強くあるため，相対効であることを明示するような条文を追加するような法改正も進まない。そうすると，条文の文言を重視するカンボジアにおいては，民事保全の登記に後れる登記申請を受け付けるべきか否かが問題となる。なお，不動産に関する合意による所有権の移転は，登記をしなければ効力を生じないので（カンボジア民法１３５条），民事保全の登記に後れる登記申請を受け付けないという見解を採った場合，事実上仮処分の対象となった不動産の権利移転そのものが大幅に制限されることになる[11]。

この点に関するカンボジアの実務は一定ではない。すなわち，相対効に沿った運用がされるか，具体的には民事保全の登記がされた土地の所有権移転登記申請を受け付けるか否か，については国全体で統一した運用がなされておらず，個々の登記官によって運用が分かれているというのが現状である。傾向としては，プノンペンではそのような登記申請を受け付けてもらえることが多く，地方部だと受け付けてもらえない，言い換えればいったん民事保全の登記がされるとそれが抹消されるまでの間所有権移転等の登記申請を受け付けないという運用がされていることが多いようである。

なお，司法省と国土管理都市計画建設省（以下，法令の引用部分も含めて「国土省」という。）の間の２０１０年７月１５日付け「民事訴訟関連不動産登記共同省令ワーク

[10] 磯井美葉「カンボジアの不動産登記について」ＩＣＤ ＮＥＷＳ第６０号３３頁，質問集３８頁

[11] 相続のように，合意によらない所有権の移転においては，登記は効力要件ではなく対抗要件（カンボジア民法１３４条１項）にすぎないので，登記申請が受理されない場合でも権利の移転は可能である。

ショップにおける司法省・国土省間の合意書」（以下「本件合意書」という。）第１項では，「本共同省令は差押え，仮差押え，仮処分の効力を相対効としつつも，カンボジアの現状に鑑み，管轄登記所は，裁判所からの嘱託によるものを除き，これらに後れる登記申請を不受理とする見解を採用する」と規定されている。この規定による帰結は法の趣旨とは異なるが[12]，本件合意書の位置付けや法的効力については必ずしも明らかではない。上記のような地方部の運用も，本件合意書に従っているというよりは，単に登記官が法を知らないことが原因のようである。すなわち，プノンペンであれば法を学ぶ機会が多く，登記官が法を知っていることが多いので，法の趣旨に沿った運用がされることが多いが，地方部では法を学ぶ機会もなく，登記官が法を知らないので，法の趣旨とは異なった運用がされることが多い[13,14]，というのが現在のカンボジアの実状である。

もっとも，本件合意書第１項後段によれば，「本共同省令は司法省・国土省共同起草班が不動産登記法を起草するまでの間，暫定適用されるものである。」とされており，第３項には，「民法関連不動産登記共同省令起草後，司法省・国土省共同起草班は，日本側ワーキンググループの助力を得ながら，差押え，仮差押え，仮処分の効力を相対効とし，さらに管轄登記所は，これらに後れる登記申請を受理する見解を前提とした『民法・民事訴訟法関連不動産登記法』の起草を開始する」と規定されているので[15]，将来的には，カンボジアにおいても，日本と同様に相対効を前提とした立法がされ，全土でそれに沿った運用がなされることが想定される。

### ４　実務上発生している問題点

カンボジアにおいては，上記のとおり日本と異なる運用がされている点があるにとどまらず，前記のとおり法を知らない法律実務家もまだまだ存在するため，法に反するような運用がなされることもある。その内容につき細かい点まで挙げれば多岐にわたるが，本稿では特に大きいと思われる点，すなわち仮差押えと仮処分の区別，保全すべき権利及び保全の必要性について述べる。

（１）仮差押えと仮処分の区別

カンボジアにおいても，日本と同様，仮差押えと仮処分は保全すべき権利が金銭債権か否かで区別される（法５３１条）。しかしながら，カンボジアにおいては，地方部を

---

12　ただし，この規定自体は法の明文に反するものではない。

13　本件合意書においても裁判所からの嘱託に基づく登記申請は受理されるので，不動産に対する仮差押えや処分禁止の仮処分の執行（法５７０条，５６７条）の場面では登記申請が受理されるはずであるが，現在のカンボジアの地方部ではそのような登記申請も受け付けてもらえないことが多いようである。

14　実務に携わる者が法律を知らないというのは必ずしも地方部に限ったことではない。筆者はワーキンググループ等でプノンペン及びその周辺の法律実務家と日々接しているが，彼らの中にも仮差押登記がされている土地を第三者に譲渡すること自体ができないと認識している法律実務家は存在する。

15　現在ＪＩＣＡで行われている「民法・民事訴訟法運用改善プロジェクト」では，あるべき成果の一つとして民法・民事訴訟法の関連法案の起草が挙げられている。現在，長期派遣専門家が司法省と国土省と共同で毎週ワーキンググループを開催し，民法関連不動産登記共同省令の内容を含めた形で不動産登記法を起草できるよう，法案の検討を進めている。

中心に，保全すべき権利を金銭債権とする処分禁止の仮処分の申立てがなされ，裁判所もそれを認めている事案が少なからず存在する。これは，「債務者所有の〇〇の不動産を仮に差し押さえる。」というような仮差押えの主文では決定の効果が不明確なので，「〇〇の不動産について，売却，賃貸，質入れ，贈与及び抵当権設定を仮に禁止する。」というように禁止される行為を具体的に主文上に記載したいという実務上の要請や[16, 17]，仮差押えと仮処分の要件の区別をせずに申立てがあった方を認めるという裁判官の考えに基づくものと思われるが，明らかに法律実務家の法の理解不足に起因するものである。前述した登記官のケースも含めて，カンボジアの特に地方部における法の普及については，まだまだ道半ばである。

（２）保全すべき権利

カンボジアにおいても，保全すべき権利の疎明がなされなければ保全決定を出すことはできない。しかしながら，カンボジアにおいては，保全すべき権利は何か，保全すべき権利の疎明はされているのか，という点を十分に判断していないのではないかとみられる保全決定が散見される。例えば，債務者ではない第三者を名宛人とする処分禁止の仮処分，債務者の出国を禁止する旨の仮処分，債務者に対して債権者との別居を命じる仮処分[18]，登記義務者の意思表示がないにもかかわらず登記官に対して所有権移転登記を命じる仮処分，行政に対して建築許可を命じる仮処分[19]などが実際に出ている。これは必ずしも地方部に限ったことではなく，実際にも上記の仮処分のいくつかはプノンペン始審裁判所で出されている。これらを見る限りにおいては，裁判所において保全すべき権利の存否についての審査が必要であるということがカンボジアの裁判官に十分に理解されていないように思われる。

（３）保全の必要性

カンボジアにおいても，保全の必要性がなければ保全決定を出すことはできない（法５４５条１項，５４８条１項，２項）。しかしながら，カンボジアにおいては，保全の必要性を十分に審査していないのではないかと思われる保全決定が散見される。例えば，金銭債権を保全するための債務者所有の不動産に対する明渡断行の仮処分が出たり，法人の営業を禁止する仮処分，法人の全ての財産に対する仮差押え，債権者使用型の占有移転禁止の仮処分がそれぞれ簡単に，しかも無担保で出されている。このような実務の背景には，申立人が求めているのだから保全の必要性を肯定するという考えがあるように思われ，保全の必要性を裁判所が審査することの必要性についてはカンボジアの裁判官に十分に浸透していないように思われる。

---

16 これらの主文例は，前者は仮差押決定，後者は処分禁止の仮処分決定の主文としてカンボジアの裁判所で実際に出されたものである。その適否については本稿では判断しない。

17 本文中で挙げた二種類の主文例を併記する形で申立てがなされ，そのような決定が出ることもある。これについて，裁判所は，仮差押えと処分禁止の仮処分の併合として扱っているようである。

18 この決定においては，債権者が債務者に対して同居している住居からの退去を求めた部分は却下されている。そのため，決定によっても，現住居にどちらが残ることができるかについては不明である。

19 カンボジアの実務上，裁判所が行政に対して建築許可を命じることはできないと考えられている。

## 5　おわりに

以上のとおり，カンボジアにおいても民事保全は使われているが，その実際の運用については，起草当時想定されていたことや日本における運用と異なっている点も存在する。起草者の想定や日本における運用とカンボジアにおける運用が異なっていること自体は決して悪いことではないが，この中には，法律実務家の法の理解不足を主たる原因とするものも含まれている。カンボジアにおいて法整備支援に携わる長期派遣専門家としては，カンボジアの法律実務家の自主性は尊重しつつ，今後もセミナー等を通して法律実務家の法の理解を促進し，誤った運用を自ら正してもらうための手助けをしていきたい。